ទស្សនាវដ្តីនៃមជ្ឈមណ្ឌលឯកសារកម្ពុជា

# ស្វែងរកការពិត



◆ ខួបលើកទី៥៦ នៃការដាក់ឱ្យប្រើប្រាស់ឡើងវិញ នូវរូបិយប័ណ្ណ ខ្មែររៀល ថ្ងៃទី២០ ខែមីនា ឆ្នាំ២០២៦

◆ ការសាងសង់ដោយខុសច្បាប់របស់ថៃ

ចែកជូនដោយឥតគិតថ្លៃដល់មន្ទីរ ស្រុក និងឃុំ ទូទាំងព្រះរាជាណាចក្រកម្ពុជា លេខ៣១៥ ខែមីនា ឆ្នាំ២០២៦

# ទស្សនាវដ្ដីនៃមជ្ឈមណ្ឌលឯកសារកម្ពុជា

## មាតិកា

### សំបុត្រ


- ខួបលើកទី៤៦ នៃការដាក់ឱ្យប្រើប្រាស់ឡើងវិញនូវរូបិយប័ណ្ណ ខ្មែររៀល ........................ ១
- មួយជំនាន់នៃអ្នករស់រានមានជីវិតពីរបបខ្មែរក្រហម........................................ ៣
- កម្ពុជា និង ថៃ ........................................ ៤
- រដ្ឋមន្ត្រីការបរទេស សីហស័ក្តិ ភួងកេតកែវ..... ៥
- ការសាងសង់ដោយខុសច្បាប់របស់ថៃ ......... ៦
- ការហាមឃាត់ទំនិញនាំចូលពីប្រទេសថៃ ...... ៧
- ការអះអាងរបស់ប្រធាននាយកដ្ឋានចារកម្មថៃ .. ៩


### ផ្នែកឯកសារ


- សូមរាយការណ៍ជូន ៨៧០ ជ្រាប.............. ១០
- ឡាយ ម៉េងហុង ហៅ ហាន៖ មន្ទីរសេនា ..... ១១


### ផ្នែកប្រវត្តិសាស្ត្រ និងការស្រាវជ្រាវ


- ខ្ញុំសូមអំពាវនាវផ្តល់យុត្តិធម៌ដល់ខ្ញុំ............ ១៥
- គឹម លឹម ៖ កងនារីចល័តតំបន់៣១........... ១៨
- ខ្ញុំបាត់បង់កូនប្រុសជាទីស្រឡាញ់ ដោយសារ...២១
- ហ៊ិន់ សុខុម ៖ អតីតទាហានប៉ារ៉ានៅជំរំ...... ២៥
- ប្តីរបស់ខ្ញុំស្លាប់ដោយសារត្រូវអំបែងគ្រាប់...២៧
- រដ្ឋបាលស្រុកបុរីអូរស្វាយ-សែនជ័យ ........២៩
- «ស្ពាបត្យកម្មបណ្ណាល័យ ហ្វូងម៉ែ» .............៣១
- សិស្សានុសិស្សថ្នាក់ទី៩ នៃវិទ្យាល័យ ..... ៣៤
- ម្ចាស់ទឹកឃ្មុំ នៅអគារមរតកសង្គមរាស្ត្រនិយមសម្តេចឪ- សម្តេចម៉ែ ......................... ៣៦
- ជនជាតិដើមភាគតិចស្ទៀងដែល ............. ៣៨


### ផ្នែកវេទិកាពិភាក្សាសាធារណៈ


- ទិវាសិទ្ធិនារីអន្តរជាតិឆ្នាំ២០២៦៖ បន្ត ........៤១
- ការលើកកម្ពស់សមភាពយេនឌ័រ និងការគាំទ្រអនាគតកុមារី នៅភូមិអូរស្វាយ ............. ៤៣




មេដឹកនាំខ្មែរក្រហមទទួលគណៈប្រតិភូ ឡាវ នៅព្រលានយន្តហោះពោធិ៍ចិនតុង។ (បណ្ណសារមជ្ឈមណ្ឌលឯកសារកម្ពុជា)


- វេទិកាថ្នាក់រៀនស្តីពីប្រវត្តិសាស្ត្រ ........... ៤៦
- វេទិកាថ្នាក់រៀនស្តីអំពី «ប្រវត្តិសាស្ត្រកម្ពុជា .. ៥០
- មជ្ឈមណ្ឌលឯកសារកោះថ្មរៀបចំវេទិកា .... ៥៣


### ផ្នែកស្រាវជ្រាវរកក្រួសារ


- ប្អូនប្រុសដែលបាត់ខ្លួន ........................ ៥៧
- ជាតិនេះ ខ្ញុំប៉ិះតែនឹងស្លាប់ចំនួន១៤លើក..... ៥៩


**រក្សាសិទ្ធិ**
មជ្ឈមណ្ឌលឯកសារកម្ពុជា
អនុញ្ញាតឱ្យបោះពុម្ពផ្សាយដោយ
ក្រសួងព័ត៌មាននៃព្រះរាជាណាចក្រកម្ពុជា
ប្រកាសទេសរដ្ឋមន្ត្រី និងរដ្ឋមន្ត្រីក្រសួងព័ត៌មាន
លេខ៣៧៥ព.មប្រក
ចុះថ្ងៃទី៣០ ខែតុលា ឆ្នាំ២០១៨
រូបថតឯកសារ៖ មជ្ឈមណ្ឌលឯកសារកម្ពុជា

**ស្នេរលេខនេះ ៖** ឆាំង យុ, កែវ សុភី, ឡុង ដានី, គាត ស្រីឡែន, ទាវ សម្ភស្ស, ស្រេង លីដា, ចាន់ណារិទ្ធ, ស៊ាង ចិន្តា, វី ស៊ីថា, សូ ហ្វារីណា, លី សុខឃាង, វ៉ន បុប្ផា, ស្រ៊ាង លីហ៊ួរ និង សៀវ សុផុន
**អ្នកនិពន្ធ និងស្រាវជ្រាវ៖** មីន សាណាស់ **អ្នកបកប្រែ៖** លឹម អ៊ិភីង និង ជ័យ ចាន់ស៊ីណែត **និពន្ធនាយកទូទៅ៖** សោម ប៊ុនថន
**ជំនួយការនិពន្ធនាយក៖** ដា៉រដ្ឋ មេត្តា **ក្រាហ្វិកកុំព្យូទ័រ៖** លី សេនសូនី ឡា **គ្រប់គ្រងការចែកផ្សាយ៖** ឆេង វ៉េង

Email: dccam@online.com.kh, Homepage: www.dccam.org, www.cambodiasri.org

# ខួបលើកទី៤៦
## នៃការដាក់ឱ្យប្រើប្រាស់ឡើងវិញ នូវរូបិយប័ណ្ណ ខ្មែររៀល
## ថ្ងៃទី២០ ខែមីនា ឆ្នាំ២០២៦

**ឆាំង យុ**



*កម្មាភិបាលខ្មែរក្រហមបាចក្រដាសប្រាក់ចោល នៅពេលរបបខ្មែរក្រហមទទួលជ័យជម្នះ នៅថ្ងៃទី១៧ ខែមេសា ឆ្នាំ១៩៧៥។ (បណ្ណសារមជ្ឈមណ្ឌលឯកសារកម្ពុជា)*

*កិច្ចសម្ភាសន៍រវាងគិរីផូស និងលោក ឆាំង យុ នាយកមជ្ឈមណ្ឌលឯកសារកម្ពុជា ស្តីអំពី «ការលុបបំបាត់រូបិយប័ណ្ណក្នុងរបបខ្មែរក្រហម» ៖*

**គិរីផូស៖ តើអ្នកអាចបកស្រាយបានទេថា ហេតុអ្វីបានជាខ្មែរក្រហមលុបបំបាត់ការប្រើប្រាស់រូបិយប័ណ្ណទាំងស្រុង នៅពេលដែលខ្លួនឡើងកាន់អំណាច?**

**ឆាំង យុ៖** *រូបិយប័ណ្ណគឺជាមធ្យោបាយឆ្ពោះទៅកាន់សេរីភាព និងអំណាច ហើយមនោគមវិជ្ជាខ្មែរក្រហមមិនចង់ឱ្យមានវត្តមានរូបិយប័ណ្ណ ព្រោះថារូបបិយប័ណ្ណអាចបង្កជាហានិភ័យដល់យុទ្ធសាស្ត្ររបស់ខ្មែរក្រហមក្នុងការក្តោបក្តាប់អំណាច និងសេរីភាពទាំងស្រុងទៅលើសង្គមខ្មែរ។ ទោះបីជាក្នុងចំនួនតិចតួចបំផុតក្តី រូបិយប័ណ្ណអាចផ្តល់អំណាច និងសេរីភាពដល់បុគ្គលក្នុងការសម្រេចចិត្តដោយឯករាជ្យលើអ្វីមួយ ហើយកត្តានេះគឺជាអ្វីដែលខ្មែរក្រហមមិនអាចទទួលយកបាន។ ការលុបបំបាត់រូបិយប័ណ្ណគឺស្មើទៅនឹងការដកហូតអំណាចរបស់ប្រជាជនក្នុងការសម្រេចចិត្តថាតើត្រូវចាត់ចែងរូបិយប័ណ្ណនោះដោយរបៀបណា។*

**គិរីផូស៖ នៅក្នុងតថភាពជាក់ស្តែង តើសេដ្ឋកិច្ច "គ្មានរូបិយប័ណ្ណ" មានឥទ្ធិពលយ៉ាងដូចម្តេចខ្លះចំពោះប្រជាជនខ្មែរសាមញ្ញ?**

**ឆាំង យុះ៖** *ក្នុងទ្រឹស្តី ក្រោមការគ្រប់គ្រងរបស់ខ្មែរក្រហម រដ្ឋគឺមានសិទ្ធិផ្តាច់មុខលើទំនិញ សេវាកម្ម និងទ្រព្យសម្បត្តិទាំងអស់ដូច្នេះសង្គមដែលគ្មានរូបិយប័ណ្ណមួយ ត្រូវបានកសាងឡើងដោយផ្អែកលើការដោះដូរធម្មតាទៅតាមទម្រង់នៃការបែងចែកធនធានដែលកំណត់ដោយរដ្ឋ និងការប្រើប្រាស់ភាពភ័យខ្លាចជាយន្តការក្នុងការអនុវត្តប្រព័ន្ធនេះ។*

**គិរីផូស៖ តើប្រជាជនអាចរស់រាន និងដោះដូរទំនិញដោយគ្មានរូបិយប័ណ្ណក្នុងអំឡុងពេលនោះយ៉ាងដូចម្តេច?**

**ឆាំង យុះ៖** *នៅពេលដែលរដ្ឋគ្រប់គ្រងលើអ្វីៗទាំងអស់ សូម្បីតែសកម្មភាពដ៏សាមញ្ញបំផុត ដូចជាការទទួលបានអាហារសម្រាប់បរិភោគ ជម្រក និងពេលវេលាសម្រាកផ្ទាល់ខ្លួន គឺសុទ្ធសឹងតែជាធនធានដែលរដ្ឋអំណាចជាអ្នកសម្រេចថាត្រូវផ្តល់ឱ្យ ឬបដិសេធទៅតាមតែអំពើចិត្ត។ អ្វីៗគ្រប់យ៉ាងមានប្រភពចេញពីរដ្ឋ ព្រោះរដ្ឋជាអ្នកគ្រប់គ្រងអ្វីៗទាំងអស់ ឬយ៉ាងហោចណាស់ នេះគឺជាគោលបំណងរបស់អ្នកដឹកនាំរដ្ឋ។ អ្នកអាចទទួលបានអាហារមួយពេល ប្រសិនបើអ្នកខិតខំប្រឹងធ្វើការនៅថ្ងៃនោះ ឬអ្នកអាចទទួលបានការអនុញ្ញាតឱ្យចំណាយពេលវេលាផ្ទាល់ខ្លួនជាមួយគ្រួសារ ប្រសិនបើអ្នកស្មោះត្រង់នឹងរបបនោះ។ ទាំងនេះគឺជាឧទាហរណ៍នៃការដែលប្រព័ន្ធនេះដំណើរការជាក់ស្តែង។*

**គិរីផូស៖ តើមានប្រព័ន្ធពាណិជ្ជកម្មក្រៅផ្លូវការ ឬបណ្តាញលួចលាក់ កើតមានដែរឬទេ បើទោះបីជាមានការហាមឃាត់ការប្រើប្រាស់រូបិយប័ណ្ណ?**

**ឆាំង យុះ៖** *រដ្ឋបានប៉ុនប៉ងគ្រប់គ្រងទៅលើគ្រប់ទម្រង់នៃអំណាច ដោយរួមទាំងសកម្មភាពសេដ្ឋកិច្ច។ ទោះបីជាយ៉ាងណាក្តី វាគឺជារឿងលំបាកក្នុងការអនុវត្តឱ្យបានដាច់ខាត។ ជាក់ស្តែង រដ្ឋអំណាចផ្ទាល់ បានឆ្លៀតឱកាសប្រើប្រាស់តួនាទីរបស់ខ្លួនដើម្បីអនុវត្តសិទ្ធិសម្រេចដោយអត្តនោម័តិ (ស៊ុយភាព) ចំពោះរឿងផ្ទាល់ខ្លួន ហើយក្នុងករណីខ្លះទៀតមានប្រព័ន្ធដោះដូរក្រៅផ្លូវការបានប្រព្រឹត្តទៅក្រោមហេតុផលនេះ។ ជាឧទាហរណ៍ យោធាបានដោះដូររបស់របរសាមញ្ញៗដែលខ្លួនទទួលបាន។ ប្រជាជនអាចនឹងធ្វើការងារ ឬផ្តល់សេវាកម្មជាក់លាក់ណាមួយ ដើម្បីដោះដូរជាមួយនឹងទំនិញជាក់លាក់ណាមួយ។ ខណៈពេលដែលខ្មែរក្រហមចង់គ្រប់គ្រងលើអ្វីៗទាំងអស់ ខ្មែរក្រហមបែរជាបង្កើតលក្ខខណ្ឌដែលធ្វើឱ្យស៊ុយភាពក្លាយជារឿងលាក់កំបាំងទៅវិញ។*

**គិរីផូស៖ តើការលុបបំបាត់រូបិយប័ណ្ណ បន្សល់ទុកផលប៉ះពាល់នៅលើផ្នែកសេដ្ឋកិច្ច និងផ្លូវចិត្ត ក្នុងរយៈពេលវែងយ៉ាងដូចម្តេចខ្លះ ចំពោះសង្គមកម្ពុជា?**

**ឆាំង យុះ៖** *ផលប៉ះពាល់ទៅលើផ្នែកសេដ្ឋកិច្ច និងផ្លូវចិត្តរយៈពេលវែង គឺមានទំហំមហាសាល។ កម្ពុជាបានឆ្លងកាត់វិបត្តិអស់ជាច្រើនទសវត្សរ៍ ក្នុងការស្តារសេដ្ឋកិច្ចឡើងវិញ ហើយឥទ្ធិពលទាំងនោះ នៅតែបន្តរហូតមកដល់សព្វថ្ងៃនេះ។ ជាឧទាហរណ៍ ប្រជាពលរដ្ឋខ្មែរ ដែលជាអ្នករស់រានមានជីវិតពីរបបខ្មែរក្រហម បានបង្កើតជាទម្លាប់ជាក់លាក់ចំពោះផ្នែកហិរញ្ញវត្ថុ និងផ្នែកសេដ្ឋកិច្ច ភាពភ័យខ្លាច និងទំនោរមួយចំនួនដែលបានផ្ទេរបន្តទៅកាន់មនុស្សជំនាន់ក្រោយរបស់ខ្លួន។ ផលប៉ះពាល់បង្កឡើងដោយរបបខ្មែរក្រហមមានភាពស្មុគស្មាញ ព្រមទាំងបន្តជះឥទ្ធិពលដល់មនុស្សជាច្រើនជំនាន់។*



*ធនាគារជាតិកម្ពុជាក្នុងរបបខ្មែរក្រហម។ (បណ្ណសារមជ្ឈមណ្ឌលឯកសារកម្ពុជា)*

# មួយជំនាន់នៃអ្នករស់រានមានជីវិត ពីរបបខ្មែរក្រហម

ឆាំង យុ



*លោក ឆាំង យុ នៅស្រុកព្រៃកប្បាស ខេត្តតាកែវ នៅឆ្នាំ១៩៩៥។ (បណ្ណសារមជ្ឈមណ្ឌលឯកសារកម្ពុជា)*

មានការប៉ាន់ស្មានថា ប្រជាជនកម្ពុជាយ៉ាងហោចណាស់គឺ៥លាននាក់ដែលបានរស់រានមានជីវិតពីរបបប្រល័យពូជសាសន៍ខ្មែរក្រហម កើតមានឡើងនៅចន្លោះឆ្នាំ១៩៧៥ ដល់ឆ្នាំ១៩៧៩។ រយៈពេល ៤៧ឆ្នាំក្រោយមក ស្ថិតនៅក្នុងជំនាន់នៃអ្នករស់រានមានជីវិតពីរបបប្រល័យពូជសាសន៍ខ្មែរក្រហម ប្រជាជនកម្ពុជា ទាំងអស់នេះគឺជាកម្លាំងចលករដ៏សំខាន់ក្នុងការស្តារកម្ពុជាឡើងវិញពីគំនរផេះផង់ពោលគឺការកសាងប្រទេសជាតិពីចំណុចទាបបំផុត ឆ្ពោះទៅសម្រេចបានចំណុចមួយដែលកម្ពុជាអាចចូលរួមនៅក្នុងតំបន់ និងពិភពលោកនាពេលបច្ចុប្បន្ន ក្នុងនាមជាប្រទេសកំពុងអភិវឌ្ឍន៍ដ៏រីកលូតលាស់។ ប្រទេសកម្ពុជា សូមសម្តែងសេចក្តីដឹងគុណចំពោះមនុស្សមួយជំនាន់នេះដែលគឺជា «ជំនាន់ដ៏អស្ចារ្យបំផុត» បានកសាងប្រទេសជាតិឡើងវិញនិងបានបើកផ្លូវសម្រាប់អនាគតរបស់កម្ពុជា។

# កម្ពុជា និង ថៃ

ឆាំង យុ



*មេបញ្ជាការកងទ័ពភូមិភាគ១ថៃ ឧត្តមសេនីយ៍ឯក វរយស លឿងសុវណ្ណ ដើរកាត់ផ្ទាំងកៅស៊ូខ្មៅដែលកងទ័ពថៃបាំងនៅក្នុងទឹកដីស្រុកអូរជ្រៅ ខេត្តបន្ទាយមានជ័យ ប្រទេសកម្ពុជា ។ (បណ្ណសារមជ្ឈមណ្ឌលឯកសារកម្ពុជា)*

ខុសពីប្រជាពលរដ្ឋថៃដែលគួរតែចោទសួររដ្ឋាភិបាលរបស់ខ្លួនចំពោះការបន្តជម្លោះព្រំដែន ប្រជាជនកម្ពុជាគួរតែផ្តល់ការគាំទ្របន្ថែមទៀតដល់រាជរដ្ឋាភិបាលរបស់ខ្លួនដែលកំពុងព្យាយាមបញ្ចប់ជម្លោះនេះដោយសន្តិវិធី។

កងទ័ពកម្ពុជាមិនបានចូលកាន់កាប់ទឹកដីថៃនោះទេ ផ្ទុយទៅវិញគឺយោធាថៃទេដែលបានឈ្លានពានទឹកដីកម្ពុជា ហើយរាជរដ្ឋាភិបាលកម្ពុជាកំពុងព្យាយាមចរចាដោយសន្តិវិធីដើម្បីឱ្យយោធាថៃទាំងនោះដកកម្លាំងរបស់ខ្លួនចេញពីទឹកដីកម្ពុជា។

បើនិយាយឱ្យងាយយល់គឺរាជរដ្ឋាភិបាលកម្ពុជា «ជាបុគ្គលមានភាពចាស់ទុំ» ក្នុងកិច្ចការនេះ ហើយប្រជាជនកម្ពុជាគួរតែគាំទ្រវិធីសាស្ត្របែបចាស់ទុំជាជាងរបៀបដែលពលរដ្ឋថៃមានប្រតិកម្មស្រួចស្រាល់ចំពោះសកម្មភាពឈ្លានពាន និងការរំលោភបំពានយ៉ាងអាម៉ាស់របស់យោធាថៃមកលើទឹកដីប្រទេសជិតខាងរបស់ខ្លួន។

# រដ្ឋមន្ត្រីការបរទេស សីហស័ក្តិ ភួងកេតកែវ ចង់ឃើញសន្តិភាពនៅមជ្ឈិមបូព៌ា

**ឆាំង យុ**




*រដ្ឋមន្ត្រីការបរទេសថៃ សីហស័ក្តិ ភួងកេតកែវ។ (បណ្ណសារមជ្ឈមណ្ឌលឯកសារកម្ពុជា)*

ខណៈពេលដែលរដ្ឋាភិបាលថៃរក្សាជំហរអព្យាក្រឹតក្នុងសង្គ្រាមជាមួយអ៊ីរ៉ង់ យោធាថៃចង់ប្រើប្រាស់ឱកាសនេះដើម្បីកម្ចាត់កងទ័ពកម្ពុជា និងអនុវត្តការផ្លាស់ប្តូររបបដឹកនាំរបស់ខ្លួនឯង។ សង្គ្រាមនៅអ៊ីរ៉ង់គឺជាលេសបិទបាំងសម្រាប់ការឈ្លានពានរបស់យោធាថៃនាពេលអនាគតផង និងជាការបង្វែរអារម្មណ៍មហាអំណាចពិភពលោក ចំពោះអ្វីដែលកំពុងកើតឡើងនៅក្នុងតំបន់អាស៊ីអាគ្នេយ៍ថែមទៀតផង។

អាស្រ័យលើកាលៈទេសៈទាំងនេះ វាគឺមិនមែនជារឿងគួរឱ្យភ្ញាក់ផ្អើលនោះទេ ប្រសិនបើមានការផ្ទុះជម្លោះម្តងទៀតរវាងកម្ពុជានិងថៃ។ វាអាចទៅរួចហើយថាអ្វីតែមួយគត់ដែលអាចរារាំងយោធាថៃមិនឱ្យបន្តទៅមុខទៀតនោះគឺប្រវត្តិសាស្ត្រ។ ប្រជាជនកម្ពុជាមានប្រវត្តិសាស្ត្រថាគឺជាអ្នកដែលពិបាកតទល់ជាមួយបំផុត។ ខ្មែរក្រហមបានបង្ហាញឱ្យឃើញរួចមកហើយតាមរយៈការប្រយុទ្ធគ្នាអស់រយៈពេលជាច្រើនទសវត្សរ៍កន្លងមកហើយ។

# ការសាងសង់ដោយខុសច្បាប់របស់ថៃ

**ឆាំង យុ**



កងទ័ពថៃដាក់កុងតឺន័រ និងរាយលួសបន្លាព័ទ្ធយកដីប្រជាជនជនខ្មែរនៅស្រុកថ្មពួក ខេត្តបន្ទាយមានជ័យ។ (បណ្ណសារមជ្ឈមណ្ឌលឯកសារកម្ពុជា)



សកម្មភាពសាងសង់ និងការអភិវឌ្ឍន៍ហេដ្ឋារចនាសម្ព័ន្ធរបស់ប្រទេសថៃ នៅលើទឹកដីកម្ពុជា គឺជាការរំលោភបំពានលើច្បាប់អន្តរជាតិ សាលក្រមរបស់តុលាការយុត្តិធម៌អន្តរជាតិ កិច្ចព្រមព្រៀងឈប់បាញ់ដែលសម្របសម្រួលដោយសហរដ្ឋអាមេរិកនិងអាស៊ាន និងដែនអធិបតេយ្យភាពរបស់ប្រទេសកម្ពុជា។

សកម្មភាពទាំងនេះ មិនមែនជាកាលៈទេសៈដែលត្រូវយកមកបកស្រាយតាមបែបច្នៃប្រឌិត ឬដេញដោលវែកញែកនោះទេ ទាំងនេះគឺជាតថភាពពិតជាក់ស្ដែង ហើយវាហាក់ដូចជាមានលទ្ធផលតែពីរប៉ុណ្ណោះ ដែលអាចកើតចេញពីតថភាពពិតទាំងនេះ។ លទ្ធផលមួយគឺ នៅទីបំផុត ប្រទេសថៃនឹងពិចារណាឡើងវិញចំពោះសកម្មភាពទាំងនេះ ហើយចាប់ផ្ដើមឆ្ពោះទៅរកការដោះស្រាយវិវាទព្រំដែនដោយសន្តិវិធី ឬលទ្ធផលមួយទៀតគឺប្រទេសថៃនៅតែបន្តបញ្ហាដែលបានក្លាយជាជម្លោះឆ្លងជំនាន់រវាងប្រទេសជិតខាងទាំងពីរ។

វិធីសាស្ត្រជាតិនិយមបែបឈ្លានពានរបស់ប្រទេសថៃ ចំពោះទំនាក់ទំនងរបស់ខ្លួនជាមួយប្រទេសកម្ពុជា គឺជាយុទ្ធសាស្ត្រមួយដែលនឹងមិនផ្ដល់ជាផលប្រយោជន៍អ្វីទាំងអស់ ក្រៅពីទុក្ខវេទនាសម្រាប់ប្រទេសទាំងពីរ ក៏ដូចជាតំបន់ទាំងមូលដែរ។

# ការហាមឃាត់ទំនិញនាំចូលពីប្រទេសថៃ គឺស្របទៅនឹងផែនការយុទ្ធសាស្ត្ររបស់ថៃ

**ឆាំង យុ**



*ស្រឡាងចម្លងរថយន្តដឹកទំនិញ និងប្រជាជន ឡាវឆ្លងកាត់ទន្លេមេគង្គ។ (បណ្ណសារមជ្ឈមណ្ឌលឯកសារកម្ពុជា)*

នាពេលថ្មីៗនេះ លោក សរ សុពុត្រា អភិបាលខេត្តស្ទឹងត្រែង បានថ្លែងថា «កម្ពុជាគឺមិនអាចហាមឃាត់ទំនិញនាំចូលពីប្រទេសថៃទាំងស្រុងបានទេ ព្រោះយើងជាសមាជិកនៃអង្គការពាណិជ្ជកម្មពិភពលោក និងសមាគមប្រជាជាតិអាស៊ីអាគ្នេយ៍ (អាស៊ាន)»។ មតិលើកឡើងរបស់លោក ត្រូវទទួលរងការរិះគន់។ ទោះបីជាយ៉ាងណាក្តី ការចាត់វិធានការហាមឃាត់ទំនិញនាំចូលពីប្រទេសថៃ មិនមែនជាសកម្មភាពឈ្លាសវៃសម្រាប់កម្ពុជានោះទេ។

ស្ថានភាពភូមិសាស្ត្រនយោបាយរបស់កម្ពុជាតែងតែមានភាពស្មុគស្មាញ លំបាកលំបិន និងប្រឈមនឹងគ្រោះថ្នាក់ ហើយនៅក្នុងបរិបទសព្វថ្ងៃ គឺគ្មានអ្វីខុសប្លែកឡើយ។ ប្រទេសកម្ពុជា ត្រូវតែប្រកាន់ខ្ជាប់វិន័យក្នុងការអនុវត្តទំនាក់ទំនងការបរទេសឥរិយាបថយោធា ព្រមទាំងគោលនយោបាយសេដ្ឋកិច្ច និងពាណិជ្ជកម្មរបស់ខ្លួន។ ដូចដែលខ្ញុំធ្លាប់បានលើកឡើងនៅក្នុងអត្ថបទវិចារណកថាដទៃទៀត ជម្លោះបច្ចុប្បន្នរវាងប្រទេសកម្ពុជា និងប្រទេសថៃគឺកើតចេញពីការប្រឈមតតាំងគ្នារវាងប្រទេសទាំងពីរ ដោយអូសបន្លាយអស់រយៈកាលជាច្រើនជំនាន់មកហើយ។ ការប្រឈមតតាំងគ្នាអស់រយៈកាលជាច្រើនជំនាន់នេះ មិនអាចសម្រេច ឬដោះស្រាយបានតាមរយៈសកម្មភាព ឬការយកជ័យជម្នះភ្លាមៗបានឡើយ។ ផ្ទុយទៅវិញ ការប្រឈមតតាំងគ្នានេះ ទាមទារនូវ



រូបរាប់ពីស្ដាំ៖ លោក ឆាំង យុ នាយកមជ្ឈមណ្ឌលឯកសារកម្ពុជា, សម្ដេចរាជបុត្រីព្រះអនុជ នរោត្ដម អរុណរស្មី ឧត្ដមប្រឹក្សាផ្ទាល់ព្រះមហាក្សត្រ និងជាសមាជិកាព្រឹទ្ធសភា និងឯកឧត្ដម សរ សុពុត្រា អភិបាលខេត្តស្ទឹងត្រែង ទស្សនកិច្ចសហគមន៍បុរីអូរស្វាយ ក្នុងស្រុកបុរីអូរស្វាយ សែនជ័យ ខេត្តស្ទឹងត្រែង។ (បណ្ណសារមជ្ឈមណ្ឌលឯកសារកម្ពុជា)

យុទ្ធសាស្ត្ររយៈពេលវែង ដោយឈរលើមូលដ្ឋាននៃភាពអត់ធ្មត់។ ប្រទេសកម្ពុជា មិនគួរបណ្ដែតបណ្ដោយខ្លួនទៅតាមអារម្មណ៍មួយកម្រូល រួចចាត់ជាវិធានការតបដោយកំរោល ចំពោះការហាមឃាត់ទំនិញនាំចូលពីប្រទេសថៃទាំងស្រុង ដែលសកម្មភាពនេះ នឹងបង្កជាផលប៉ះពាល់ចំពោះស្ថានភាពសេដ្ឋកិច្ច និងផលប្រយោជន៍ជាយុទ្ធសាស្ត្ររយៈពេលវែងរបស់កម្ពុជាទៅវិញ។

ក្រៅពីជាការប្រឈមតទល់គ្នាជាច្រើនជំនាន់ ជម្លោះបច្ចុប្បន្ននេះ នឹងមិនអាចសម្រេចបុដោះស្រាយបានតាមរយៈការប្រកួតប្រជែងជាយុទ្ធសាស្ត្រតែមួយមុខ។ កម្ពុជា ត្រូវតែអនុវត្តភាពជាអ្នកដឹកនាំវិន័យ និងយុទ្ធសាស្ត្រប្រកបដោយថាមវន្ត នៅគ្រប់វិស័យនៃអំណាចជាតិ ដែលរួមមានវិស័យនយោបាយ វិស័យយោធា វិស័យការទូត វិស័យសេដ្ឋកិច្ច និងវិស័យព័ត៌មាន។ តើការហាមឃាត់ទាំងស្រុងលើទំនិញនាំចូលពីប្រទេសថៃ អាចនឹងផ្ដល់ផលចំណេញសេដ្ឋកិច្ចខ្លះ ឬយ៉ាងណានោះ គឺមិនមានភាពច្បាស់លាស់ទេ ប៉ុន្តែអ្វីដែលច្បាស់លាស់នោះគឺ ការហាមឃាត់ទំនិញនាំចូលពីប្រទេសថៃទាំងស្រុង ប្រាកដជាស្របទៅនឹងផែនការរបស់របបដឹកនាំថៃ ដែលប៉ុនប៉ងធ្វើឱ្យកម្ពុជាស្ថិតនៅឯកោពីពិភពលោក។ យ៉ាងហោចណាស់ចាប់តាំងពីដើមសតវត្សរ៍ទី២០មក ប្រទេសថៃបានស៊ុះស្មែងសម្រេចឱ្យបាននូវគោលដៅនយោបាយការបរទេសដ៏ចម្រូងចម្រាសបំផុតមួយចំនួនរបស់ខ្លួនមកលើកម្ពុជា តាមរយៈការប្រកាន់ខ្ជាប់នូវយន្តការទេ្វភាគីនិយម។ ម្ដងហើយម្ដងទៀត មហិច្ឆតាជាតិនិយមរបស់ថៃមកលើកម្ពុជា ត្រូវបានរារាំងពីសំណាក់មហាអំណាចបរទេស ជាពិសេសគឺប្រទេសបារាំង និងសហរដ្ឋអាមេរិក។ នៅពេលដែលកម្ពុជាត្រូវបានកាត់ផ្ដាច់ឱ្យនៅឯកោពីពិភពលោក ថៃអាចបង្កើនការទាញយកផលប្រយោជន៍ពីកម្ពុជា ហើយច្បាស់ណាស់ ថៃនឹងលើកឡើងថា សកម្មភាពដែលកម្ពុជាដាក់ចេញចំពោះវិស័យសេដ្ឋកិច្ចនេះ ជាការប្រមាថដល់ច្បាប់ និងទំនៀមទម្លាប់អន្តរជាតិ។

ប្រទេសកម្ពុជា បានអនុវត្តភាពចាស់ទុំដ៏វិសេសវិសាលរបស់ខ្លួនតទល់ទៅនឹងការឈ្លានពានជាច្រើនលើកច្រើនសាររបស់ប្រទេសថៃ ហើយកម្ពុជាមិនត្រូវចុះញ៉ម ទោរទន់ ឬបាត់បង់ជំនឿចិត្តលើសមត្ថភាពរបស់ខ្លួនក្នុងការទទួលបានជ័យជម្នះឡើយ។ កម្ពុជានឹងទទួលបានជ័យជម្នះលើជម្លោះនេះ លុះត្រាតែកម្ពុជានៅតែបន្តរក្សាវិន័យ និងជំហរយុទ្ធសាស្ត្រនៅក្នុងការដាក់ចេញជាវិធានការរបស់ខ្លួន។



ភូមិរបស់ប្រជាជនឡាវនៅតាមដងទន្លេមេគង្គ ជាប់នឹងខេត្តស្ទឹងត្រែងប្រទេសកម្ពុជា។
(បណ្ណសារមជ្ឈមណ្ឌលឯកសារកម្ពុជា)

# ការអះអាងរបស់ប្រធាននាយកដ្ឋានចារកម្មថៃ ពីការផ្ទុះឡើងអរិភាព ខណៈយោធាថៃកំពុងកាន់កាប់ទឹកដីកម្ពុជាដោយខុសច្បាប់

**ឆាំង យុ**

ឧត្តមសេនីយ៍ឯក ធីរ៉ាណាន ណាន់ថាខ្វាង ប្រធាននាយកដ្ឋានចារកម្មនៃកងយោធពលភូមិន្ទថៃ បានធ្វើសេចក្តីថ្លែងការណ៍ដែលបង្កជាការងឿងឆ្ងល់មួយ អំពីការដែលកងយោធាថៃគួរតែបន្តការប្រុងប្រយ័ត្នខ្ពស់ចំពោះការផ្ទុះឡើងជាថ្មីនូវអរិភាពពីសំណាក់កងទ័ពកម្ពុជា នៅរយៈពេលបួនទៅប្រាំខែខាងមុខ ក្រោយពីរដូវវស្សាបញ្ចប់។

សេចក្តីថ្លែងការណ៍របស់លោកបានបង្កជាការងឿងឆ្ងល់ជាខ្លាំង ពីព្រោះថា ក្នុងនាមជាប្រធានចារកម្មថៃ លោកដឹងច្បាស់ជាងនរណាទាំងអស់ថា បច្ចុប្បន្នកងកម្លាំងយោធាថៃកំពុងកាន់កាប់ និងក្តោបក្តាប់ខុសច្បាប់លើទីតាំងជាច្រើននៅក្នុងទឹកដីកម្ពុជាដោយចំហ។ លោកថែមទាំងដឹងទៀតថា ការកាន់កាប់ដោយខុសច្បាប់ពីសំណាក់យោធាថៃនេះ បានបង្កជាផលវិបាកយ៉ាងច្បាស់ក្រឡែត ដែលមិនត្រឹមតែបានបំផ្លិចបំផ្លាញលើមូលដ្ឋានទ័ពកម្ពុជាតែប៉ុណ្ណោះទេ ប៉ុន្តែថែមទាំងបានផ្លាស់ទីប្រជាជនកម្ពុជាជាច្រើនគ្រួសារដោយបង្ខំ និងបង្កជាការខូចខាតដល់ទ្រព្យសម្បត្តិឯកជនរបស់ពលរដ្ឋកម្ពុជារួមទាំងប្រាសាទបុរាណនានា និងទីតាំងតំបន់បេតិកភណ្ឌពិភពលោកមួយកន្លែងក្នុងទឹកដីកម្ពុជាទៀតផង។ ទោះបីជាមានតថភាពជាក់ស្តែងច្បាស់ៗទាំងនេះក្តី លោកបែរជាលើកឡើងថា យោធាថៃដែលធ្វើសកម្មភាពការពារខ្លួន ត្រូវតែប្រុងប្រយ័ត្នចំពោះការឈ្លានពានបន្ថែមទៀតទៅវិញ។ នេះគឺជារឿងដ៏គួរឱ្យអស់សំណើចចំពោះរដ្ឋមួយ ដែលប្រកាសក្តែងៗជាសាធារណៈអំពីការព្រួយបារម្ភចំពោះការឈ្លានពាននាពេលអនាគត ខណៈពេលដែលខ្លួនកំពុងពង្រាយកម្លាំងយោធាកាន់កាប់លើទឹកដីនៃប្រទេសជិតខាងដោយខុសច្បាប់ ដែលជាការបំពានលើច្បាប់អន្តរជាតិ និងកិច្ចព្រមព្រៀងឈប់បាញ់។ កាលៈទេសៈនេះ គឺប្រៀបបានទៅនឹងជនពាល ដែលដើរបៀតបៀនគេ ហើយប្រកាសប្រាប់ពិភពលោកថា ខ្លួនត្រូវតែប្រយ័ត្នប្រយែង ដើម្បីទប់ស្កាត់ការការពារខ្លួនរបស់ជនរងគ្រោះដែលនឹងអាចកើតមានទៅវិញ។ ពិតណាស់ យើងកំពុងរស់នៅក្នុងសម័យកាលដែលពោរពេញដោយភាពចម្រូងចម្រាស់ នៅពេលជនពាលដែលបៀតបៀនគេបន្ទំធ្វើជាជនរងគ្រោះ ហើយជនរងគ្រោះពិតប្រាកដ បែរជាត្រូវបង្ហាញនូវភាពចាស់ទុំ និងការអត់ធ្មត់ខ្ពស់ ក្នុងការដោះស្រាយជម្លោះដោយសន្តិវិធីទៅវិញ។ វាគឺជាសំណាងរបស់ប្រទេសថៃ តំបន់ និងពិភពលោក ដែលកម្ពុជាមានផ្លូវចិត្តរឹងមាំ មានវិន័យ និងមានភាពចាស់ទុំក្នុងការខិតខំដោះស្រាយជម្លោះដោយអត់ធ្មត់តាមសន្តិវិធី និងនឹងនរជាជាងជ្រើសរើសការធ្វើប្រតិកម្មតបសមហេតុសមផល តាមរយៈការបង្កើនទម្ងន់ជម្លោះ និងការពង្រីកវិសាលភាពនៃសង្គ្រាមយោធា។



ប្រជាជនភៀសសឹកពីការឈ្លានពានពីយោធាថៃនៅតំបន់បឹងត្រកួន ស្រុកថ្មពួក ខេត្តបន្ទាយមានជ័យ។ (បណ្ណសារមជ្ឈមណ្ឌលឯកសារកម្ពុជា)

ទូរលេខ ៖ ២២

៣៦២ ៖ ខ្ទង់

# សូមរាយការណ៍ជូន ៨៧០ ជ្រាប

ដកស្រង់ចេញពីឯកសារ D០១៩៦៨

**សោម ប៊ុនថន**

១- ថ្ងៃ២០.១២ នេះ វេលាម៉ោង១ ៣០នាទី រសៀល មានយន្តហោះខ្មាំងចំនួន៤គ្រឿង ធុនមិច២គ្រឿង និងអាប្រហោងគូថ២គ្រឿង មកទម្លាក់គ្រាប់បែក និងបាញ់រះនៅមុខសញ្ញាបន្ទាយទី១ ច័ន្ទគីរី និងជីរំចំបក់ អស់រយៈពេលមួយម៉ោងកន្លះជាង។

២- ថ្ងៃដដែលវេលាម៉ោង៥ល្ងាច មានយន្តហោះធុនប្រហោងគូថចំនួន ២គ្រឿង ដដែលមកទម្លាក់គ្រាប់បែក និងបាញ់រះនៅម្តុំម៉ក់ហឹន តាមដួរផ្លូវទៅភ្នំម៉ាឡៃ អស់រយៈពេល៤០វិនាទី។

៣- យោងតាមសភាពការណ៍ខាងលើនេះ យើងបាញ់កាំភ្លើង៦០ មីលីម៉ែត្រ និង៨២មីលីម៉ែត្រមួយចំនួនទៅលើទីតាំងវាមុខអូរជ្រៅ។ ឃើញច្បាស់ពេលដែលយើងបាញ់ចូលទីតាំងវានៅទល់មុខអូរជ្រៅនោះ ពួកវាបាញ់តមកវិញ ដោយកាំភ្លើង ៨២មីលីម៉ែត្រ និង៦០មីលីម៉ែត្រ និងអឹម៧៩ វាផ្លោងចេញពីមុខអូរជ្រៅជាច្រើនគ្រាប់។

៥- ការដែលខ្មាំងទម្លាក់គ្រាប់បែក និងបាញ់រះលើយើងនេះ បណ្តាលឱ្យឆេះផ្ទះយើង និងអង្ករ ២កំណាត់បាវ និងចានឆ្នាំងមួយចំនួនត្រូវខូច។ ការរាយការណ៍ បូកសរុបមិនបានល្អិតទេ ចាំរាយការណ៍ពេលក្រោយថែមទៀត។

៦- ថ្ងៃ២១.១២ មានការប្រយុទ្ធគ្នា តាំងពីព្រឹករហូតដល់ម៉ោង៧ ល្ងាច ម៉ោង២រសៀល យើងបាញ់យន្តហោះ ធុនអាទ្រុងជ្រូកធ្លាក់មួយគ្រឿងនៅក្នុងដីយើង ចម្ងាយជាង២គីឡូពីព្រំដែន អ្នកបើកយន្តហោះ លោតឆ័ត្រ ហើយគ្នាវាចុះឧទ្ធម្ភាគចក្រយកទៅវិញបាន តែសម្បកយន្តហោះនៅក្នុងដីយើង ២គីឡូ។

៧- ព្រឹកថ្ងៃ២២.១២ អត់មានការបាញ់ទេ។

៨- អាទូតស៊ុយអែត និងប្រពន្ធវាចូលមក វាដើរចូលមកប្រហែល១គីឡូ បងប្អូនយោធាយើងបើក ឡានហ្ស៊ីបទៅទទួលវា។

ដោយភាតរភាពបដិវត្តន៍យ៉ាងកក់ក្តៅបំផុត
ញឹម និង ហែម
ថ្ងៃ២២.១២.៧៧
ទទួលថ្ងៃ២២.១២.៧៧ ម៉ោង ២៣ ០០
បញ្ជាក់ជូនអង្គការ ៖ ទូរលេខនេះ
មិនឃើញខទី៤



កងទ័ពការពារដែនសមុទ្រនៅក្នុងរបបកម្ពុជាប្រជាធិបតេយ្យ។
(បណ្ណសារមជ្ឈមណ្ឌលឯកសារកម្ពុជា)

# ឡាយ ម៉េងហុង ហៅ ហាន ៖ មន្ទីរសេនាធិការ និង រោងចក្រអគ្គិសនី

***មីន សាណាស់***



*រោងចក្រផលិតចង្កៀងនៅក្នុងរបបកម្ពុជាប្រជាធិបតេយ្យ។ (បណ្ណសារមជ្ឈមណ្ឌលឯកសារកម្ពុជា)*

*នៅក្នុងចម្លើយសារភាពលេខJ00៨៩២ ឌុចបានសរសេររាយការណ៍ជូនថ្នាក់លើថា៖ «បងជាទីគោរព អា ឡាយ ម៉េងហុង ហៅ ហាន រាយការណ៍ថាវាជា សេ-អ៊ី-អា តែកម្លាំងដែលវារាយការណ៍គឺរាលដាលសម្បើមណាស់។ ដោយក្តីគោរព!»។ នៅឯផ្នែកចុងបញ្ចប់នៃចំណាររាយការណ៍គឺមានហត្ថលេខារបស់ឌុចផ្ទាល់បន្ទាប់ពី ឡាយ ម៉េងហុង សរសេរចម្លើយសារភាពរបស់ខ្លួនឯងចប់នៅថ្ងៃទី២២ ខែមីនា ឆ្នាំ១៩៧៧។ ខាងក្រោមនេះគឺជាចម្លើយសារភាពរបស់ ឡាយ ម៉េងហុង ហៅ ហាន សរសេរអក្សរដោយផ្ទាល់ដៃ៖*

*ខ្ញុំសូមរាយការណ៍ជូនអង្គការអំពីប្រវត្តិរបស់ខ្ញុំដូចតទៅ ឈ្មោះដើម ឡាយ ម៉េងហុង ឈ្មោះបដិវត្តន៍ ហាន អាយុ៣៩ឆ្នាំ (១៩៧៧) កើតនៅភូមិព្រៃទទឹង ឃុំជ្រៃវៀន ស្រុកព្រៃឈរ ខេត្តកំពង់ចាម។ ខ្ញុំមានឪពុកឈ្មោះ ឡាយ ស៊ុនឡេង ប្រកបរបរស៊ីឈ្នួលកាត់ដេរឱ្យថៅកែ ថាំង អ៊ឹម នៅផ្សារព្រៃទទឹង ខេត្តកំពង់ចាម ក្រោយមករកស៊ីលក់ឆ្នោតជាតិ។ ម្តាយខ្ញុំឈ្មោះ ប៊ុក ហួន ហៅ ទូច មានជំងឺពិការភ្នែកទាំងសងខាង។*

*កាលពីតូចខ្ញុំរៀននៅសាលាបឋមសិក្សាព្រៃទទឹង។ នៅឆ្នាំ១៩៥៦ ខ្ញុំបន្តការសិក្សានៅវិទ្យាល័យកំពង់ចាម។ នៅឆ្នាំ១៩៦០ ខ្ញុំប្រឡងជាប់គ្រូ និងចេញទៅធ្វើការជាគ្រូបង្រៀននៅអនុវិទ្យាល័យស៊ឹងត្រង់ ខេត្តកំពង់ចាម។ បន្ទាប់មក មិត្តខ្ញុំឈ្មោះ នូ តៃភុន ខស្យាហ៍នាំខ្ញុំមកលេងផ្ទះបង យ៉ាងជួន នៅខេត្តកំពង់ចាម។ ជាបន្តបន្ទាប់ បងយ៉ាងជួនតែងអប់រំខ្ញុំឱ្យស្រឡាញ់របបកុម្មុយនីស្ត។ ខ្ញុំ និង នូ តៃភុន បានចេញ*

ចូលសំណាក់នៅផ្ទះបងយ៉ាងជួន ញឹកញាប់ណាស់។

នៅឆ្នាំ១៩៦៤ ខ្ញុំប្រឡងជាប់ជានិស្សិតសាស្ត្រាចារ្យ ខ្ញុំខានទៅ ទាក់ទងបងយ៉ាងជួន ហើយក្រោយមក ខ្ញុំឮដំណឹងថាគាត់ត្រូវខ្មាំងវាតគ្បាត។

នៅឆ្នាំ១៩៦៦ ខ្ញុំចេញទៅបង្រៀននៅវិទ្យាល័យព្រះគន្ធបុប្ផា ស្រុកព្រៃទទឹង ខេត្តកំពង់ចាម។ នៅទីតាំងនេះ ខ្ញុំបានជួបឈ្មោះ ជាម គឹមយាន។ ជាម គឹមយាន តាមពិនិត្យខ្ញុំមួយឆ្នាំ ទើបគាត់ផ្ដើម ទាក់ទងមកខ្ញុំ និងរាប់អានមិត្តភក្ដិខ្ញុំឈ្មោះ សាយ គី ហៅ ព្រាប។

នៅថ្ងៃទី១ ខែឧសភា ឆ្នាំ១៩៦៧ ជាម គឹមយាន បាននាំខ្ញុំ និង សាយ គី ហៅ ព្រាប ទៅលេងទឹកឆា និងមានចាក់បាញ់ឆែវហូប។ នៅពេលនោះហើយដែលមិត្ត ជាម គឹមយាន ចាប់ផ្ដើមអប់រំបំពាក់បំប៉ននយោបាយលោកសេរីឱ្យខ្ញុំ និងមិត្តសាយ គី ហៅ ព្រាប។ ដោយ ជាម គឹមយាន ចាប់ផ្ដើមនិយាយថា ថ្ងៃនេះជាថ្ងៃបុណ្យអន្តរជាតិ ជាថ្ងៃបុណ្យបក្សកុម្មុយនីស្ត ខ្ញុំយកថ្ងៃនេះមកជួបមិត្ត ព្រោះម្យ៉ាងចង់បន្ទំជនចម្រើនថា យើងជាជនចម្រើនដែរ ហើយម្យ៉ាងទៀត យើងអាចរស់នៅបន្តប់ក្នុងជួរបដិវត្តន៍បានយូរអង្វែង តែខ្លឹមសារគឺយើងធ្វើការឱ្យអាមេរិកាំង។ យើងជាសាស្ត្រាចារ្យមានប្រាក់ខែ៧ប្ុ៨ពាន់ ទៅធ្វើកុម្មុយនីស្តមានប្រយោជន៍អី? វាបានតែជាប់គុកហ្នឹង។ ការអប់រំនយោបាយក្បត់បែបនេះដល់ខ្ញុំនិងមិត្តសាយ គី ហៅ ព្រាប តែងមានជាហូរហែ។ ចុងបញ្ចប់ខ្ញុំ និងមិត្តសាយ គី ក៏យល់ព្រមតាម ជាម គឹមយាន។ ក្រោយមក ជាម គឹមយាន បានហៅខ្ញុំនិងមិត្តសាយ គី ហៅ ព្រាប ទៅជួបជុំគ្នានៅវិទ្យាល័យគន្ធបុប្ផា។ នៅពេលនោះ គឺជាថ្ងៃអាទិត្យ។ ពេលទៅដល់ខ្ញុំបានឃើញមិត្ត យាង ស៊ីមធន់ ជានាយកវិទ្យាល័យពាមជីកង, មិត្តយ៉ង់ស៊ីម មានតួនាទីជានាយកវិទ្យាល័យស្ទឹងត្រង់ និង ហែម ប៊ុណ្ណា ជាសាស្ត្រាចារ្យ។ បន្ទាប់ពីជុំគ្នាអស់ ជាម គឹមយាន ក៏ចាប់ផ្ដើមពិធីបញ្ចូលជា សេ-អ៊ី-អា ចំពោះសមាជិកថ្មីចំនួនបីនាក់គឺ រូបខ្ញុំ ឡាយ ម៉េងហុង ហៅ ហាន, សាយ គី ហៅ ព្រាប និង យាង ស៊ីមធន់ ហៅ សេក។ ក្នុងពិធីនោះមាន ជាម គឹមយាន ជាអ្នកនាំចូល។ ហែម ប៊ុណ្ណា ជាអ្នកឧទ្ទេសនាម និង យ៉ង់ ស៊ីម ជាអ្នកទទួលស្គាល់។ ក្រុមខ្ញុំទាំងបីនាក់បានគោរពទង់សេរីភាពអាមេរិកាំង និងការប្ដេជ្ញាចិត្តម្នាក់ម្ដងៗ ថានឹងស្មោះត្រង់ចំពោះអាមេរិកាំងជារៀងរហូត និងចូលបង្កប់ក្នុងជួរបដិវត្តន៍ឱ្យជ្រៅ។ ចុងបញ្ចប់គឺមានការហូបនំផឹកតែ ទឹកក្រូចបន្តិចបន្តួច មុននឹងបែកគ្នា។

នៅឆ្នាំ១៩៦៨ ដោយសារមានសិស្សវិទ្យាល័យគន្ធបុប្ផានាំគ្នាឡើងធ្វើបាតុកម្មញឹកញាប់ ប្រឆាំងនឹងរបបសង្គមរាស្ត្រនិយម ខ្ញុំក៏សហការជាមួយកម្លាំង សេ-អ៊ី-អា មួយចំនួនទៀត ដើម្បីខ្ទប់ក្បួនបាតុកម្ម ដែលដឹកនាំដោយឈ្មោះ ប្រាក់ មីន។ ខ្ញុំ និងសាយ គី ហៅ ព្រាបបានរាយការណ៍ទៅស័ក្តិ៩ ឈ្មោះ សេង ដែលនៅប្រចាំសាលាស្រុកព្រៃទទឹង ឱ្យមកចាប់ ប្រាក់ មីនយកទៅឃុំខ្លួន។ បន្ទាប់មកទៀត ខ្ញុំបានបង្កប់ខ្លួនក្នុងចំណោមកូនសិស្ស និងសាស្ត្រាចារ្យដែលបង្កសកម្មភាពដុត ឡានចៅកែ ផន់ ហាក់ ដើម្បីស្វែងរកអ្នកបង្កហេតុឱ្យចលាចល ដើម្បីប្ដឹងទៅថ្នាក់លើឱ្យចាប់ខ្លួនជាបន្តទៀត។

នៅឆ្នាំ១៩៦៩ ខ្ញុំបានឡើងមកធ្វើជាគណៈមេប្រយោគនៅ ទីក្រុងភ្នំពេញ និងបានជួបជាមួយ យ៉ង់ ស៊ីម។ យ៉ង់ ស៊ីម បានប្រាប់ខ្ញុំថា ខ្សែ សេ-អ៊ី-អា ខាងគាត់បានប្រឆាំងនឹងសិស្សក្រហម ដែលមានបំណងហែក្បួនបាតុកម្មប្រឆាំងនឹងរបបសីហនុ (សង្គមរាស្ត្រនិយម) និង លន់ នល់។ ចុងឆ្នាំ១៩៦៩ ខ្ញុំបានឃោសនាអប់រំសាស្ត្រាចារ្យភាសាអង់គ្លេសឈ្មោះ ហេង អេងលី និងបញ្ចូលជា សេ-អ៊ី-អា។

នៅថ្ងៃទី១៨ ខែមីនា ឆ្នាំ១៩៧០ ទីក្រុងភ្នំពេញក៏មានផ្ទុះរដ្ឋប្រហារដឹកនាំដោយលោក លន់ នល់ ផ្ដួលរំលំរបបសីហនុចេញពីតំណែង។ បន្ទាប់មកទៀត នៅថ្ងៃទី២៥ ខែមីនា ឆ្នាំ១៩៧០បាតុកម្មប្រជាជនក៏ផ្ទុះឡើងគគ្រឹកគគ្រេងពេញក្រុងកំពង់ចាម។ ភ្លាមៗនោះ កម្លាំង សេ-អ៊ី-អា ក៏បើកការប្រជុំរកវិធានការរំសាយក្រុមបាតុកម្ម ដោយឆក់ឱកាសដឹកនាំក្បួនបាតុកម្មឱ្យបែកខ្ញែកគ្នា ឈានទៅរំសាយបន្តិចម្ដងៗ រួចរំសាយបានទាំងស្រុង ស្របពេលទាហាន លន់ នល់ ដើរចាក់បំបែកកង ឡានអស់ថែមទៀតបាតុកម្មក៏រំសាយអស់គ្មានសល់។ ចប់បាតុកម្ម ស្រាប់តែក្ដួយរបស់ អ៊ុនតាំ ឈ្មោះ ម៉ម ចន្ទនា ទៅប្ដឹងចៅហ្វាយខេត្ត អ៊ុនតាំ



*រោងចក្រផលិតក្បាលបូមទឹកនៅក្នុងរបបកម្ពុជាប្រជាធិបតេយ្យ។ (បណ្ណសារមជ្ឈមណ្ឌលឯកសារកម្ពុជា)*

ថាឈ្មោះខ្ញុំ, សាយ គឹហៅ ព្រាប, ម៉ក់ ប៉ិច, សាត់ ថាំង និង ទៀវ អឿន ជាអ្នកដឹកនាំធ្វើបាតុកម្មប្រឆាំងរដ្ឋអំណាច លន់ នល់ ទៅវិញ។ អ៊ិន តាំ ពុំដឹងថាក្រុមខ្ញុំជាកម្លាំង សេ-អ៊ី-អា ក៏ឱ្យទាហានចំនួន៤ ឡានមកចាប់ក្រុមខ្ញុំយកទៅដាក់គុកអស់រយៈពេល១ខែកន្លះ រួចបន្តយកទៅឃុំនៅបន្ទាយ ទន្លេអុំរយៈពេល៤ខែបន្ថែមទៀត។ ក្រោយពី អ៊ិន តាំ ដឹងថាក្រុមខ្ញុំជាភ្នាក់ងារ សេ-អ៊ី-អា អ៊ិន តាំ បានបញ្ជូនខ្ញុំ, ទៀវ អឿន និង សាយ គឹ ហៅ ព្រាប មកបង្កប់ខ្លួននៅជួរបដិវត្តន៍ក្រុងភ្នំពេញ។ ចំណែកឈ្មោះ ម៉ក់ ប៉ិច ហៅ ភាព និង សាត់ ថាំង ឱ្យបង្កប់នៅក្រុងកំពង់ចាមដដែល។

នៅឆ្នាំ១៩៧១ ខ្ញុំ និង សាយ គឹ ហៅ ព្រាប បានឡើងមកដល់ក្រុងភ្នំពេញ និងដើរស្រាវជ្រាវរកខ្មែរបដិវត្តន៍ដើម្បីចូលបង្កប់ខ្លួន។ ដំបូងខ្ញុំទៅជួបជាមួយ ហុក តាំងអ៊ាង និងបងមីនី ដែលជាខ្មែរ សេ-អ៊ី-អា របស់ យាង ស៊ីមធន់ ហៅ សេក នៅចាក់អង្រែ។ ប៉ុន្តែ ហុក តាំងអ៊ាង បាននិយាយប្រាប់ខ្ញុំថា យាង ស៊ីមធន់ ដែលនៅកាន់កាំភ្លើងការពារនៅសាលាស្រុកពាមជីកងក្នុងឆ្នាំ១៩៧០ ឥឡូវបានបាត់ខ្លួនពុំឮដំណឹងអ្វីសោះ។ តាមរយៈ ហុក តាំងអ៊ាង ខ្ញុំបានចូលទៅក្នុងខ្មែរបដិវត្តន៍ដែលមានឈ្មោះ ចាន់ ជាអ្នកដឹកនាំ។ ខ្ញុំនិង សាយ គឹ ហៅ ព្រាបបានទទួលការណែនាំពីចាន់អំពីការកសាងកម្លាំង និងរៀនឯកសារការងារប្រាំជំហានជាបន្តបន្ទាប់។

នៅថ្ងៃទី១១ ខែកុម្ភៈ ឆ្នាំ១៩៧៣ ចាន់ បានធ្វើពិធីបញ្ចូលខ្ញុំជាកម្មាភិបាលរណសិរ្សនៅវិទ្យាល័យទួលទំពូង។ ចាន់ តែងតែចុះមកជួបផ្ទាល់ជាមួយខ្ញុំនិង សាយ គឹ ហៅ ព្រាប ដើម្បីធ្វើការណែនាំ និងជំរុញកូដកម្មតាមសាលាជាមីទិញ ឬជាបាតុកម្មហែតាមផ្លូវ។ នៅថ្ងៃទី១៧ ខែមីនា ឆ្នាំ១៩៧៣ខ្មែរសេ-អ៊ី-អាបានចូលរួមមីទិញគ្រូនៅមហាវិទ្យាល័យគរុកោសល្យ។ ប៉ុន្តែមីទិញនេះត្រូវទាហាន លន់ នល់ បំបែកបាន។ បន្ទមកទៀតឈ្មោះ ព្រំសំអា ហៅជឹមជាសាស្ត្រាចារ្យបានចាត់តាំងខ្ញុំឱ្យប្រមូលកម្លាំង សេ-អ៊ី-អា ទាំងអស់មកប្រជុំរៀបចំខ្មែរសង្កាក់ទាក់ទងសារជាថ្មី។ រីឯជឹមក៏រត់ទៅបង្កប់ខ្លួននៅតំបន់រំដោះ។ ហេតុនេះខ្ញុំត្រូវភ្ជាប់ខ្សែទំនាក់ទំនងទៅឈ្មោះ យី យ៉ុន។ នៅចុងឆ្នាំ១៩៧៣ មិត្ត សាយ គឹ ហៅ ព្រាប បាននាំមិត្ត សុខមកឱ្យទទួលស្គាល់ខ្ញុំ ដោយឱ្យប្រាប់ថា សុខ គឺដូចយើង។ ក្រោយមកទៀតសភាពការណ៍កាន់តែស្រួច

សមាជិកក្នុងក្រុមក៏រកជួលផ្ទះមួយ សម្រាប់លាក់សុខ។ សុខ ធ្វើបែបនេះដើម្បីបន្លំធ្វើជាកម្មាភិបាលបដិវត្តន៍លាក់ខ្លួន ដឹកនាំចលនាតស៊ូក្នុងក្រុង។

នៅខែមិថុនា ឆ្នាំ១៩៧៤ កុប្បកម្មសម្លាប់ថាច់ជា និង កែវ សង់គីម បានផ្ទុះឡើងនៅវិទ្យាល័យយុគន្ធរ។ ខ្ញុំ, សាយ គី ហៅ ព្រាប និង យាង ស៊ីមចាន់ ហៅ សេន បានយកព្រឹត្តិការណ៍នេះទៅរាយការណ៍ឱ្យមិត្តសុខ។ មិត្តសុខ មានមតិថា តែប៉ុណ្ណេះបក្សទុកចិត្តយើងហើយ។ ថ្ងៃណាមួយយើងនាំគ្នាទៅជួបអង្គការនៅតំបន់រំដោះ។ ដល់ថ្ងៃទី២៥ ខែកញ្ញា ឆ្នាំ១៩៧៤ មិត្តសុខ បាននាំខ្ញុំ និងគ្នីគ្នាមួយចំនួនទៀតទៅតំបន់រំដោះ ដើម្បីបន្តទៅរៀននៅមន្ទីរអង្គការ ដែលមានបងខៀវ ជាអ្នកខទ្ទេសនាមឯកសារ។ រៀនបានកន្លះខែយើងនាំគ្នាវិលត្រឡប់ចូលមកក្នុងក្រុងវិញនៅថ្ងៃទី៣១ ខែតុលា ឆ្នាំ១៩៧៤។

នៅខែមករា ឆ្នាំ១៩៧៥ ចលនាវាយសម្រុករបស់កងទ័ពបដិវត្តន៍មានសន្ទុះកាន់តែខ្លាំងក្លាឡើង។ មិត្តសុខ បាននិយាយប្រាប់ខ្ញុំថា បដិវត្តន៍ប្រាកដជារំដោះទីក្រុងភ្នំពេញបានជោគជ័យ។ យើងត្រូវរៀបចំសម្របសម្រួលខ្លួនជាមួយបដិវត្តន៍ឱ្យកាន់តែជ្រៅ។ ថ្ងៃទី១៤ ខែមេសា ឆ្នាំ១៩៧៥ មិត្តសុខបានឱ្យក្រុមខ្ញុំធ្វើត្រាក់បោះអំពាវនាវឱ្យទាហាន លន់ នល់ ដាក់អាវុធចុះ និងណែនាំឱ្យទៅផ្ដុំគ្នានៅមហាវិទ្យាល័យអក្សរសាស្ត្រ និងមនុស្សសាស្ត្រ ដើម្បីចាំទទួលកងទ័ពបដិវត្តន៍។ ថ្ងៃទី១៧ ខែមេសា ឆ្នាំ១៩៧៥ ខ្ញុំ និងគ្រួសារត្រូវជម្លៀសទៅមន្ទីរ៩០។ នៅខែកក្កដា ឆ្នាំ១៩៧៥ មិត្តសុខបើកវគ្គនៅមន្ទីរ១០០ និងចាត់តាំងឱ្យ ព្រាប ចុះទៅប្រមូលខ្សែ សេ-អ៊ី-អា តាមជនបទ។ ព្រាប បានចុះទៅតំបន់២៥ និងប្រមូលបានឈ្មោះ មិត្តប៉ាវ, មិត្តគុង។ បន្ទាប់មក ព្រាប ចុះទៅតំបន់៤១ ប្រមូលបាន មិត្តអន, មិត្តសាស្ត្រាចារ្យភាសាអង់គ្លេស និង ចុះទៅតាមតំបន់ជាច្រើនទៀត។

នៅឆ្នាំ១៩៧៦ ខ្ញុំទទួលបញ្ជាពីមិត្តរិន្ទ ឱ្យទៅសាកល្បងអូសទាញមិត្តស៊ិ។ ចំណែក មិត្តឡឿន ត្រូវទៅសាកល្បងអូសទាញមិត្តលី។ មិត្តស៊ិ មាននមនោសញ្ចេតនាមកលើខ្ញុំ។ ក្រោយមកខ្ញុំទៅរៀននៅតាខ្មៅ។ ពេលខ្ញុំត្រឡប់មកវិញ អង្គការផ្លាស់មិត្តស៊ិចេញបាត់។ បន្ទាប់ពីនោះ មិត្តរិន្ទបានហៅប្រជុំសរុបឯកសារអគ្គិសនីទី២ ស្ថិតនៅទីតាំងផ្ទះទល់មុខមន្ទីរពេទ្យ៧០៣ ដោយបើកចំហថា យើងគិតផ្ដើមបង្កទំនាស់ម្ដង គិតចាប់ផ្ដើមវាយឥទ្ធិពលបងហ៊ិ។ មិត្តរិន្ទ បាននិយាយបន្តថា ពេលធ្វើឱ្យបងហ៊ិឱ្យឯកោហើយ ចាំឈានទៅដល់ បងឌុច ធ្វើឱ្យឯកោម្នាក់ទៀត។ ក្រោយមក ពេលមកនៅសាលាទួលស្វាយព្រៃ មិត្តរិន្ទ បានចាត់តាំងខ្ញុំឱ្យមកនៅជាមួយបងចាន់ដើម្បីស៊ើបសួរថា តើបងចាន់មានគំនិតអ្វីចំពោះមិត្តរិន្ទ? ម្យ៉ាងទៀតដើម្បីចង់ក្ដាប់ឯកសារក្រុមសេ-អ៊ី-អា ឱ្យបានគ្រប់ផ្នែក។ ដោយសារការណែនាំរបស់មិត្តរិន្ទឱ្យធ្វើសកម្មភាពបំផុសបំផុល បង្កទំនាស់កាន់តែខ្លាំង អង្គការក៏ដកមិត្តរិន្ទ និង មិត្តសែង ចេញ។ ក្រោយមកទៀត អង្គការចាត់តាំងខ្ញុំឱ្យធ្វើជាប្រធានពួក ខ្ញុំក៏បន្តអប់រំសមាជិកឱ្យភ្លើតភ្លើន និងសេរីក្នុងការធ្វើការប្រចាំថ្ងៃ ដូចជាការបេះបោច ហូបតាមចិត្ត។

នៅថ្ងៃទី២៨ ខែកុម្ភៈ ឆ្នាំ១៩៧៧ អង្គការយកប្រពន្ធខ្ញុំមក។ ប្រពន្ធខ្ញុំបាននិយាយថា បងតៅ គ្រួសារមិត្តឡឿនមកតាំងពីម្សិលមិញ ម្ដេចមិនឃើញ? ខ្ញុំឈប់ស្រពិចស្រពិល ហើយសន្មតថា មិត្តឡឿនអង្គការចាប់បាត់ហើយ។ នៅថ្ងៃទី១៤ ខែមីនា ឆ្នាំ១៩៧៧ បងចាន់បានមកប្រាប់ខ្ញុំឱ្យទៅស្រែ។ ខ្ញុំវិភាគផ្អៀងខាងទៅស្រែ ព្រោះសម្អាងថា ចម្លើយមិត្តឡឿនតែម្នាក់អង្គការពុំទាន់យកជាការទេ។ ខ្ញុំចូលដល់ក្នុងឡាន ស្រាប់តែអង្គការចាប់ខ្ញុំ។

***កំណត់ចំណាំ៖ អត្ថបទនេះដកស្រង់ចេញពីឯកសារចម្លើយសារភាពលេខ J00៤៩២ រាល់ចម្លើយសារភាពរបស់អ្នកទោសទាំងអស់នៅមន្ទីរសន្តិសុខស-២១ សុទ្ធតែឆ្លងកាត់ការបង្ខិតបង្ខំ និងធ្វើទារុណកម្មយ៉ាងធ្ងន់ធ្ងរពីកងសួរចម្លើយរបស់ខ្មែរក្រហម។ ដូច្នេះយើងមិនអាចសន្និដ្ឋានបានថាចម្លើយសារភាពរបស់ ឡាយ ម៉េងហុង ហៅ ហាន ពិតប្រាកដបុយ៉ាងណានោះទេ។***

# ខ្ញុំសូមអំពាវនាវផ្តល់យុត្តិធម៌ដល់ខ្ញុំ និងប្រពន្ធដែលរងរបួសបាក់ភ្លៅដោយគ្រាប់កាំភ្លើងធំរបស់ទាហានថៃ

**កែវ សុភី**



*សួយ រិញ អាយុ៦៥ឆ្នាំ រស់នៅក្នុងភូមិសុភី ឃុំសុភី ស្រុកអូរជ្រៅ ខេត្តបន្ទាយមានជ័យ រងរបួសបាក់ភ្លៅដោយសារគ្រាប់ផ្លោង និងការទម្លាក់បែកពីកងទ័ពថៃ។*
*(បណ្ណសារមជ្ឈមណ្ឌលឯកសារកម្ពុជា)*

ខ្ញុំឈ្មោះ សួយ រិញ អាយុ៦៥ឆ្នាំ បច្ចុប្បន្នរស់នៅក្នុងភូមិសុភី ឃុំសុភី ស្រុកអូរជ្រៅ ខេត្តបន្ទាយ-មានជ័យ។ ខ្ញុំមានឪពុកឈ្មោះ ទេន សួយ និងម្តាយឈ្មោះ ខន ខឿន។ បច្ចុប្បន្នឪពុកម្តាយខ្ញុំស្លាប់អស់ហើយ។ ខ្ញុំមានបងប្អូនចំនួន៦នាក់ គឺប្រុស២នាក់ និងស្រី៤នាក់ ហើយខ្ញុំគឺជាកូនទី៤នៅក្នុងគ្រួសារ។ ខ្ញុំមានប្រពន្ធឈ្មោះ លិញ សាវិល អាយុ៥៥ឆ្នាំ មានស្រុកកំណើតនៅភូមិសុភី ឃុំសុភី ស្រុកអូរជ្រៅ ខេត្តបន្ទាយមានជ័យដូចខ្ញុំដែរ។ ក្រោយពីរៀបការយើងមានកូនចំនួន៦នាក់។ ខ្ញុំមិនមានមុខរបរពិតប្រាកដទេ សព្វថ្ងៃខ្ញុំនិងប្រពន្ធរបស់ខ្ញុំនៅចាំដីចម្ការឱ្យប្រជាជនក្នុងភូមិសុភី។

កាលពីក្មេង ខ្ញុំមិនបានចូលរៀនទេ។ នៅក្នុងរបបខ្មែរក្រហម ខ្ញុំត្រូវបានចាត់តាំងឱ្យធ្វើការងារ

ពលកម្ម ដូចជា លើកទំនប់ ជីកប្រឡាយ និងវែកដីយ៉ាងលំបាកវេទនា។ នៅក្នុងឆ្នាំ១៩៧៨ ខ្មែរក្រហមបានជ្រើសរើសខ្ញុំឱ្យចូលកងទ័ពប្រចាំនៅភូមិភាគពាយ័ព្យ។ អង្គភាពរបស់ខ្ញុំប្រចាំការនៅអាងកន្សែងក្នុងឃុំសីង្ហ ដើម្បីការពារព្រំដែនកម្ពុជា-ថៃ ក្នុងភូមិសាស្ត្រស្រុកអូរជ្រៅ។ ខ្ញុំបានដើរល្បាត និងយាមកាមតាមបណ្ដោយព្រំដែនខ្មែរ-ថៃ ជាពិសេសនៅភូមិព្រាវ និងភូមិយាង។ មេបញ្ជាការខ្មែរក្រហមប្រចាំនៅស្រុកអូរជ្រៅមានឈ្មោះ ឈិត ចំណែកប្រធានភូមិភាគពាយ័ព្យមានឈ្មោះ តាម៉ុក (ឡើងគ្រប់គ្រងជំនួសប្រធានភូមិភាគពាយ័ព្យចាស់)។

នៅឆ្នាំ១៩៧៩ ខ្មែរក្រហមបានបញ្ជូនអង្គភាពខ្ញុំទៅវាយជាមួយកងទ័ពវៀតណាម នៅស្វាយ-ស៊ីសុផុន។ កងទ័ពខ្មែរក្រហមបានបរាជ័យ រួចហើយដកខ្លួនរត់ចូលព្រៃ និងបែកខ្ញែកគ្នាអស់។ បន្ទាប់មកខ្ញុំត្រឡប់មករស់នៅជាមួយឪពុកម្ដាយនៅភូមិកំណើតនៅក្នុងភូមិសុភី ឃុំសុភី ស្រុកអូរជ្រៅ ខេត្តបន្ទាយ-មានជ័យវិញ។ នៅក្នុងឆ្នាំ១៩៧៩ ដដែល ខ្ញុំបានរៀបការប្រពន្ធទីមួយមានឈ្មោះ ងឹម និងផ្លាស់ទៅរស់នៅភូមិកូនត្រី ឃុំកូប ស្រុកអូរជ្រៅ ខេត្តបន្ទាយ-មានជ័យ ដោយប្រកបមុខរបរធ្វើស្រែចម្ការ។

នៅពាក់កណ្ដាលឆ្នាំ១៩៨២ ខ្ញុំ និងគ្រួសារបានធ្វើដំណើរទៅរស់នៅក្នុងជំរំណងចាន់។ បន្ទាប់មកខ្ញុំបានចូលធ្វើទាហានប៉ារ៉ាប្រចាំនៅជំរំណងចាន់ ដោយមានលោក ប៊ិន ភារម្យ គឺជាមេបញ្ជាការកងវរសេនាតូច។ នៅអំឡុងពេលនោះប្រពន្ធ និងកូនៗរបស់ខ្ញុំបានស្នាក់នៅជំរំណងចាន់ជាមួយខ្ញុំដែរ។

នៅចុងឆ្នាំ១៩៨៤ កងទ័ពវៀតណាម និងកងទ័ពនៃរបបសាធារណរដ្ឋប្រជាមានិតកម្ពុជាវាយចូលជំរំណងចាន់។ ប្រពន្ធកូនខ្ញុំ ត្រូវបានអង្គការយូអ៊ិនប្រូដឹកទៅរស់នៅជំរំសាយធូ ដែលមានទីតាំងស្ថិតនៅក្នុងប្រទេសថៃ។ ចំណែកខ្ញុំបានបន្តឈរជើងនៅជំរំណងចាន់ ដើម្បីវាយតទល់ជាមួយកងទ័ពវៀតណាម។ ខ្ញុំបានឈរជើងនៅជំរំណងចាន់រហូតដល់ឆ្នាំ១៩៩២ និងពេលដែលអ៊ុនតាក់ចូលមករៀបចំបោះឆ្នោតនៅក្នុងឆ្នាំ១៩៩៣។ បន្ទាប់ពីបោះឆ្នោតសកលលើកទី១ នៅឆ្នាំ១៩៩៣ ខ្ញុំបានចូលធ្វើទាហានក្នុងកងពលលេខ១២ ប្រចាំនៅនិមិត្តមួយរយៈខ្លី ទើបលាឈប់ពីទាហាន។ ខ្ញុំបានដើរស៊ីឈ្នួលអារឈើពីខេត្តមួយទៅខេត្តទៀតរហូតដល់ឆ្នាំ២០១០ ទើបត្រឡប់មករស់នៅភូមិសុភី និងរៀបការជាមួយប្រពន្ធក្រោយឈ្មោះ លិញ សារិល។ បន្ទាប់ពីរៀបការរួច ខ្ញុំ និងប្រពន្ធមិនមានមុខរបរអ្វីពិតប្រាកដឡើយ គឺយើងដើរស៊ីឈ្នួលចាំចម្ការឱ្យអ្នកភូមិសុភី ឃុំសុភី ស្រុកអូរជ្រៅ ខេត្តបន្ទាយមានជ័យ។

អំឡុងផ្ទុះអាវុធលើកទី១ ពីថ្ងៃទី២៤ ដល់ ២៨ ខែកក្កដា ឆ្នាំ២០២៥ ខ្ញុំ និងប្រពន្ធបានស្នាក់នៅក្នុងចម្ការស្វាយចន្ទីរបស់អ្នកភូមិធម្មតា។ ប្ដីប្រពន្ធខ្ញុំមិនបានរត់ទៅណាទេ។ ខ្ញុំរស់នៅចម្ការរហូតដល់ផ្ទុះអាវុធលើកទី២ ពីថ្ងៃទី៨ ដល់ ថ្ងៃទី២៧ ខែធ្នូ ឆ្នាំ២០២៥ ដែលមានទ្រង់ទ្រាយធំ។ នៅវេលាម៉ោង៨:៣០នាទីព្រឹកព្រលឹម ថ្ងៃទី២២ ខែធ្នូ ឆ្នាំ២០២៥ ពេលខ្ញុំភ្ញាក់ពីដេក ខ្ញុំទាញវិទ្យុមកបើកស្ដាប់ព័ត៌មាន និងអង្គុយជក់បារី ស្រាប់តែគ្រាប់ផ្លោងរបស់ទាហានថៃបានធ្លាក់នៅក្បែរគ្រែប្ដីប្រពន្ធខ្ញុំ ហើយអំបែងគ្រាប់បានហោះមកត្រូវត្រង់ភ្លៅខាងឆ្វេងរបស់ខ្ញុំ។ ចំណែកប្រពន្ធខ្ញុំក៏ត្រូវអំបែងគ្រាប់ត្រង់ភ្លៅខាងស្ដាំបណ្ដាលឱ្យបាក់ឆ្អឹងដែរ។ ខ្ញុំនិងប្រពន្ធត្រូវអំបែងគ្រាប់ក្នុងពេលតែមួយ។ បន្ទាប់ពីត្រូវរបួស ខ្ញុំបានលូនចេញពីគ្រែសំដៅមកផ្លូវដើម្បីរកមនុស្សឱ្យជួយ។ នៅខណៈពេលខ្ញុំលូនមកដល់ផ្លូវក៏បានជួបអ្នកភូមិម្នាក់ ហើយបានផ្ដាំគាត់ឱ្យជួយប្រាប់ឪពុកមាខ្ញុំថា «ខ្ញុំត្រូវគ្រាប់ហើយ»។

នៅវេលាម៉ោងប្រហែល៧:៣០ព្រឹក ថ្ងៃទី២២ ខែធ្នូឆ្នាំ២០២៥ដដែល ទើបមានឡានសង្គ្រោះបន្ទាន់មកជួយដឹកខ្ញុំនិងប្រពន្ធទៅមន្ទីរពេទ្យ។ ប្រពន្ធខ្ញុំ

ត្រូវគ្រាប់ផ្លោងទាហានថៃបាក់ភ្លៅដូចខ្ញុំដែរ ប៉ុន្តែស្ថានភាពរបស់គាត់ធ្ងន់ជាងខ្ញុំ។ ខ្ញុំខំប្រឹងលូនរហូតមកដល់ផ្លូវ ប៉ុន្តែប្រពន្ធខ្ញុំមិនអាចលូនបានទេ។ នៅខណៈពេលឡានពេទ្យបញ្ជូនខ្ញុំមកដល់មន្ទីរពេទ្យស្រុកអូរជ្រៅ គ្រូពេទ្យបានចាក់ថ្នាំ និងរុំរបួសរួចក៏បញ្ជូនប្តីប្រពន្ធខ្ញុំ ទៅមន្ទីរពេទ្យមង្គលបុរី ដើម្បីវះកាត់ដាក់ដែកក្នុងឆ្អឹងភ្លៅ។

នៅថ្ងៃទី១៩ ខែមករា ឆ្នាំ ២០២៦ ស្ថានភាពជំងឺរបស់ខ្ញុំបានប្រសើរច្រើន ខ្ញុំបានសុំអនុញ្ញាតពីគ្រូពេទ្យដើម្បីត្រឡប់មកសម្រាកនៅផ្ទះវិញ។ ចំណែកស្ថានភាពរបស់ប្រពន្ធខ្ញុំ គ្រូពេទ្យមិនទាន់ឱ្យវិលត្រឡប់មកផ្ទះវិញទេ។ នៅថ្ងៃទី២៨ ខែកុម្ភៈ ឆ្នាំ ២០២៦ គ្រូពេទ្យបានណាត់ខ្ញុំឱ្យទៅថតដើម្បីពិនិត្យ និងដោះដែកចេញ។

បច្ចុប្បន្ន ខ្ញុំនិងប្រពន្ធបានបាត់បង់កម្លាំងធ្វើការ និងរកស៊ី ធ្វើឱ្យយើងទាំងពីរនាក់ជួបការលំបាកយ៉ាងខ្លាំងផ្នែកជីវភាព។ ខ្ញុំសំណូមពរដល់អង្គការក្រៅរដ្ឋាភិបាល និងរាជរដ្ឋាភិបាលកម្ពុជា សូមមេត្តាជួយឧបត្ថម្ភខ្ញុំបាទ ដូចជាស្បៀង និងរបស់របរហូបចុកមួយចំនួនក្នុងគ្រាដ៏លំបាកនេះ។



រោងចាំចម្ការរបស់ សួយ រិញ ផ្ទះធ្លាយដោយសារគ្រាប់ផ្លោង និងការទម្លាក់បែកពីកងទ័ពថៃ។
(បណ្ណសារមជ្ឈមណ្ឌលឯកសារកម្ពុជា)

ជាចុងក្រោយ ខ្ញុំចង់ឱ្យប្រទេសជាតិត្រឡប់មកមានសន្តិភាព និងសុំជួយរកយុត្តិធម៌ដល់រូបខ្ញុំ និងប្រពន្ធដែលជាប្រជាជនស្លូតត្រង់ ដែលត្រូវរងរបួសធ្ងន់ដោយសារគ្រាប់កាំភ្លើងធំរបស់ទាហានថៃផ្លោងមកលើប្រជាជនក្នុងទឹកដីកម្ពុជា។



រោងចាំចម្ការរបស់ សួយ រិញ ផ្ទះធ្លាយដោយសារគ្រាប់ផ្លោង និងការទម្លាក់បែកពីកងទ័ពថៃ។
(បណ្ណសារមជ្ឈមណ្ឌលឯកសារកម្ពុជា)

# គីម លីម ៖ កងនារីចល័តតំបន់៣១

**ធ្យុង ជានី**

ខ្ញុំឈ្មោះ គីម លីម អាយុ៦៤ឆ្នាំ កើតនៅក្នុងភូមិអន្គ ឃុំពពេល ស្រុកបរិបូណ៌ ខេត្តកំពង់ឆ្នាំង។ បច្ចុប្បន្ន ខ្ញុំរស់នៅក្នុងភូមិក្រាំងរងៀង ឃុំអន្ទង់រាប ស្រុកវាលវែង ខេត្តពោធិ៍សាត់ និងប្រកបមុខរបរធ្វើចម្ការ។ ខ្ញុំមានឪពុកឈ្មោះ គីម ញឹម ស្លាប់ក្នុងឆ្នាំ១៩៧៦ ដោយសារធ្វើការងារហួសកម្លាំង និងម្ដាយឈ្មោះ ឃឹម លន ស្លាប់ក្នុងឆ្នាំ២០២០ ដោយសារជំងឺចាស់ជរា។ ខ្ញុំមានបងប្អូនបង្កើតចំនួន៤នាក់ គឺស្រី២នាក់ និងប្រុស២នាក់ ហើយខ្ញុំគឺជាកូនទី៣នៅក្នុងគ្រួសារ។ ខ្ញុំមានប្ដីឈ្មោះ អ៊ិន ផុន អាយុ៧៥ឆ្នាំ។ ក្រោយពេលរៀបការយើងមានកូនចំនួន៤នាក់ គឺកូនស្រីម្នាក់ និងប្រុស៣នាក់។

កាលនៅវ័យកុមារ ខ្ញុំចូលរៀននៅសាលាបឋមសិក្សាអន្គ ស្ថិតក្នុងភូមិអន្គ បានរយៈពេល២ឆ្នាំ។ នៅថ្ងៃទី១៨ ខែមីនា ឆ្នាំ១៩៧០ សេនាប្រមុខ លន់ នល់ បានធ្វើរដ្ឋប្រហារទម្លាក់សម្ដេចព្រះ នរោត្តម សីហនុ ចេញពីតំណែង ទើបខ្ញុំឈប់រៀន ហើយមកជួយឃ្វាលគោក្របីឪពុកម្ដាយនៅផ្ទះ។

នៅឆ្នាំ១៩៧១ ខ្ញុំឃើញយន្តហោះមកទម្លាក់គ្រាប់បែកបេ-៥២នៅភ្នំគុក និងនៅវត្តប្រាំងត្រពាំង ដែលស្ថិតនៅក្នុងឃុំពពេល ប៉ុន្តែមិនបានមកទម្លាក់គ្រាប់នៅក្នុងភូមិខ្ញុំទេ។ យន្តហោះមកទម្លាក់គ្រាប់បែកនៅជិតភូមិខ្ញុំទាំងយប់ទាំងថ្ងៃ ដូច្នេះខ្ញុំនិងក្រុមគ្រួសារនាំគ្នាចូលសម្ងំលាក់ខ្លួនក្នុងលេណដ្ឋានរហូតដល់សភាពការណ៍ស្ងប់ស្ងាត់ទើបហ៊ានចេញមកខាងក្រៅវិញ។

នៅឆ្នាំ១៩៧៤ ខ្ញុំផ្លាស់មករស់នៅជាមួយជីដូននៅក្នុងឃុំពេជចង្វារ។ បន្ទាប់មក ខ្ញុំបានដឹងដំណឹងថាឪពុករបស់ខ្ញុំត្រូវបានទាហាន លន់ នល់ ចាប់ខ្លួនយក



គីម លីម អាយុ៦៤ឆ្នាំ សព្វថ្ងៃរស់នៅក្នុងភូមិក្រាំងរងៀង ឃុំអន្ទង់រាប ស្រុកវាលវែង ខេត្តពោធិ៍សាត់។
(បណ្ណសារមជ្ឈមណ្ឌលឯកសារកម្ពុជា)

ទៅដាក់នៅបន្ទាយក្នុងទីរួមខេត្តកំពង់ឆ្នាំង ព្រោះគាត់ត្រូវចោទប្រកាន់ថាបានចូលដៃជើងជាមួយកងទ័ពរំដោះខ្មែរក្រហម។ ប៉ុន្តែក្រោយមក ទាហាន លន់ នល់ បានដោះលែងឪពុករបស់ខ្ញុំវិញ។ នៅចុងឆ្នាំ១៩៧៤ ម្ដាយ និងបងប្អូនរបស់ខ្ញុំ រួមទាំងប្រជាជនក្នុងឃុំពពេល បានបររទេះចាកចេញពីផ្ទះសម្បែងទៅរស់នៅឃុំពេជចង្វារ។ ពេលនោះ ខ្ញុំបានជួបជុំឪពុកម្ដាយវិញ។ ក្រុមគ្រួសាររបស់ខ្ញុំបានសាងសង់កូនខ្ទមរស់នៅតាមវាលស្រែ ក្នុងឃុំពេជចង្វារ។ នៅទីនោះ ឪពុកម្ដាយរបស់ខ្ញុំ និងអ្នកភូមិទាំងអស់បានប្រកបមុខរបរធ្វើស្រែ។

នៅឆ្នាំ១៩៧៥ ខ្មែរក្រហមរំដោះបានទីក្រុងភ្នំពេញទាំងស្រុង។ ខ្ញុំត្រូវបានខ្មែរក្រហមចាត់តាំងឱ្យ

ចូលក្នុងកងចល័តឃុំពពេល។ ខ្ញុំធ្វើការងាររែកដីដាក់ស្រែ កាប់ដីដំបូក និងរែកដី នៅតាមការដ្ឋានផ្សេងៗក្នុងស្រុកបរិបូណ៌។ បងៗរបស់ខ្ញុំត្រូវបានចាត់ឱ្យចូលក្នុងកងចល័តដូចខ្ញុំដែរ ប៉ុន្តែនៅក្នុងកងផ្សេង ហើយត្រូវចល័តឱ្យទៅធ្វើការងារនៅឆ្ងាយពីស្រុកបរិបូណ៌។ រីឯម្ដាយរបស់ខ្ញុំ ត្រូវបានខ្មែរក្រហមចាត់ឱ្យដាំបាយនៅក្នុងសហករណ៍ក្នុងឃុំពពេល។ ចំណែកឪពុកត្រូវបានចាត់តាំងឱ្យទៅនេសាទត្រីយកមកផ្គត់ផ្គង់តាមសហករណ៍ឱ្យបានគ្រប់ចំនួនដែលអង្គការកំណត់។ នៅក្នុងសម័យនោះ ឃុំពពេលមានសហករណ៍ចំនួន៣។ សម្រាប់របបអាហារ ខ្ញុំហូបបបរអង្ករដំណើប ប៉ុន្តែមិនបានហូបគ្រប់គ្រាន់ទេ។

នៅឆ្នាំ១៩៧៦ ខ្ញុំត្រូវធ្វើការងារកាន់តែធ្ងន់ធ្ងរជាងមុន។ នៅវេលាម៉ោង៤ទៀបភ្លឺ ប្រធានកងបានវាយជួងដាស់សមាជិកកងចល័តទាំងអស់ឱ្យក្រោកទៅតម្រង់ជួរ។ ម៉ោង៦ព្រឹក ខ្ញុំដើរទៅដល់ការដ្ឋានរួចហើយចាប់ផ្ដើមកាប់ដី និងរែកដីចាក់លើខ្នងទំនប់។ ប្រធានកងបានកំណត់ឱ្យមិត្តនារី៣នាក់ កាប់ដីឱ្យបាន៦ម៉ែត្រគុបក្នុងមួយថ្ងៃ រួចហើយរែកយកទៅចាក់លើទំនប់ឱ្យបានរួចរាល់ទើបអាចត្រឡប់មកសម្រាកបាន។ ប្រធានកងរបស់ខ្ញុំឈ្មោះ នារី រ៉ន កាចខ្លាំងណាស់ និងតែងតែបញ្ជាសមាជិកកងនារីឱ្យធ្វើការងារហើយរួចរាល់ទើបអនុញ្ញាតឱ្យឈប់សម្រាក។ ចំណែកចុងភៅចែករបបអាហារឱ្យខ្ញុំកាន់តែតិចទៅៗ គឺអង្ករដំណើប១កំប៉ុងសម្រាប់ហូបគ្នា១០នាក់។ ដោយសាររបបអាហារខ្វះខាតខ្លាំង និងធ្វើការមិនមានពេលវេលាសម្រាក ឪពុករបស់ខ្ញុំបានធ្លាក់ខ្លួនឈឺរហូតដល់ស្លាប់។ មិនយូរប៉ុន្មាន ប្អូនប្រុសពៅរបស់ខ្ញុំបានស្លាប់បន្តទៀតដោយសារមិនមានអាហារហូបគ្រប់គ្រាន់។ ខ្ញុំបានខិតខំកាប់ដីឱ្យបានរួចរាល់មុនថ្ងៃលិចជារៀងរាល់ថ្ងៃ រហូតថ្ងៃមួយ ខ្ញុំបានកាប់ត្រូវជើងខ្លួនឯងធ្វើឱ្យហូរឈាមយ៉ាងច្រើន។ ខ្ញុំបានសម្រាកព្យាបាលនៅផ្ទះអស់រយៈពេល៣ខែទើបធូរស្បើយ។ បន្ទាប់ពីជាសះស្បើយ ខ្ញុំនៅធ្វើការងារក្នុងចល័តស្រុកបរិបូណ៌ និងស្រុកមួយចំនួនទៀតក្នុងខេត្តកំពង់ឆ្នាំងដដែល។ នៅរដូវវស្សា ខ្ញុំបានចល័តទៅធ្វើស្រែជាមួយកងផ្សេងៗទៀត។ នៅពេលធ្វើការងារហើយរួចរាល់ ខ្ញុំតែងតែឆ្លៀតពេលលួចទៅរកក្ដាម ខ្យង យកមកដុតហូបនៅពេលយប់ស្ងាត់ ទោះបីខ្ញុំដឹងថាមានពូម្នាក់បានលួចទៅជីកដំឡូងហូប ហើយអង្គការចាប់បាន និងវាយសម្លាប់ចោលនៅរងដំឡូងក៏ដោយ។

នៅឆ្នាំ១៩៧៧ ខ្ញុំ និងមិត្តនារីក្នុងភូមិជាមួយគ្នា ត្រូវបានប្រធានកងបុរសឈ្មោះ សាត ជ្រើសរើសឱ្យធ្វើកងឈ្លបយាមតាមសហករណ៍ក្នុងឃុំពពេល។ ខ្ញុំ និងមិត្តនារី២នាក់ទៀត ត្រូវបានបញ្ជាឱ្យយាមនៅសហករណ៍ក្នុងឃុំពពេល ដើម្បីឃ្លាំចាំមើលក្រែងលោមានប្រជាជនលួចដាំបាយហូប និងលួចបេះបន្លែផ្លែឈើនៅក្នុងភូមិ។ នៅយប់មួយ ខ្ញុំបានលួចបេះផ្លែដូងមួយធ្លាយយកទៅឱ្យម្ដាយ។ លុះព្រឹកឡើង ខ្ញុំបានប្រាប់ប្រធានកងឈ្មោះ សាត ថា «ពូយប់មិញខ្ញុំបានបេះផ្លែដូងមួយធ្លាយយកទៅឱ្យម៉ែហើយ» ប៉ុន្តែពូសាត មិនបានស្ដីបន្ទោសខ្ញុំទេ។

នៅខែមករា ឆ្នាំ១៩៧៩ កងទ័ពវៀតណាមបានវាយចូលមកដល់ស្រុកបរិបូណ៌ ពេលនោះខ្ញុំបានរត់តាមកងទ័ពខ្មែរក្រហមចេញពីស្រុកបរិបូណ៌ទៅរស់នៅក្នុងព្រៃនៅភ្នំគុកជាមួយតា ធី។ ខ្ញុំបានផ្លាស់ទីតាំងពីកន្លែងមួយទៅកន្លែងមួយទៀត ព្រោះកងទ័ពវៀតណាមដេញបាញ់ពីក្រោយ។ ខ្ញុំរស់នៅលើភ្នំ និងដើរជីកដំឡូងហូប ហើយពេលខ្លះខ្ញុំលួចចូលមកក្នុងភូមិដើម្បីសុំអង្ករពីអ្នកស្រុក។

នៅឆ្នាំ១៩៨២ ខ្ញុំបានទៅរស់នៅជាមួយ អ៊ំ យឹម គឺជាគណៈតំបន់៣១ (តំបន់កំពង់ឆ្នាំង) នៅភ្នំឱរ៉ាល់ ខេត្តកំពង់ស្ពឺ។ ខ្ញុំបានរស់នៅចល័តពីកន្លែងមួយទៅកន្លែងមួយនៅលើភ្នំឱរ៉ាល់ ហើយត្រូវដើរស្ពាយចានឆ្នាំង ឱ្យកងទ័ពប្រុសៗ ដែលកំពុងប្រយុទ្ធតទល់ជាមួយកងទ័ពវៀតណាម និងកងទ័ពរណសិរ្សសាមគ្គីសង្គ្រោះជាតិកម្ពុជា។ បន្ទាប់មក អ៊ំ យឹម បាននាំខ្ញុំ និងមិត្តនារីប្រហែល៥០នាក់ ដើរថ្មើរជើងចេញពីភ្នំឱរ៉ាល់មកកាន់ព្រំដែនថ្មដា ខេត្តពោធិ៍សាត់។ ខ្ញុំធ្វើដំណើរអស់រយៈពេលជិតមួយខែ ទើបមកដល់ព្រំដែនថ្មដា។

ខ្ញុំស្នាក់នៅតំបន់ស្ទឹងកាច់ ទឹកឈូ (ថ្មដាធំ) ស្ថិតក្នុងឃុំថ្មដា ខេត្តពោធិ៍សាត់។ នៅពេលខ្ញុំមកដល់ថ្មដាដំបូង ខ្ញុំមិនឃើញមានប្រជាជនឡើយ គឺឃើញមានតែកងទ័ពខ្មែរក្រហម។ ខ្ញុំដើរលេងនៅលើភ្នំតាមព្រំដែនថ្មដា រួចមើលឃើញប្រជាជនថៃកំពុងភ្ជួររាស់ដី និងស្ទូងស្រូវ។ ខ្ញុំមើលពីលើភ្នំទៅឃើញមនុស្ស និងរថយន្តតូចៗ។ ខ្ញុំមិនបានដឹងថាទីតាំងនេះគឺជាព្រំដែនរវាងប្រទេសកម្ពុជា និងប្រទេសថៃទេ។ ចំពោះដីរបស់ខ្មែរ ដែលត្រូវកងទ័ពខ្មែរក្រហមកាន់កាប់គឺនៅតាមភ្នំខ្ពស់ៗ ចំណែកដីថៃនៅតាមដីវាលរាបខាងក្រោម និងនៅឆ្ងាយពីជើងភ្នំ។ អ៊ំ យឹម នៅប្រជុំជាមួយកម្មាភិបាលខ្មែរក្រហមនៅថ្មដារយៈពេល១ខែ ទើបធ្វើដំណើរទៅកាន់ភ្នំឱ្រាល់វិញ។ នៅពេលធ្វើដំណើរ ខ្ញុំ និងមិត្តនារី បានស្ពាយអង្ករម្នាក់៥០គីឡូក្រាម គ្រាប់មីន គ្រាប់បេ និងសម្លៀកបំពាក់ចេញពីថ្មដាទៅកាន់ភ្នំឱ្រាល់វិញ។

នៅឆ្នាំ១៩៨៤ ខ្ញុំបានរៀបការជាមួយប្ដីឈ្មោះ អិន ផុន គឺជាពេទ្យកងទ័ពខ្មែរក្រហម ដោយមាន អ៊ំ យឹម គឺជាមេបាចាស់ទុំ។ ខ្ញុំបានធ្វើដំណើរមកកាន់ព្រំដែនថ្មដា៤ដងប៉ុណ្ណោះ។ នៅឆ្នាំ១៩៩៧ ខ្ញុំ និងប្ដីបានរត់ភៀសខ្លួនទៅរស់នៅក្នុងជំរំខៅភ្លូ ប្រទេសថៃ អស់រយៈពេល៣ឆ្នាំ។ នៅឆ្នាំ២០០០ ខ្ញុំ និងប្ដីបានចូលមករស់នៅក្នុងឃុំអន្លង់រាប ស្រុកវាលវែង ខេត្តពោធិ៍សាត់រួមជាមួយក្រុមគ្រួសារកងទ័ពខ្មែរក្រហមប្រហែល៤០ទៅ៥០គ្រួសារទៀត ដោយសាងសង់ផ្ទះតូចៗសម្រាប់ស្នាក់នៅ។



ចម្ការដំណាំ និងផ្ទះប្រជាជននៅភូមិដីក្រហម ឃុំអន្លង់រាប ស្រុកវាលវែង ខេត្តពោធិ៍សាត់ ។
(បណ្ណសារមជ្ឈមណ្ឌលឯកសារកម្ពុជា)

# ខ្ញុំបាត់បង់កូនប្រុសជាទីស្រឡាញ់ ដោយសារការឈ្លានពានរបស់ទាហានថៃ

គាត ស្រីឡែន



ឡេង គីមលាង អាយុ៤៥ឆ្នាំ សព្វថ្ងៃរស់នៅភូមិគោកព្រេច ឃុំគោករមៀត ស្រុកថ្មពួក ខេត្តបន្ទាយមានជ័យ។ (បណ្ណសារមជ្ឈមណ្ឌលឯកសារកម្ពុជា)

កូនប្រុសខ្ញុំមានឈ្មោះ ខុម ឃីម អាយុ១៣ឆ្នាំ បានបាត់បង់ជីវិត ដោយសារតែគ្រាប់ផ្លោងរបស់ទាហានថៃធ្លាក់ចំផ្ទះរបស់ខ្ញុំស្ថិតក្នុងភូមិគោកព្រេច ឃុំគោករមៀត ស្រុកថ្មពួក ខេត្តបន្ទាយមានជ័យ កាលពីព្រឹកព្រលឹមថ្ងៃទី១០ ខែធ្នូ ឆ្នាំ២០២៥។

ខ្ញុំឈ្មោះ ឡេង គីមលាង អាយុ៤៥ឆ្នាំ មានស្រុកកំណើតនៅភូមិគោកព្រេច ឃុំគោករមៀត ស្រុកថ្មពួក ខេត្តបន្ទាយមានជ័យ។ សព្វថ្ងៃ ខ្ញុំរស់នៅភូមិឃុំដដែល។ ខ្ញុំមានឪពុកឈ្មោះ គុណ ឡេង សព្វថ្ងៃរស់នៅឃុំបន្ទាយឆ្មារ និងម្តាយឈ្មោះ គៀក រីន ស្លាប់ប្រហែល១០ឆ្នាំហើយ។ ខ្ញុំមានបងប្អូនចំនួន៦នាក់ គឺប្រុស៤នាក់និងស្រី២នាក់ ហើយខ្ញុំគឺជាកូនទី៣នៅក្នុងគ្រួសារ។

ខ្ញុំមានប្តីឈ្មោះ ណៃ ខុម អាយុ៤៤ឆ្នាំ មានស្រុកកំណើតនៅឃុំធិបតី ស្រុកគាស់ក្រឡ ខេត្តបាត់ដំបង។ កាលពីក្មេង ខ្ញុំមិនបានរៀនសូត្រទេ ព្រោះខ្ញុំទៅធ្វើការស៊ីឈ្នួលដកដំឡូង និងដាំដំឡូងនៅប្រទេសថៃ។ ខ្ញុំរស់នៅប្រទេសថៃបានរយៈពេលប្រហែល១ឆ្នាំ ក៏ត្រឡប់មកស្រុកកំណើតវិញ។ ក្រោយពីត្រឡប់មកពីប្រទេសថៃវិញ ខ្ញុំបានរៀបការជាមួយប្តីរបស់ខ្ញុំ និងប្រកបរបរធ្វើស្រែចម្ការ ដាំដំឡូង និងដើរស៊ីឈ្នួលស្ទូងស្រូវ ដកដំឡូង ដាំដំឡូងឱ្យអ្នកស្រុកក្នុងភូមិជាមួយគ្នា។ ចំណងអាពាហ៍ពិពាហ៍របស់ខ្ញុំនិងប្តី មានកូនប្រុសពីរនាក់ គឺកូនប្រុសច្បងឈ្មោះ ខុម សុឃី សព្វថ្ងៃមានអាយុ១៨ឆ្នាំ។ ចំណែកកូនប្រុសពៅឈ្មោះ ខុម ឃីម អាយុ១៣ឆ្នាំ។ កូនប្រុសច្បងរបស់ខ្ញុំបានចេញទៅធ្វើការនៅទីក្រុងភ្នំពេញ និងមានប្រពន្ធរួចហើយ។

មុនពេលផ្ទុះអាវុធរវាងកម្ពុជានិងថៃ ក្នុងខែធ្នូ ឆ្នាំ២០២៥ នៅផ្ទះខ្ញុំមានសមាជិកចំនួន៣នាក់ គឺរូបខ្ញុំ ប្តី និងកូនប្រុសពៅ។ កូនប្រុសពៅរបស់ខ្ញុំគឺជាក្មេងប្រុសសុភាពរាបសារ ចេះជួយការងារឪពុកម្តាយ ចេះគោរពចាស់ទុំ។ ជាពិសេសកូនប្រុសពៅរបស់ខ្ញុំស្រឡាញ់ខ្ញុំខ្លាំងណាស់ ហើយតែងតែជួយការងារខ្ញុំ ដូចជាទៅជួយដកដំឡូង និងដាំដំឡូងជាមួយខ្ញុំ។ ពេលកូនប្រុសពៅរបស់ខ្ញុំទៅណាមកណាម្តងៗ ចង់ឱ្យខ្ញុំទៅជាមួយគាត់គ្រប់ពេល។

នៅថ្ងៃទី៨ ខែធ្នូ ឆ្នាំ២០២៥ ទាហានថៃចាប់ផ្តើមផ្ទុះអាវុធជាលើកទី២។ នៅពេលនោះ ប្រជាជនមួយចំនួននៅក្នុងភូមិគោកព្រេច បាននាំគ្នាភៀសខ្លួន



ប្តីរបស់ ឡេង គីម លាង នៅផ្ទះនៅភូមិគោកព្រេច ឃុំគោករមៀត ស្រុកថ្មពួក ខេត្តបន្ទាយមានជ័យ។ (បណ្ណសារមជ្ឈមណ្ឌលឯកសារកម្ពុជា)

ចេញពីផ្ទះសម្បែង និងភូមិឋាន។ ចំណែកខ្ញុំចង់ភៀសខ្លួនចេញជាមួយប្រជាជនទាំងនោះដែរ ប៉ុន្តែប្តី និងកូនប្រុសខ្ញុំមិនព្រមចាកចេញពីផ្ទះ។ ហេតុនេះ គ្រួសារខ្ញុំបានត្រឹមនាំគ្នារត់ចូលលេណដ្ឋាន ដែលបានជីកទុកតាំងពីពេលផ្ទុះអាវុធលើកទី១ ក្នុងថ្ងៃទី២៤ ខែកក្កដា ឆ្នាំ២០២៥ ដើម្បីលាក់ខ្លួន។ នៅថ្ងៃនោះ កូនប្រុសពៅខ្ញុំបាននិយាយប្រាប់ខ្ញុំថា «ម៉ែៗ ខ្ញុំបានឃើញដ្រូនរបស់ទាហានថៃហោះ»។

ចាប់តាំងពីផ្ទុះអាវុធថ្ងៃទី៨ ខែធ្នូ ឆ្នាំ២០២៥មក គ្រួសារខ្ញុំមានសមាជិកបីនាក់ តែងតែរត់ចូលពួននៅក្នុងលេណដ្ឋាន។ ខ្ញុំតែងតែនិយាយប្រាប់កូនប្រុសច្បងខ្ញុំអំពីស្ថានភាពទាហានថៃបាញ់ផ្លោងចូលមកលើទឹកដីខ្មែរ។ នៅថ្ងៃទី៩ ខែធ្នូឆ្នាំ២០២៥ សភាពការណ៍បានស្ងប់ស្ងាត់ ហើយនៅម៉ោងប្រហែល១២រំលងអាធ្រាតឈានចូលដល់ថ្ងៃទី១០ កូនប្រុសរបស់ខ្ញុំនិយាយមកកាន់ខ្ញុំថា«ម៉ែៗ! ខ្វយទិចខ្ញុំ»ព្រុដូច្នេះ ខ្ញុំបានយកប្រេងកូឡាទៅលាបឱ្យកូន រួចហើយខ្ញុំនាំកូនចេញពីលេណដ្ឋាន ឡើងទៅសម្រាកនៅលើផ្ទះ ព្រោះនៅមិនទាន់មានការបាញ់ផ្លោងបន្តទៀត។

នៅព្រឹកព្រលឹមថ្ងៃទី១០ ខែធ្នូ ឆ្នាំ២០២៦ ពេលខ្ញុំក្រោកពីដេក ខ្ញុំមិនឃើញកូនប្រុសពៅរបស់ខ្ញុំទេ។ ពេលខ្ញុំចុះមកក្រោមផ្ទះ ទើបដឹងថាកូនប្រុសខ្ញុំចុះមកក្រោមដើម្បីចូលបន្ទប់ទឹក។ បន្ទាប់ពីកូនខ្ញុំចូលបន្ទប់ទឹកមួយសន្ទុះ កូនខ្ញុំបានដើរមករកខ្ញុំដែលកំពុងឈរនៅជិតចង្រ្កាន។ ខ្ញុំបានសួរទៅកូនប្រុសខ្ញុំថា «យ៉ាងម៉េចហើយកូនមានព្រុសំឡេងគ្រាប់កាំភ្លើងទៀតទេ?» កូនខ្ញុំឆ្លើយថាមិនព្រុទេ។ បន្ទាប់មកកូនខ្ញុំកាន់ទូរសព្ទយកមកសាកថ្ម រួចដាក់ទូរសព្ទនៅលើតុថ្ម។ ខ្ញុំសួរកូនរួចហើយ ក៏ដើរទៅអង្គុយលើគ្រែដើម្បីរៀបចំបត់ខោអាវទុក។ បន្ទាប់មក កូនខ្ញុំបានដើរមករកខ្ញុំដែលកំពុងអង្គុយបត់ខោអាវ ស្រាប់តែមានគ្រាប់កាំភ្លើងធំធ្លាក់ក្បែរគ្រែ ហើយអំបែងគ្រាប់បានហោះមកចំកូនប្រុសខ្ញុំ ដែលកំពុងដើរមកកាន់ខ្ញុំ។ ពេលនោះកូនខ្ញុំបានដួលទៅលើដីភ្លាមៗ។ ខ្ញុំភាំងស្មារតី ឈរងើងមើលអ្វីមិនឃើញឡើយ បានត្រឹមស្រែកហៅប្តី ចំណែកត្រចៀកខ្ញុំឡើងហឹង និងមានផ្សែងហុយងងឹតឈឹង។ ខ្ញុំរកមើលអ្វីមិនឃើញឡើយ។ អំបែងគ្រាប់ខ្ទាតត្រូវចំខ្នងដៃឆ្វេងរបស់ខ្ញុំ និងដាច់ក្រវិលត្រចៀកមួយចំហៀងរបស់ខ្ញុំ។

រំពេចនោះ ប្តីខ្ញុំដែលកំពុងឈរនៅមុខផ្ទះ បានរត់មករកខ្ញុំ ហើយបានទាញខ្ញុំចូលទៅក្នុងលេណដ្ឋាន។ បន្ទាប់មកប្តីខ្ញុំសួររកកូន ខ្ញុំបានត្រឹមឆ្លើយតបទៅប្តីទាំងទឹកភ្នែកថា «កូនយើងត្រូវគ្រាប់ហើយ នៅក្រោមផ្ទះ»។ ប្តីខ្ញុំដឹងថាកូនស្លាប់ ក៏រត់ចេញពីលេណដ្ឋានទៅរកកូន ហើយបានលើកកូនបីរត់ចូលក្នុងលេណដ្ឋានវិញ។ កូនខ្ញុំធ្លាយពោះ ត្រូវចំចង្កោរ ហើយអំបែងគ្រាប់ផ្លោងខ្ទាតត្រូវស៊ុះពេញខ្លួនប្រាណ។ នៅពេលប្តីខ្ញុំបីកូនពីក្រោមផ្ទះចូលក្នុងលេណដ្ឋាន កូនខ្ញុំនៅមានដង្ហើមតិចៗ បន្ទាប់មកក៏ផុតដង្ហើមទៅ។ គ្រាប់ផ្លោងបានបន្តរហូតដល់ម៉ោងប្រមាណ៧ព្រឹក បន្ទាប់មកមេភូមិគោកព្រេចបានដើរមកផ្ទះខ្ញុំ និងប្រាប់ប្តីខ្ញុំឱ្យនាំខ្ញុំទៅមន្ទីរពេទ្យមុន ចាំត្រឡប់មកយកសពកូនតាមក្រោយ។ បន្ទាប់ពីមេភូមិប្រាប់ប្តីខ្ញុំរួច ប្តីខ្ញុំបានដឹកខ្ញុំទៅភូមិបន្ទាត់បោះ ឃុំតាផូ ស្រុកស្វាយចេក ខេត្តបន្ទាយមានជ័យ។ នៅពេលទៅដល់ភូមិបន្ទាត់បោះ ប្រជាជននៅក្នុងភូមិដែលឃើញប្តីខ្ញុំប្រឡាក់ឈាមពេញខ្លួន បានប្រាប់ប្តីខ្ញុំឱ្យទៅងូតទឹកសម្អាតខ្លួន ដោយទុកឱ្យពួកគាត់ជួយនាំខ្ញុំទៅមណ្ឌលសុខភាពឃុំ

តាផូជំនួស។ បន្ទាប់ពីគ្រូពេទ្យពិនិត្យរបួសខ្ញុំរួចហើយ គ្រូពេទ្យបានផ្តល់ថ្នាំឱ្យខ្ញុំទុកលេប និងលាបរបួស។ ក្រោយមក ខ្ញុំចេញពីមណ្ឌលសុខភាពឃុំតាផូ រួចធ្វើដំណើរមកភូមិបន្ទាត់បោះវិញ។ នៅវេលាម៉ោង១២ថ្ងៃត្រង់ ប្តីខ្ញុំបានមកយកសាកសពកូនម្នាក់ឯង និងបានដឹកសពកូនតាមគោយន្តតាមផ្លូវភូមិស្រែល្អ ឆ្ពោះទៅស្រុកថ្មពួក។ នៅតាមផ្លូវ ប្តីខ្ញុំបានជួបព្រះសង្ឃចំនួនពីរអង្គ ក៏និមន្តព្រះសង្ឃ ទាំងពីឱ្យឡើងជិះគោយន្តមកជាមួយសពកូនប្រុសខ្ញុំ។ ប្តីខ្ញុំបានបើកគោយន្តទៅវត្តភូមិថ្មី ឃុំភូមិថ្មី ស្រុកថ្មពួក ខេត្តបន្ទាយមានជ័យ។ នៅវេលាម៉ោង៥ល្ងាចថ្ងៃដដែល ប្តីខ្ញុំទៅដល់វត្តភូមិថ្មី ដោយអាជ្ញាធរស្រុកថ្មពួក នៅរង់ចាំទទួល និងរៀបចំបុណ្យសពកូនខ្ញុំនៅក្នុងវត្តភូមិថ្មីតែម្តង។ ប្តីខ្ញុំបាននិមន្តព្រះសង្ឃចំនួន៣អង្គបង្សុកូលមុននឹងយកសពកូនប្រុសខ្ញុំទៅបូជានៅវេលាម៉ោងប្រមាណជាង៦ល្ងាច ក្នុងថ្ងៃដដែល។ នៅខណៈពេលកំពុងបូជាសពកូន ព្រះសង្ឃបានប្រាប់ប្តីខ្ញុំឱ្យមកមើលថែខ្ញុំនៅភូមិបន្ទាត់បោះវិញ ដោយទុកឱ្យព្រះអង្គជួយរើសឆ្អឹងកូនប្រុសខ្ញុំរក្សាទុកឱ្យ។ ប្តីរបស់ខ្ញុំបានចេញមករកខ្ញុំទាំងយប់ ទាំងមិនស្គាល់ផ្លូវច្បាស់លាស់។ ប្តីខ្ញុំបានវង្វេងផ្លូវរហូតដល់ម៉ោងជិត១០យប់ ទើបមកដល់ភូមិបន្ទាត់បោះ។

នៅព្រឹកនៅថ្ងៃទី១១ ខែធ្នូ ឆ្នាំ២០២៥ ប្តីរបស់ខ្ញុំបានទៅយកឆ្អឹងកូនប្រុសមកផ្ញើទុកជាមួយព្រះសង្ឃក្នុងភូមិបន្ទាត់បោះ។ នៅថ្ងៃបុណ្យគម្រប់៧ថ្ងៃកូនប្រុសខ្ញុំ ខ្ញុំបានដាំបាយធ្វើម្ហូបបន្តិចបន្តួចតែប៉ុណ្ណោះ យកទៅប្រគេនព្រះសង្ឃនៅវត្តបន្ទាត់បោះ។ ចាប់តាំងពីកូនប្រុសស្លាប់ ខ្ញុំខ្សឹកខ្សួលហ៍យល់សប្តិឃើញកូនខ្ញុំ។ ខ្ញុំយល់សប្តិឃើញកូនខ្ញុំមករកទូរសព្ទ។ ខ្ញុំដឹងថាកូនខ្ញុំស្រឡាញ់ទូរសព្ទណាស់ ពីព្រោះខ្ញុំទើបទិញឱ្យកូនខ្ញុំប្រើប្រាស់បានរយៈពេល២០ថ្ងៃតែប៉ុណ្ណោះ មុនពេលកូនខ្ញុំស្លាប់ដោយសារគ្រាប់ផ្លោងរបស់ទាហានថៃ។

ខ្ញុំ និងប្តី ត្រូវភៀសខ្លួនរហូតមកដល់ថ្ងៃទី៣ ខែមករា ឆ្នាំ២០២៦ ទើបខ្ញុំត្រឡប់មកផ្ទះវិញ។ បន្ទាប់មកខ្ញុំបានរៀបចំធ្វើបុណ្យឱ្យកូនប្រុសបានសមរម្យ និងបានយកទូរសព្ទកូនទៅវត្ត ដើម្បីឱ្យព្រះសង្ឃសូត្រធម៌ឧទ្ទិសទៅឱ្យកូន។



លេណដ្ឋានការពារខ្លួនរបស់គ្រួសារ ឡេង គឹមលាង ពីការបាញ់ផ្លោងនិងការទម្លាក់គ្រាប់ពីកងទ័ពថៃ ស្ថិតនៅផ្ទះក្នុងភូមិគោកព្រេច ឃុំគោកមៀត ស្រុកថ្មពួក ខេត្តបន្ទាយមានជ័យ។ (បណ្ណសារមជ្ឈមណ្ឌលឯកសារកម្ពុជា)

ខ្ញុំនឹកកូនខ្ញុំខ្លាំងណាស់។ ខ្ញុំស្រឡាញ់កូនខ្ញុំខ្លាំងណាស់ ព្រោះកូនប្រុសទី២របស់ខ្ញុំតែងតែនៅក្បែរខ្ញុំជានិច្ចមិនថានៅកន្លែងធ្វើការ ឬនៅផ្ទះ។ ពេលខ្ញុំជួបបញ្ហាក្នុងពេលកំពុងធ្វើការ និងពេលមេឃភ្លៀង គឺកូនខ្ញុំតែងតែយកចិត្តទុកដាក់ជាមួយខ្ញុំ ដោយយកស្លឹកមកបាំងឱ្យខ្ញុំកុំឱ្យទទឹក។ គ្រួសារខ្ញុំធ្លាប់តែមានសេចក្តីសុខ សុភមង្គល ប្រែជាមានទុក្ខធំ។ ខ្ញុំបានបាត់បង់កូនប្រុសជារៀងរហូត ខ្ញុំមិនអាចកាត់ចិត្តពីកូនប្រុសខ្ញុំបានឡើយ។ ខ្ញុំធ្លាប់តែគិតថា អនាគតទៅ ខ្ញុំនឹងពឹងពាក់ទៅលើកូនប្រុសពៅរបស់ខ្ញុំ ប៉ុន្តែពេលនេះ ខ្ញុំបានបាត់បង់កូនជាទីស្រឡាញ់ហើយ។ ខ្ញុំនិងប្តីគិតអ្វីលែងចេញ ព្រោះតែនឹកកូន។

ខ្ញុំបានបាត់បង់កូនប្រុស ក៏ព្រោះតែទាហានថៃបានបំពានច្បាប់ ចង់ដណ្តើមយកទឹកដីខ្មែរ។ គ្រាប់ផ្លោងរបស់ទាហានថៃមិនត្រឹមតែធ្វើឱ្យកូនខ្ញុំស្លាប់ទេថែមទាំងធ្វើឱ្យសម្ភារប្រើប្រាស់ផ្ទះសម្បែងខ្ញុំបែកបាក់គ្មានសល់ឡើយ។ ខ្ញុំចង់ឱ្យប្រទេសជាតិមានសុខសន្តិភាព និងចង់បានយុត្តិធម៌សម្រាប់កូនប្រុសរបស់ខ្ញុំ។



ផ្ទះរបស់ ឡេង គឹមលាង ធ្លុះធ្លាយដោយសារគ្រាប់ផ្លោង និងការទម្លាក់គ្រាប់ពីកងទ័ពថៃ។
(បណ្ណសារមជ្ឈមណ្ឌលឯកសារកម្ពុជា)



ផ្ទះរបស់ ឡេង គឹមលាង ធ្លុះធ្លាយដោយសារគ្រាប់ផ្លោង និងការទម្លាក់គ្រាប់ពីកងទ័ពថៃ។ (បណ្ណសារមជ្ឈមណ្ឌលឯកសារកម្ពុជា)

# ហ៊ាន់ សុខុម ៖ អតីតទាហានប៉ារ៉ានៅជំរំឫទ្ធិសែន

**ផាវ សម្ផស្ស**



*ហ៊ាន់ សុខុម អាយុ៦៦ឆ្នាំ សព្វថ្ងៃរស់នៅភូមិ៣ សង្កាត់ព្រះពន្លា ក្រុងសិរីសោភ័ណ ខេត្តបន្ទាយមានជ័យ។ (បណ្ណសារមជ្ឈមណ្ឌលឯកសារកម្ពុជា)*

ខ្ញុំឈ្មោះ ហ៊ាន់ សុខុម អាយុ៦៦ឆ្នាំ កើតនៅភូមិរកាកោងជើង ឃុំមហាលាភ ស្រុកកោះសូទិន ខេត្តកំពង់ចាម។ បច្ចុប្បន្ន ខ្ញុំរស់នៅភូមិ៣ សង្កាត់ព្រះពន្លា ក្រុងសិរីសោភ័ណ ខេត្តបន្ទាយមានជ័យ។ ខ្ញុំមានឪពុកឈ្មោះ អេង ហ៊ាន់ (ស្លាប់ឆ្នាំ២០២១) និងម្តាយឈ្មោះ ឡាំ អាន។ ខ្ញុំមានបងប្អូនចំនួន៩នាក់ ក្នុងនោះមានស្រីចំនួន៥នាក់ និងប្រុសចំនួន៤នាក់ ហើយខ្ញុំគឺជាកូនទី២នៅក្នុងគ្រួសារ។ ខ្ញុំមានប្រពន្ធឈ្មោះ ម៉ិន ប៊ុនធឿន អាយុ៦៣ឆ្នាំ និងមានកូនចំនួន៦នាក់ ក្នុងនោះមានកូនប្រុសចំនួន៣នាក់ និងកូនស្រីចំនួន៣នាក់។

កាលពីវ័យកុមារ គ្រួសារខ្ញុំបានផ្លាស់មករស់នៅធ្វើការងារនៅស្រុកចំការលើ ខេត្តកំពង់ចាម។ ខ្ញុំរៀនបានត្រឹមថ្នាក់ទី១០ពីសង្គមចាស់ នៅសាលាបឋមសិក្សាក្នុងភូមិស្វាយទាប ស្រុកចំការលើ ខេត្តកំពង់ចាម។ នៅឆ្នាំ១៩៧៣ គ្រួសារខ្ញុំបានត្រឡប់មករស់នៅស្រុកកំណើតវិញ។ នៅពេលនោះ ខ្មែរក្រហមបានចូលមកគ្រប់គ្រងភូមិកំណើតរបស់ខ្ញុំ និងបានចាត់តាំងឪពុកម្តាយខ្ញុំឱ្យដាំបេក។ នៅឆ្នាំ១៩៧៥ ខ្មែរក្រហមចាត់តាំងខ្ញុំឱ្យនៅក្នុងកងស្រួច និងបង្ខំខ្ញុំឱ្យធ្វើការងារពលកម្ម ដូចជា ប្រូតស្រូវ ដកស្ទូង និងរែកដី។

នៅឆ្នាំ១៩៧៦ ខ្មែរក្រហមបញ្ជូនខ្ញុំទៅវែកដីលើកទំនប់ ជីកប្រឡាយ និងធ្វើផ្លូវនៅស្រុកអូររាំងឪ និងស្រុកមួយចំនួនក្នុងខេត្តព្រៃវែងនៃតំបន់២២ ភូមិភាគបូព៌ា។ ពេលនោះ ខ្ញុំមិនសូវបានហូបគ្រប់គ្រាន់ទេ គឺហូបតែបបរលាយត្រកួន និងដើមចេក។ ខ្ញុំលើកទំនប់ប្រឡាយរហូតដល់ពេលកងទ័ពវៀតណាមចូលមករំដោះនៅឆ្នាំ១៩៧៩។ បន្ទាប់មក ខ្ញុំបានត្រឡប់មកជួបឪពុកម្ដាយវិញ។ ខ្ញុំរស់នៅជាមួយឪពុកម្ដាយបានមួយរយៈ ក៏ចេញទៅរកស៊ីដឹកថ្នាំជក់ពីមហាលាភ ស្រុកកោះសូទិនយកទៅលក់នៅបារិតក្នុងខេត្តស្វាយរៀងជាប់ព្រំដែនប្រទេសវៀតណាម។ បន្ទាប់មក ខ្ញុំទិញខ្ទឹមស ខ្សែក្រវាត់ និងគ្រឿងបម្លាស់កង់យកមកលក់នៅផ្សារក្នុងខេត្តកំពង់ចាមវិញ។

នៅឆ្នាំ១៩៨១ ខ្ញុំបានផ្លាស់មករកស៊ីនៅស្វាយស៊ីសុផុនជាមួយមិត្តភក្តិម្នាក់ឈ្មោះ ស្រៀក ដោយត្រូវជិះកង់ចេញពីស្រុកកំណើតមកស្នាក់នៅស្វាយស៊ីសុផុន។ បន្ទាប់មក ខ្ញុំទិញបារីរួចហើយដឹកតាមកង់ទៅលក់នៅខេត្តបាត់ដំបង និងទីក្រុងភ្នំពេញ។

នៅឆ្នាំ១៩៨២ ខ្ញុំសម្រេចចិត្តចេញពីស្វាយស៊ីសុផុនមករស់នៅក្នុងជំរំណងចាន់។ នៅជំរំណងចាន់ ខ្ញុំស្នាក់ជាមួយឪពុកមាខ្ញុំឈ្មោះ ឆេង។ បន្ទាប់មក ខ្ញុំចូលធ្វើទាហានប៉ារ៉ានៅជំរំថ្មី។ ខ្ញុំស្នាក់នៅជិតប្រាសាទសេរីដែលស្ថិតនៅក្នុងដីខ្មែរ។ នៅឆ្នាំ១៩៨២ ដដែល ខ្ញុំបានរៀបការជាមួយប្រពន្ធឈ្មោះ ម៉ន ប៊ុនធឿន។ នៅជំរំថ្មី មានប្រជាជនរាប់ម៉ឺននាក់ បានសង់ផ្ទះស្នាក់នៅទៅតាមសង្កាត់នីមួយៗ។ ប្រធានជំរំថ្មីមានឈ្មោះ សាញ់ ណោ។ ខ្ញុំបានសង់ផ្ទះដោយសសរឫស្សី ជញ្ជាំងឫស្សី និងប្រក់ស្លឹក។ នៅជំរំថ្មីមានទាហានចំនួន៣ កងវរសេនាតូច៖ កងវរសេនាតូច២១៥ ដឹកនាំដោយលោក ខឹម សោភ័ណ្ឌ និងលោក ស្ដើង។ កងវរសេនាតូចលេខ២០៦ ដឹកនាំដោយលោក ផែន លឺ និងកងវរសេនាតូចលេខ១៨៣ ដឹកនាំដោយលោក ឆាយ គី។

នៅខែធ្នូ ឆ្នាំ១៩៨៤ កងទ័ពវៀតណាមបានវាយចូលជំរំថ្មី ហេតុនេះប្រជាជននាំគ្នារត់ទៅស្នាក់នៅជិតព្រំប្រទល់កម្ពុជា-ថៃ។ បន្ទាប់មកអង្គការសហប្រជាជាតិនាំប្រជាជនភៀសខ្លួនទាំងនោះ ទៅរស់នៅក្នុងជំរំសាយធូក្នុងដីថៃ។ នៅជំរំសាយធូមានប្រធានជំរំឈ្មោះ ធូ ថុន។ ពេលខ្ញុំរស់នៅជំរំសាយធូ គ្រួសារខ្ញុំប្រកបមុខរបរលក់នំបញ្ចុករហូតដល់មាតុភូមិវិវត្តន៍នៅឆ្នាំ១៩៩២។



អតីតជំរំជនភៀសខ្លួនណងចាន់ នៅទសវត្សរ៍ ឆ្នាំ១៩៨០ ។ (បណ្ណសារមជ្ឈមណ្ឌលឯកសារកម្ពុជា)

# ប្តីរបស់ខ្ញុំស្លាប់ដោយសារត្រូវអំបែងគ្រាប់ផ្លោងរបស់ទាហានថៃ

កែវ សុភី

ខ្ញុំឈ្មោះ ឈិត សំអែត អាយុ៥៣ឆ្នាំ គឺជាកូនទី៤ នៅក្នុងចំណោមបងប្អូនចំនួន៥នាក់។ ក្នុងចំណោមបងប្អូនទាំង៥នាក់របស់ខ្ញុំ គឺមានចំនួន២នាក់បានស្លាប់ដោយសារជំងឺ។ កាលពីក្មេង ខ្ញុំមិនបានរៀនសូត្រដូចក្មេងឯទៀតទេ គឺខ្ញុំនៅឃ្វាលគោ-ក្របី ធ្វើស្រែ ចម្ការ ជាមួយម្តាយឈ្មោះ ហែម អ្លួន និងឪពុកឈ្មោះ ឈិត។ សព្វថ្ងៃឪពុកម្តាយរបស់ខ្ញុំបានស្លាប់អស់ហើយ។

នៅចន្លោះឆ្នាំ១៩៨៧ និងឆ្នាំ១៩៨៨ ខ្ញុំមានបំណងចង់រៀនសូត្រ និងចង់ទៅលេងបងប្អូនដែលរស់នៅជំរំជនភៀសខ្លួន ហេតុដូច្នេះខ្ញុំសម្រេចចិត្តលួចធ្វើដំណើរទៅជំរំសាយធូតែម្នាក់ឯង។ ខ្ញុំចេញពីផ្ទះទៅជំរំទាំងមិនបានប្រាប់ម្តាយ ពីព្រោះខ្ញុំដឹងថាម្តាយខ្ញុំច្បាស់ជាមិនអនុញ្ញាតឱ្យខ្ញុំទៅម្នាក់ឯងឡើយ។ ខ្ញុំមកស្នាក់នៅជំរំសាយធូបានប្រហែលជា៣ខែ ក៏ត្រឡប់មកផ្ទះវិញ។



ឈិត សំអែត អាយុ៥៣ឆ្នាំ សព្វថ្ងៃរស់នៅភូមិកណ្តោល ឃុំគោករមៀត ស្រុកថ្មពួក ខេត្តបន្ទាយមានជ័យ។ (បណ្ណសារមជ្ឈមណ្ឌលឯកសារកម្ពុជា)

លុះដល់ឆ្នាំ១៩៩០ ខ្ញុំបានសម្រេចចិត្តត្រឡប់ទៅជំរំសាយធូជាលើកទីពីរ។ ការធ្វើដំណើររបស់ខ្ញុំទៅជំរំសាយធូលើកនេះបានផ្លាស់ប្តូរជីវិតរបស់ខ្ញុំជារៀងរហូត។ នៅក្នុងជំរំសាយធូខ្ញុំបានជួបជាមួយប្តីរបស់ខ្ញុំឈ្មោះ វ៉ាន់វីរៈ (ហៅយក្ស) មានស្រុកកំណើតនៅភូមិអូរមុនី ឃុំអន្លង់វិល ស្រុកសង្កែ ខេត្តបាត់ដំបង។ បន្ទាប់ពីស្គាល់គ្នាបានត្រឹមតែ២ថ្ងៃ នៅសង្កាត់លេខ១០ ជំរំបាំងភូ បំណុះជំរំសាយធូ យើងបានសម្រេចចិត្តរៀបការ និងសាងគ្រួសារជាមួយគ្នានៅក្នុងជំរំសាយធូនោះតែម្តង។ ពេលនោះ ថ្លៃបណ្ណាការប្តុំថ្លៃទឹកដោះខ្ញុំគិតពីប្តីមានចំនួន៩០០បាត។ ក្រោយមកខ្ញុំ និងប្តីបានវិលត្រឡប់មករស់នៅក្នុងស្រុកកំណើតរបស់ខ្ញុំវិញ គឺនៅភូមិកណ្តោល ឃុំគោករមៀត ស្រុកថ្មពួក ខេត្តបន្ទាយមានជ័យ។ ខ្ញុំរស់នៅស្រុកកំណើតបានរយៈពេល៣ខែក៏ផ្លាស់ទៅរស់នៅស្រុកកំណើតប្តីនៅភូមិអូរមុនីឃុំអន្លង់វិល ស្រុកសង្កែ ខេត្តបាត់ដំបង។ ខ្ញុំរស់នៅភូមិអូរមុនីបានរយៈពេលមួយឆ្នាំ ទើបត្រឡប់មករស់នៅភូមិកណ្តោល ឃុំគោករមៀតវិញ។

ខ្ញុំ និងប្តីមានកូនសរុបចំនួន៤នាក់ គឺស្រី២នាក់ និងប្រុស២នាក់ ដែលក្នុងនោះមានកូនបង្កើតចំនួន៣នាក់ និងកូនចិញ្ចឹមម្នាក់អាយុ១៨ឆ្នាំ។ ទោះបីជាជីវិតកាលពីអតីតកាលឆ្លងកាត់ការលំបាក ប៉ុន្តែខ្ញុំមានសុភមង្គលជាមួយក្រុមគ្រួសារ និងកូនៗទាំង៤នាក់។ សព្វថ្ងៃខ្ញុំប្រកបរបរបិតស្រា និងចិញ្ចឹមជ្រូក។

អំឡុងពេលទាហានថៃវាយប្រហារលើកម្ពុជាលើកទីមួយ ក្រុមគ្រួសារខ្ញុំមិនបានរត់ភៀសខ្លួនទេ។ ខ្ញុំរស់នៅផ្ទះ និងឮស្នូរគ្រាប់ផ្លោងល្វើយៗពីចម្ងាយ។ អំឡុងពេលផ្ទុះអាវុធលើកទី២ នៅថ្ងៃទី៨ ខែធ្នូ ឆ្នាំ ២០២៥ ខ្ញុំនិងកូន៤នាក់ បានភៀសខ្លួនទៅរស់នៅផ្ទះជន្ទង ដែលត្រូវជាឪពុកម្ដាយក្មេកកូនប្រុសខ្ញុំ នៅភូមិតាអុង ឃុំប៉ោយចារ ស្រុកភ្នំស្រុក ខេត្តបន្ទាយមានជ័យ។ ចំណែកប្ដីខ្ញុំមិនបានទៅជាមួយខ្ញុំទេ ពីព្រោះត្រូវនៅមើលថែផ្ទះសម្បែង និងដាក់បាយឱ្យជ្រូកស៊ី។

នៅព្រឹកថ្ងៃទី១០ ខែធ្នូ ឆ្នាំ២០២៥ ខ្ញុំបានទូរសព្ទប្រាប់ប្ដីខ្ញុំថា នៅព្រឹកស្អែកថ្ងៃទី១១ ខែធ្នូ ឆ្នាំ២០២៥ ខ្ញុំនឹងឡើងទៅផ្ទះជួយកើបស្រូវដែលហាលថ្ងៃរួចដាក់ក្នុងជង្រុក និងដាក់បាយជ្រូក រួចហើយយើងធ្វើដំណើរត្រឡប់មកស្នាក់នៅផ្ទះជន្ទងក្នុងភូមិតាអុង ឃុំប៉ោយចារ ស្រុកភ្នំស្រុក ទាំងអស់គ្នា។ ប៉ុន្តែនៅយប់ថ្ងៃទី១០ ខែធ្នូ ឆ្នាំ២០២៥ ភ្លើងអគ្គិសនី និងអ៊ីនធឺណែតត្រូវបានកាត់ផ្ដាច់ទាំងអស់ ធ្វើឱ្យខ្ញុំមិនអាចទាក់ទងប្ដីបានឡើយ ដោយសារទូរសព្ទគាត់អស់ថ្ម។

នៅវេលាម៉ោង៩ព្រឹក ថ្ងៃទី១១ ខែធ្នូ ឆ្នាំ២០២៥ ខណៈពេលខ្ញុំជិះម៉ូតូមកដល់វត្តកណ្ដោល អ្នកភូមិបានប្រាប់ថា មីងកុំទៅ ព្រោះមានគ្រាប់ផ្លោងធ្លាក់មកច្រើនណាស់។ នៅវេលាម៉ោងប្រហែល១០ព្រឹក អ្នកភូមិកណ្ដោល ទូរសព្ទប្រាប់កូនប្រុសខ្ញុំឈ្មោះ ម៉ី ថា «ពុកឯងត្រូវគ្រាប់ហើយ»។ ពេលកូនខ្ញុំទៅដល់ ប្ដីខ្ញុំបានស្លាប់បាត់ទៅហើយ។ ហេតុការណ៍នេះបានកើតឡើងនៅចុងភូមិកណ្ដោល នៅខណៈដែលប្ដីខ្ញុំកំពុងយកកន្ទក់ទៅឱ្យជ្រូកមិត្តភក្តិរបស់គាត់ស៊ី ស្រាប់តែអំបែងគ្រាប់ខ្ទាតមកត្រូវចំស្លាបប្រចៀវគាត់តែម្ដង។ ពិធីបុណ្យសពប្ដីខ្ញុំធ្វើឡើងនៅវត្តភូមិថ្មី ឃុំភូមិថ្មី ដោយមានព្រះសង្ឃចំនួន៣អង្គ សូត្រមន្តបង្សុកូល។ នៅវេលាម៉ោង៥ល្ងាច ខ្ញុំមិនបានទៅរើសធាតុប្ដីខ្ញុំដោយផ្ទាល់ទេ គឺព្រះសង្ឃជាអ្នករើស និងរក្សាទុកឱ្យ ពីព្រោះខ្ញុំត្រូវប្រញាប់ភៀសខ្លួនត្រឡប់ទៅផ្ទះជន្ទងវិញ។

នៅថ្ងៃទី១៨ ខែមករា ឆ្នាំ២០២៦ ទើបខ្ញុំត្រឡប់មកធ្វើបុណ្យគម្រប់ខួប៧ថ្ងៃឧទ្ទិសដល់ប្ដីខ្ញុំនៅវត្តភូមិថ្មីដដែល ដោយមានកូនចៅ និងជន្ទងមកចូលរួម។ នៅថ្ងៃទី១ ខែកុម្ភៈ ឆ្នាំ២០២៦ ខ្ញុំបានវិលត្រឡប់មកផ្ទះវិញ និងបានយកធាតុប្ដីរបស់ខ្ញុំមករក្សាទុក។

តាំងពីប្ដីខ្ញុំស្លាប់ ខ្ញុំធ្វើអ្វីក៏មិនសមបំណងដែរ ព្រោះនៅពេលចង់ទៅណាមកណា គឺគ្មានអ្នកជូនឡើយ។ ខ្ញុំមានអនុស្សាវរីយ៍យ៉ាងច្រើនជាមួយប្ដីខ្ញុំ ជាពិសេសពេលខ្ញុំសម្រាលកូន និងពេលឈឺថ្កាត់ម្ដងៗ ប្ដីរបស់ខ្ញុំតែងតែនៅមើលថែ និងបោកខោអាវឱ្យគ្រប់សព្វ។ សូម្បីតែចៅៗក៏ត្អូញត្អែរថា អស់ពីតាទៅ គ្មានអ្នកណានាំចៅទៅដាក់បាយជ្រូក និងដឹកចៅដើរលេងតាមស្រែចម្ការទេ។

បំណងប្រាថ្នារបស់ប្ដីខ្ញុំពេលនៅរស់ គឺធ្លាប់និយាយប្រាប់ខ្ញុំថាចង់សាងសង់ផ្ទះមួយឱ្យកូនចិញ្ចឹម និងរស់នៅជាមួយកូនចិញ្ចឹមនៅពេលខ្ញុំ និងគាត់ចាស់ជរា ប៉ុន្តែពេលនេះប្ដីខ្ញុំបានស្លាប់ហើយ។ ខ្ញុំសូមបួងសួងឱ្យស្រុកទេសមានសុខសន្តិភាព ឈប់មានសង្គ្រាម ដើម្បីឱ្យប្រជាជនបានរស់នៅជួបជុំគ្នា។



វ៉ាន់ វីរៈ ត្រូវជាប្ដីរបស់ សំអែត មានស្រុកកំណើតនៅភូមិអូរមុនី ឃុំអន្លង់វិល ស្រុកសង្កែ ខេត្តបាត់ដំបង បានស្លាប់ដោយសារត្រូវអំបែងគ្រាប់របស់កងទ័ពថៃនៅផ្ទះ ស្ថិតនៅភូមិកណ្ដោល ឃុំគោករមៀត ស្រុកថ្មពួក ខេត្តបន្ទាយមានជ័យ។ (បណ្ណសារមជ្ឈមណ្ឌលឯកសារកម្ពុជា)

# រដ្ឋបាលស្រុកបុរីអូរស្វាយ-សែនជ័យ
## បើកផ្លូវថ្មើរជើងថ្មីតាមមាត់ទន្លេ ដើម្បីលើកកម្ពស់សោភ័ណភាព និងវិស័យទេសចរណ៍

**ស្រេង លីដា**



*អគារមរតកសង្គមរាស្ត្រនិយម សម្តេចឪ សម្តេចម៉ែ (បុរីអូរស្វាយ-សែនជ័យ) ស្ថិតនៅជាប់មាត់ទន្លេមេគង្គ ក្នុងភូមិអូរស្វាយ ឃុំអូរស្វាយ ស្រុកបុរីអូរស្វាយសែនជ័យ ខេត្តស្ទឹងត្រែង ។ (បណ្ណសារមជ្ឈមណ្ឌលឯកសារកម្ពុជា)*

នៅថ្ងៃទី២ ខែមីនា ឆ្នាំ២០២៦ លោក ផាន់យុត អភិបាលនៃគណៈភិបាលស្រុកបុរីអូរស្វាយសែនជ័យ បានដឹកនាំកងកម្លាំងចម្រុះ ចុះអនុវត្តសកម្មភាពបើកផ្លូវថ្មើរជើងថ្មីមួយខ្សែ ស្ថិតនៅតាមបណ្ដោយមាត់ទន្លេមេគង្គ ក្នុងភូមិសាស្ត្រភូមិអូរស្វាយ ឃុំអូរស្វាយ ស្រុកបុរីអូរស្វាយសែនជ័យ ខេត្តស្ទឹងត្រែង ដើម្បីបម្រើដល់ផលប្រយោជន៍សាធារណៈ និងទាក់ទាញភ្ញៀវទេសចរ។

ផ្លូវថ្មើរជើងដែលទើបនឹងស្ថាបនារួចនេះ មានលក្ខណៈបច្ចេកទេសដូចខាងក្រោម៖

ទំហំ៖ ទទឹងប្រមាណ ៣ ម៉ែត្រ និងបណ្ដោយសរុប ៥៧០ ម៉ែត្រ។

ទីតាំង៖ ចាប់ផ្ដើមពីចំណុចអគារមរតកសង្គមរាស្ត្រនិយមសម្តេចឪ សម្តេចម៉ែ (បុរីអូរស្វាយ-សែនជ័យ) រហូតដល់ ស្នាក់ការបរិស្ថាន (វ៉ាមសារ) ដែលស្ថិតនៅទល់មុខសាលាបឋមសិក្សា ព្រះនរោត្តម សីហនុរាជា និងសម្តេចព្រះវររាជមាតា នរោត្តម មុនិនាថ សីហនុ អូរស្វាយ។



ស្តូបអនុស្សាវរីយ៍សម្តេចព្រះ នរោត្តម សីហនុ ព្រះបរមរតនកោដ្ឋ ស្ថិតនៅជាប់មាត់ទន្លេមេគង្គ ក្នុងភូមិអូរស្វាយ ឃុំអូរស្វាយ ស្រុកបុរីអូរស្វាយសែនជ័យ ខេត្តស្ទឹងត្រែង ។ (បណ្ណសារមជ្ឈមណ្ឌលឯកសារកម្ពុជា)

ផ្លូវថ្មើរជើងនេះ ចូលរួមសិក្សាឧបត្ថម្ភដោយមជ្ឈមណ្ឌលឯកសារកម្ពុជា ដែលមានកិច្ចសហការជាមួយរដ្ឋបាលស្រុកបុរីអូរស្វាយ-សែនជ័យ និងរដ្ឋបាលខេត្តស្ទឹងត្រែងដើម្បីបម្រើដល់ប្រយោជន៍ប្រជាជននៅក្នុងសហគមន៍។

មជ្ឈមណ្ឌលឯកសារកម្ពុជាបានសាងសង់អគារមរតកសង្គមរាស្ត្រនិយម សម្តេចឪ សម្តេចម៉ែ (បុរីអូរស្វាយ-សែនជ័យ) ក្នុងភូមិអូរស្វាយ ដែលជាអតីតព្រះរាជដំណាក់តូចមួយរបស់សម្តេចព្រះ នរោត្តម សីហនុ (ព្រះបរមរតនកោដ្ឋ) ពេលដែលព្រះអង្គយាងទៅកាន់ស្រុកបុរីអូរស្វាយ នៅក្នុងឆ្នាំ១៩៦៤ ធ្វើជាបណ្ណាល័យ, សាងសង់កំពង់ផែបណ្តែតទឹក, សាងសង់ទូកជាច្រើនគ្រឿង សម្រាប់ប្រើប្រាស់ជាសាធារណៈ។ អគារមរតកសង្គមរាស្ត្រនិយម សម្តេចឪ សម្តេចម៉ែ (បុរីអូរស្វាយ-សែនជ័យ) រួមបញ្ចូលសកម្មភាពជាច្រើនរួមមានការស្រាវជ្រាវប្រវត្តិសាស្ត្រ



លោក ផាន់ យុត អភិបាលនៃគណៈភិបាលស្រុកបុរីអូរស្វាយសែនជ័យ (រូបកណ្តាល) ដឹកនាំកងកម្លាំងចម្រុះ ចុះពិនិត្យផ្លូវថ្មើរជើងថ្មី ស្ថិតនៅតាមបណ្តោយមាត់ទន្លេមេគង្គ ក្នុងភូមិសាស្ត្រភូមិអូរស្វាយ ឃុំអូរស្វាយ ស្រុកបុរីអូរស្វាយសែនជ័យ ខេត្តស្ទឹងត្រែង ។ (បណ្ណសារមជ្ឈមណ្ឌលឯកសារកម្ពុជា)

របស់សហគមន៍ សិល្បៈ ចម្លាក់ និងការកែលម្អសហគមន៍នៅជុំវិញ។

អគារមរតកសង្គមរាស្ត្រនិយមសម្តេចឪ សម្តេចម៉ែ (បុរីអូរស្វាយ-សែនជ័យ) មានតម្កល់ឯកសារប្រវត្តិ-សាស្ត្រ ទាក់ទងនឹងរបបខ្មែរក្រហម, រាជវង្សានុវង្ស និងឯកសារសម្ព័យជាច្រើនបម្រើដល់សិស្ស និស្សិត អ្នកសិក្សាស្រាវជ្រាវជាតិ និងអន្តរជាតិ ជាពិសេសប្រជាជននៅក្នុងសហគមន៍។

# «ស្លាបត្រកម្មបណ្ណាល័យហ្លួងម៉ែ»

## របស់មជ្ឈមណ្ឌលឯកសារកម្ពុជាទទួលបានជ័យលាភីលេខ១ ក្នុងការប្រកួតប្រជែងស្នាដៃស្លាបត្រកម្ម «ពោធិចិនតុងកើតឡើងវិញ ការបម្លែងអាកាសយានដ្ឋានចាស់ភ្នំពេញឱ្យក្លាយទៅជាទីក្រុងអេប៉ុង»

**សោម ប៊ុនថន**



ស្ថាបត្យករវ័យក្មេងរបស់ព្រះរាជបណ្ណាល័យ ហ្លួងម៉ែ នៃមជ្ឈមណ្ឌលឯកសារកម្ពុជា ធ្វើបទបង្ហាញអំពីគម្រោង ៖ «ការផ្លាស់ប្តូរទីតាំងប្រវត្តិសាស្ត្រដ៏រឹងមាំមួយរបស់កម្ពុជា តាមរយៈវិសុកម្មហេដ្ឋារចនាសម្ព័ន្ធបៃតង» ដល់គណៈកម្មាធិការដាក់ពិន្ទុ។ (បណ្ណសារមជ្ឈមណ្ឌលឯកសារកម្ពុជា)

គណៈកម្មាធិការដាក់ពិន្ទុក្នុងការប្រកួតប្រជែងបានវាយតម្លៃលើគម្រោងរបស់បេក្ខភាពទាំង២៥០ក្រុម ដែលមានស្ថាបត្យករវ័យក្មេងចំនួន៨៥០រូប ឆ្លងកាត់ការជម្រុះ៣វគ្គ គឺវគ្គ៤៥ក្រុម និងវគ្គ១០ក្រុមកន្លងមក ហើយទីបំផុតនៅថ្ងៃទី៩ ខែមីនា ឆ្នាំ២០២៦ គណៈកម្មាធិការបានប្រកាសជ័យលាភីក្នុងការប្រកួតប្រជែងស្នាដៃស្ថាបត្យកម្ម «ពោធិចិនតុងកើតឡើងវិញ ការបម្លែងអាកាសយានដ្ឋានភ្នំពេញចាស់ឱ្យក្លាយទៅជាទីក្រុងអេប៉ុង»។ ក្នុងចំណោមជ័យលាភីបីក្រុមចុងក្រោយពីលេខ១ដល់លេខ៣ ដែល



គណៈកម្មាធិការដាក់ពិន្ទុក្នុងការប្រកួតប្រជែងស្នាដៃស្ថាបត្យកម្ម «ពោធិចិនតុងកើតឡើងវិញ ការបម្លែងអាកាសយានដ្ឋានភ្នំពេញចាស់ឱ្យក្លាយទៅជាទីក្រុងអេប៉ុង» វគ្គប្រកាសលទ្ធផលចុងក្រោយ នៅថ្ងៃទី៩ ខែមីនា ឆ្នាំ២០២៦។ (បណ្ណសារមជ្ឈមណ្ឌលឯកសារកម្ពុជា)

គណៈកម្មាធិការដាក់ពិន្ទុក្នុងការប្រកួតប្រជែងប្រកាសនៅថ្ងៃនេះ គឺមានលេខ១១សួនពីរក្រុម ហើយក្នុងចំណោមនោះមានក្រុម «ស្ថាបត្យកម្មបណ្ណាល័យ ហ្វូងម៉ែ» របស់មជ្ឈមណ្ឌលឯកសារកម្ពុជា ដឹកនាំដោយលោក ទិត្យ សត្យាវង្ស, កញ្ញា លាង ចន្ទី, កញ្ញា លឹម វណ្ណសូលីហ្សា និងលោក វន រ័ត្នវិសាល។ ក្រុមការងារបានជ្រើសរើសគម្រោង៖ «ការផ្លាស់ប្តូរទីតាំងប្រវត្តិសាស្ត្រដ៏រឹងមាំមួយរបស់កម្ពុជា តាមរយៈវិស្វកម្មហេដ្ឋារចនាសម្ព័ន្ធបៃតង» ដើម្បីចូលរួមប្រកួតប្រជែង។

គម្រោងនេះ គឺជាគំនិតផ្តួចផ្តើមមួយដើម្បីផ្លាស់ប្តូរអតីតអាកាសយានដ្ឋានអន្តរជាតិពោធិ៍ចិនតុងទៅជាសួនច្បារទីក្រុងអេប៉ុង។ គម្រោងនេះអនុវត្តគោលការណ៍ស្នូលនៃការរចនាទីក្រុងដែលងាយរងគ្រោះដោយជំនន់ទឹកភ្លៀង ដែលត្រូវបានគេហៅថាជាគំរូ «ទីក្រុងអេប៉ុង» ដោយអនុញ្ញាតឱ្យទេសភាពស្រូបយករក្សាទុក ត្រង និងបញ្ចេញទឹកភ្លៀងដោយធម្មជាតិ។ អតីតអាកាសយានដ្ឋាននឹងក្លាយជាផ្លូវដើរដែលអាចជ្រាបទឹកបានជាមួយនឹងប្រករបៀងបៃតងដែលទឹកភ្លៀងជ្រាបចូលតាមរយៈផ្លូវជីវសាស្ត្រសួនច្បារទឹកភ្លៀង និងផ្លូវក្រាលកៅស៊ូ។ ផ្នែកធំនៃតំបន់អាកាសយានដ្ឋាននឹងត្រូវបានផ្លាស់ប្តូរទៅជាតំបន់សើម បឹងស្តុកទឹក និងតំបន់ទំនាបលិចទឹកដែលអាចកាត់បន្ថយទឹកភ្លៀង ខណៈពេលដែលតំបន់នេះគាំទ្រដល់ជីវចម្រុះ និងសត្វព្រៃដែរ។ គម្រោងនេះ នឹងបង្កើនជីវចម្រុះដល់ទីក្រុង និងកែលម្អបញ្ហាបរិស្ថាន និងសង្គម ដូចជា ការកាត់បន្ថយកម្រិតនៃការបំពុលបរិស្ថាន និងការបង្កើតកន្លែងកម្សាន្ត និងលើកទឹកចិត្តដល់ការផ្លាស់ប្តូររវាងមនុស្សជំនាន់មុនទៅកាន់មនុស្សជំនាន់ក្រោយ។ ផែនការមេរបស់គម្រោងគឺ៖ «រង្វង់បៃតង» តាមដានបរិវេណនៃអាកាសយានដ្ឋានចាស់ដោយភ្ជាប់ព្រៃឈើថ្មីវាលស្មៅ និងផ្លូវកម្សាន្ត។ «ឆ្អឹងខ្នងពណ៌ខៀវ» ពង្រីកប្រព័ន្ធគ្រប់គ្រងទឹកនៃផ្លូវរត់កណ្តាលដែលមានស្រាប់ទៅជាច្រករបៀងទឹកជាមួយនឹងស្រះទឹកតាមរដូវកាល និងទីលានសាធារណៈដែលបង្ហូរទឹកជំនន់ដោយសុវត្ថិភាពក្នុងអំឡុងពេលមានភ្លៀងធ្លាក់ខ្លាំង។ «ចំណុចប្រសព្វ» ត្រូវបានរចនាឡើងដើម្បីស្រូបយករក្សាទុក ត្រង និងបញ្ចេញទឹកភ្លៀងយឺតៗដោយរួមបញ្ចូលជាមួយផ្លូវដើរដែលអាចជ្រាបទឹកបាន តំបន់សើមសហគមន៍ ពន្លាវប្បធម៌កសិដ្ឋានទីក្រុង និងទេសភាពអប់រំដែលបង្ហាញពីវដ្តទឹកយ៉ាងសកម្មភាព។




ស្ថាបត្យករវ័យក្មេងរបស់ព្រះរាជបណ្ណាល័យ ហ្វូងម៉ែ នៃមជ្ឈមណ្ឌលឯកសារកម្ពុជា ធ្វើបទបង្ហាញអំពីគម្រោង៖ «ការផ្លាស់ប្តូរទីតាំងប្រវត្តិសាស្ត្រដ៏រឹងមាំមួយរបស់កម្ពុជា តាមរយៈវិស្វកម្មហេដ្ឋារចនាសម្ព័ន្ធបៃតង» ដល់គណៈកម្មាធិការដាក់ពិន្ទុ។ (បណ្ណសារមជ្ឈមណ្ឌលឯកសារកម្ពុជា)

ការបង្កើតឡើងវិញនៃអាកាសយានដ្ឋានពោធិ៍ចិនតុងគឺច្រើនជាងការអភិវឌ្ឍន៍ប្រព័ន្ធជលសាស្ត្រទំនើបដែលគាំទ្រដល់បរិស្ថានក្នុងស្រុក និងសហគមន៍ទីក្រុង/ជនបទ។ គម្រោងនេះគឺជាគំនិតរចនាទីក្រុងដែលផ្តោតលើប្រជាជន ដែលនឹងកំណត់ស្តង់ដារសម្រាប់គម្រោងអភិវឌ្ឍន៍នាពេលអនាគត។ គំនិតនៃតំបន់បៃតងដែលមានស្រមោលនឹងកាត់បន្ថយកម្តៅទីក្រុង ខណៈពេលដែលបើកកន្លែងសាធារណៈ កន្លែងកម្សាន្តទីលានកីឡា និងសួនច្បារវប្បធម៌សម្រាប់ការប្រើប្រាស់ជាសាធារណៈពេញមួយឆ្នាំ។ គម្រោងនេះនឹងជួយបំពេញតម្រូវការនៃការអភិវឌ្ឍន៍ទីក្រុងនាពេលអនាគតប្រកបដោយចីរភាពជាមួយនឹងសារៈសំខាន់នៃភាពធន់នឹងអាកាសធាតុ ការអភិរក្សជីវៈចម្រុះ និងបេតិកភណ្ឌពិសិដ្ឋរបស់ប្រទេសកម្ពុជា។ ប្រទេសកម្ពុជាអាចកំណត់ស្តង់ដារសម្រាប់ការអភិវឌ្ឍន៍ទីក្រុងប្រកបដោយចីរភាព ដោយការផ្លាស់ប្តូរទីតាំងប្រវត្តិសាស្ត្រមួយនៅក្នុងការរចនាទីក្រុងដែលងាយរងគ្រោះដោយទឹកជំនន់ ដែលមិនត្រឹមតែគាំទ្រដល់រាជធានី និងសហគមន៍ក្នុងតំបន់តែប៉ុណ្ណោះទេ ប៉ុន្តែថែមទាំងបរិស្ថាន និងបេតិកភណ្ឌរបស់ប្រទេសសម្រាប់មនុស្សជំនាន់ក្រោយទៀតផង។ នៅក្នុងគម្រោងនេះគឺមានរួមបញ្ចូលអគារប្រវត្តិសាស្ត្រ ព្រះរាជបណ្ណាល័យ ហ្វូងម៉ែ, ទីតាំងរំឭកវិញ្ញាណក្ខន្ធវីរកងទ័ពកម្ពុជាដែលបានពលីនៅក្នុងបុព្វហេតុការពារបូរណភាពទឹកដីពីការឈ្លានពានរបស់កងទ័ពថៃ, សាលពិព័រណ៍រូបថតមេដឹកនាំពិភពលោកដែលបានធ្វើដំណើរមកដល់ព្រលានយន្តហោះពោធិ៍ចិនតុង និងមជ្ឈមណ្ឌលភស្តុភារកម្ម។

បន្ទាប់ពីទទួលបានជ័យលាភីលេខ១ ក្រុម «ស្ថាបត្យកម្មបណ្ណាល័យ ហ្វូងម៉ែ» របស់មជ្ឈមណ្ឌលឯកសារកម្ពុជា នឹងធ្វើបទបង្ហាញនៅក្រសួងដែនដី នគរូបនីយកម្ម និងសំណង់ បន្តទៀត។ នៅក្នុងពេលជាមួយគ្នានេះដែរ ក្រុម «ស្ថាបត្យកម្មបណ្ណាល័យ ហ្វូងម៉ែ» របស់មជ្ឈមណ្ឌលឯកសារកម្ពុជា កំពុងសិក្សាប្លង់សាងសង់ព្រះរាជសារមន្ទីរ នៅខេត្តស្ទឹងត្រែង ជាប់ព្រំដែនឡាវ ដែលជាកេរដំណែលរបស់សម្តេចព្រះនរោត្តម សីហនុ ព្រះបរមរតនកោដ្ឋ។



ការបង្ហាញគម្រោងរបស់ក្រុមស្ថាបត្យករវ័យក្មេងដែលជាប់ក្នុងវគ្គជម្រុះចុងក្រោយ។
(បណ្ណសារមជ្ឈមណ្ឌលឯកសារកម្ពុជា)



ព្រលានយន្តហោះពោធិ៍ចិនតុង ក្នុងសម័យសង្គមរាស្ត្រនិយម។
(បណ្ណសារមជ្ឈមណ្ឌលឯកសារកម្ពុជា)

# សិស្សានុសិស្សថ្នាក់ទី៩ នៃវិទ្យាល័យ ហ៊ុន សែន ប្រម៉ោយ មកទស្សនាខ្សែភាពយន្ត

## ឯកសារ «កុំស្មានបងភ្លេច» នៅមជ្ឈមណ្ឌលផ្សះផ្សាវាលវែង

**ចាន់ ណារិទ្ធ**



សិស្សចំនួន៨នាក់នៃវិទ្យាល័យ ហ៊ុន សែន ប្រម៉ោយ មកទស្សនាខ្សែភាពយន្តឯកសារមានចំណងជើង «កុំស្មានបងភ្លេច» នៅមជ្ឈមណ្ឌលផ្សះផ្សាវាលវែង បន្ទាប់ពីទំនេរពីម៉ោងសិក្សានៅក្នុងថ្នាក់ នៅព្រឹកថ្ងៃទី១៩ ខែមីនា ឆ្នាំ២០២៦។ (បណ្ណសារមជ្ឈមណ្ឌលឯកសារកម្ពុជា)

នៅព្រឹកម៉ោង៩ ថ្ងៃទី១៩ ខែមីនា ឆ្នាំ២០២៦ សិស្សចំនួន៨នាក់ មកពីវិទ្យាល័យ ហ៊ុនសែន ប្រម៉ោយ ស្នើមជ្ឈមណ្ឌលផ្សះផ្សាវាលវែងចាក់បញ្ចាំងខ្សែភាពយន្តឯកសារ មានចំណងជើង «កុំស្មានបងភ្លេច» ដើម្បីទស្សនា បន្ទាប់ពីទំនេរពីម៉ោងសិក្សានៅក្នុងថ្នាក់។

ក្រុមការងារមជ្ឈមណ្ឌលផ្សះផ្សាវាលវែងបានយល់ព្រមទៅតាមសំណើខាងលើ ពីព្រោះ ទី១) ចង់ឱ្យសិស្សានុសិស្សបានយល់ដឹងអំពីការបាត់បង់តន្ត្រី និងអ្នកសិល្បៈច្រើនទម្រង់ក្នុងរបបកម្ពុជាប្រជាធិបតេយ្យ (១៩៧៥-១៩៧៩) ទី២) ចង់ឱ្យសិស្សានុសិស្សស្វែងយល់អំពីសម័យកាលនីមួយៗនៅក្នុងខ្សែភាពយន្ត«កុំស្មានបងភ្លេច» ទី៣) ចង់ឱ្យសិស្សានុសិស្សបានដឹងអំពីផលលំបាកនៃការកើតមានសង្គ្រាម និងទី៤) ការដោះស្រាយបញ្ហាដោយសន្តិវិធី និងការទប់ស្កាត់ជម្លោះនានា។

ក្រោយទស្សនាខ្សែភាពយន្តឯកសាររឿង «កុំស្មានបងភ្លេច» ចប់ ក្រុមការងាររបស់មជ្ឈមណ្ឌលផ្សះផ្សាវាលវែង បានពិភាក្សាពីព្រឹត្តិការណ៍ប្រវត្តិសាស្ត្រ និងរឿងរ៉ាវរបស់សិល្បករ តន្ត្រី នៅក្នុងខ្សែ

ភាពយន្តនេះ ជាមួយសិស្សានុសិស្ស ហើយចុងក្រោយ សិស្សបង្ហាញចំណាប់អារម្មណ៍ដូចខាងក្រោម៖

សិស្សឈ្មោះ សែ ម៉េងហាក់ រៀនថ្នាក់ទី៩ រៀបរាប់ថា «ខ្ញុំបានដឹងពីការរស់នៅ និងភាពរុងរឿងរបស់ប្រទេសកម្ពុជាក្នុងសម័យសង្គមរាស្ត្រនិយម ហើយខ្ញុំបានស្គាល់អ្នកចម្រៀង និងស្តាប់បទចម្រៀងជាច្រើននៅក្នុងខ្សែភាពយន្តឯកសារ «កុំស្មានបងភ្លេច»។ ខ្ញុំបានចាប់អារម្មណ៍រឿងរ៉ាវក្នុងរបបខ្មែរក្រហម ដែលបានជះឥទ្ធិពលអាក្រក់ទៅលើប្រជាជនខ្មែរ និងសិល្បករ។ ប្រជាជនត្រូវទទួលរងទុក្ខលំបាក ត្រូវធ្វើការងារមិនមានពេលវេលាសម្រាក និងគ្មានអាហារហូបចុកគ្រប់គ្រាន់។

រីឯ សាយ សុខហេង បានចងចាំបន្ទាប់ពីទស្សនាខ្សែភាពយន្តកុំស្មានបងភ្លេចរួចមក «ខ្ញុំឃើញការបែងចែកសាច់រឿងជា៣សម័យកាលផ្សេងៗគ្នា គឺទី១) នៅសម័យសង្គមរាស្ត្រនិយមខ្ញុំបានឃើញពីភាពរីកចម្រើននៃវិស័យចម្រៀង និងតន្ត្រីរីក ទី២) នៅសម័យសាធារណរដ្ឋខ្មែរ មានការប្រយុទ្ធគ្នា ការបាញ់ផ្លោងដាក់គ្នា និងមានយន្តហោះមកទម្លាក់គ្រាប់បែកយ៉ាងច្រើនសន្ធឹកសន្ធាប់នៅតាមព្រៃ និងនៅក្នុងភូមិឋានប្រជាពលរដ្ឋ ដែលបណ្តាលឱ្យប្រជាជនត្រូវរងរបួស និងស្លាប់ និងទី៣) នៅក្នុងរបបកម្ពុជាប្រជាធិបតេយ្យ(១៩៧៥-១៩៧៩) ឬរបបខ្មែរក្រហម ខ្ញុំបានឃើញពីទុក្ខលំបាក ការធ្វើបាបប្រជាជន និងការធ្វើទារុណកម្មទៅលើប្រជាជន»។

កង ម៉េងគាង បានចែករំលែកថា «ក្រោយពីខ្ញុំបានទស្សនាខ្សែភាពយន្តឯកសារ«កុំស្មានបងភ្លេច» ខ្ញុំសង្កេតឃើញ ប្រជាជនកម្ពុជាសម័យនោះកម្សាន្តរីករាយជាមួយបទចម្រៀង និងក្បាច់រាំប្លែកៗ។ ប្រទេសកម្ពុជាមានការរីកចម្រើនគ្រប់វិស័យ។ បន្ទាប់ពីមានការរីកចម្រើន ប្រទេសកម្ពុជាបានធ្លាក់ចូលក្នុងសង្គ្រាមស៊ីវិល ដែលធ្វើឱ្យប្រជាជនរស់ក្នុងភាពភ័យខ្លាច។ នៅពេលកងទ័ពខ្មែរក្រហមទទួលបានជ័យជម្នះទៅលើរបប លន់ នល់ អ្នកចម្រៀងល្បីៗ និងក្រុមភ្លេងជាច្រើនត្រូវបានជម្លៀសទៅតាមទីជនបទ ដើម្បីធ្វើការងារពលកម្ម ហើយខ្លះទៀតត្រូវបានចាប់យកទៅសម្លាប់»។

យុវតី ផេង ដាវ៉ែឡន យល់ឃើញថា «ខ្ញុំសង្កេតឃើញខ្សែភាពយន្តនេះបង្ហាញសម័យកាលផ្សេងៗគ្នា គឺទាំងភាពសប្បាយរីករាយ និងទុក្ខក្រៀមក្រំ។ នៅក្នុងសម័យកាលសម្តេចព្រះ នរោត្តម សីហនុគ្រប់គ្រងអំណាច ខ្ញុំឃើញមានការរីកចម្រើនគ្រប់វិស័យពិសេសលើវិស័យតន្ត្រី។ បន្ទាប់ពីមានការរីកចម្រើនគឺចាប់ផ្តើមមានសង្គ្រាមនៅក្នុងប្រទេសកម្ពុជា។ នៅពេលនោះក្រុមតន្ត្រីជាច្រើនត្រូវបានបញ្ឈប់ឱ្យលេងតន្ត្រីបន្ទាប់មកខ្មែរក្រហមបង្ខំឱ្យទៅធ្វើការងារនៅតាមការដ្ឋានផ្សេងៗ»។

ជាចុងបញ្ចប់នៃកិច្ចពិភាក្សា យុវតី គឿន ស៊ីលីញ លើកឡើងថា «នៅក្នុងខ្សែភាពយន្តឯកសារនេះ បង្កប់រឿងរ៉ាវជាច្រើន ដូចជា តន្ត្រី សង្គ្រាម ការធ្វើទារុណកម្ម និងការបាត់បង់ជីវិតសិល្បករ។ នៅក្នុងរបបខ្មែរក្រហម ប្រជាជនកម្ពុជារស់នៅក្រោមការគាបសង្កត់ លំបាកវេទនា និងការកាប់សម្លាប់។ នៅពេលអនាគត ខ្ញុំចង់ឃើញប្រជាជនរស់នៅក្នុងសុខសន្តិភាព។



សិស្សចំនួន៨នាក់នៃវិទ្យាល័យ ហ៊ុន សែន ប្រម៉ោយ មកទស្សនាខ្សែភាពយន្តឯកសារមានចំណងជើង «កុំស្មានបងភ្លេច» នៅមជ្ឈមណ្ឌលផ្សះផ្សាវាលវែង បន្ទាប់ពីទំនេរពីម៉ោងសិក្សានៅក្នុងថ្នាក់ នៅព្រឹកថ្ងៃទី១៩ ខែមីនា ឆ្នាំ២០២៦។ (បណ្ណសារមជ្ឈមណ្ឌលឯកសារកម្ពុជា)

# ម្នាស់ទឹកឃ្មុំ នៅអគារមរតកសង្គមរាស្ត្រនិយម សម្តេចឪ-សម្តេចម៉ែ

## (បុរីអូរស្វាយ-សែនជ័យ) នៃព្រះរាជបណ្ណាល័យហ្លួងម៉ែ

ស៊ាង ចិន្តា



ម្នាស់ទឹកឃ្មុំនៅខេត្តកំពតនៅសម័យសង្គមរាស្ត្រនិយម។ (បណ្ណសារមជ្ឈមណ្ឌលឯកសារកម្ពុជា)

ដំណាំម្នាស់នៅប្រទេសកម្ពុជាគឺជាផលិតផលសក្តានុពលសម្រាប់កសិឧស្សាហកម្មកែច្នៃនិងសេដ្ឋកិច្ចរបស់កម្ពុជា។ ប្រទេសកម្ពុជាមានអាកាសធាតុត្រូពិច (ក្តៅសើម) និងដីសម្បូរជីវជាតិដែលជាកត្តាអំណោយផលល្អប្រសើរសម្រាប់ការដាំដុះម្នាស់។ បើទោះបីជាម្នាស់អាចដាំដុះបាននៅលើដីគ្រប់ប្រភេទយ៉ាងណាក៏ដោយ ម្នាស់អាចលូតលាស់ល្អបំផុតនៅលើដីទួលដែលមានប្រព័ន្ធរំដោះទឹកល្អ ដូចជា ខេត្តស្ទឹងត្រែង។ ម្នាស់ជាច្រើនប្រភេទត្រូវបានដាំដុះនៅប្រទេសកម្ពុជា ដែលក្នុងនោះរួមមានម្នាស់ទឹកឃ្មុំ ម្នាស់ស្ករ និងម្នាស់កែវ ជាដើម។

ម្នាស់ (ឈ្មោះវិទ្យាសាស្ត្រ «Ananas comosus») គឺមិនមែនជាដំណាំកសិកម្មដែលមានដើមកំណើតនៅតំបន់អាស៊ីអាគ្នេយ៍នោះទេ ប៉ុន្តែម្នាស់បានក្លាយជាផ្នែកមួយដ៏សំខាន់នៃវិស័យកសិកម្ម វិស័យសេដ្ឋកិច្ច និងវិស័យវប្បធម៌ម្ហូបអាហាររបស់ប្រទេសកម្ពុជាអស់រយៈពេលរាប់សតវត្សរ៍មកហើយ។ ផ្អែកតាមការសិក្សាស្រាវជ្រាវផ្នែករុក្ខជាតិវិទ្យា ម្នាស់គឺមានដើមកំណើតនៅតំបន់អាមេរិកខាងត្បូង (ប្រទេសប្រេស៊ីល និងប្រទេសប៉ារ៉ាហ្គាយ)។ ម្នាស់ត្រូវបាននាំចេញពីតំបន់អាមេរិកខាងត្បូង តាមរយៈការធ្វើដំណើររបស់លោក Christopher Columbus ទៅកាន់តំបន់អឺរ៉ុប។

ក្រោយមកទៀតជនជាតិអេស្ប៉ាញ និងព័រទុយហ្គាល់ បាននាំយកម្នាស់ចូលមកកាន់តំបន់អាស៊ីនៅអំឡុងសតវត្សរ៍ទី១៦។ ប្រទេសកម្ពុជា ចាប់ផ្តើមស្គាល់និងដាំដុះម្នាស់ តាមរយៈការធ្វើពាណិជ្ជកម្មជាមួយជនជាតិអឺរ៉ុប និងចិន នៅសម័យក្រោយអង្គរ។

ម្នាស់ត្រូវបានដាំដុះជាលក្ខណៈគ្រួសារនៅតាមភូមិឋានៗ រហូតមកដល់សម័យសង្គមរាស្ត្រនិយម សម្តេចព្រះ នរោត្តម សីហនុ បានចាប់ផ្តើមកសិឧស្សាហកម្មកែច្នៃនៃដំណាំម្នាស់។ នៅឆ្នាំ១៩៦៥ សម្តេចព្រះ នរោត្តម សីហនុបានដាំដុះម្នាស់សម្រាប់ផលិតផលកសិឧស្សាហកម្មកែច្នៃ នៅស្រុកចំការលើ ខេត្តកំពង់ចាម និងខេត្តកំពត ដើម្បីផ្គត់ផ្គង់ទីផ្សារក្នុងស្រុក និងអន្តរជាតិ។ ជាក់ស្តែង ម្នាស់កម្ពុជាត្រូវបាននាំចេញទៅផ្គត់ផ្គង់ទីផ្សារនៅប្រទេសសិង្ហបុរីជាបន្តបន្ទាប់។ បន្ទាប់ពីប្រទេសកម្ពុជាធ្លាក់ចូលក្នុងសង្គ្រាមស៊ីវិល និងរបបប្រល័យពូជសាសន៍ខ្មែរក្រហម (១៩៧៥-១៩៧៩) ដំណាំម្នាស់ ស្ទើរតែបាត់បង់ប្រវត្តិនៅក្នុងវិស័យកសិកម្ម និងមិនត្រូវបានដាំដុះឡើងវិញនោះទេ ដោយហេតុថាមិនមានទីផ្សារ និងមិនមានប្រព័ន្ធកសិកម្មគ្រប់គ្រាន់។ សព្វថ្ងៃនេះ ប្រជាកសិករកម្ពុជាចាប់ផ្តើមដាំដុះម្នាស់ឡើងវិញ នៅតាមបណ្តាខេត្តនានាក្នុងប្រទេសកម្ពុជា។ ឱជារសរបស់ម្នាស់ ប្រែប្រួលពីជូរអែមទៅជាផ្អែមមុត ទៅតាមកត្តាដី និងអាកាសធាតុ។ម្នាស់មួយប្រភេទក្នុងចំណោមម្នាស់ទាំងអស់ដែលមានឱជារសគួរឱ្យកត់សម្គាល់បំផុតនោះគឺ«ម្នាស់ទឹកឃ្មុំ» ដែលដាំដុះនៅខេត្តស្ទឹងត្រែង ភាគឦសាននៃប្រទេសកម្ពុជា។

ម្នាស់ទឹកឃ្មុំនៃខេត្តស្ទឹងត្រែងត្រូវបានទទួលស្គាល់ពីលក្ខណៈសម្បត្តិពិសេសនោះគឺរសជាតិផ្អែមមុតដូចទឹកឃ្មុំ ក្លិនក្រអូប និងសាច់ពណ៌លឿងដុំៗដូចមាស។ ម្នាស់ទឹកឃ្មុំនៃខេត្តស្ទឹងត្រែង ក្លាយជាផលិតផលកសិកម្មសរីរាង្គដ៏សំខាន់មួយ ដែលត្រូវបានប្រើប្រាស់សម្រាប់ផលិតទឹកម្នាស់ ស្រាម្នាស់ មេស្រាម្នាស់សរីរាង្គ និងម្នាស់ស្ងួត ដើម្បីផ្គត់ផ្គង់នៅទីផ្សារក្នុងស្រុក និងអន្តរជាតិ។

ការបន្តដាំដុះ និងការនាំចេញម្នាស់គឺមិនត្រឹមតែជួយពង្រឹងវិស័យកសិឧស្សាហកម្មរបស់កម្ពុជាតែប៉ុណ្ណោះទេ ប៉ុន្តែថែមទាំងបង្ហាញអំពីកេរដំណែលនៃវិស័យកសិកម្មនៅសម័យសង្គមរាស្ត្រនិយម និងការវិលត្រឡប់មកវិញនៃមូលដ្ឋានគ្រឹះកសិឧស្សាហកម្មនៅប្រទេសកម្ពុជា ក្រោយពីសង្គ្រាម និងរបបប្រល័យពូជសាសន៍ខ្មែរក្រហម។ ម្នាស់កម្ពុជាគឺជាផលិតផលមួយដ៏លេចធ្លោ និងមានសក្តានុពលខ្ពស់សម្រាប់អនាគតសេដ្ឋកិច្ចរបស់ប្រទេសកម្ពុជា។



ម្នាស់ទឹកឃ្មុំនៅស្រុកចំការលើ ខេត្តកំពង់ចាមនៅសម័យសង្គមរាស្ត្រនិយម។ (បណ្ណសារមជ្ឈមណ្ឌលឯកសារកម្ពុជា)

# ជនជាតិដើមភាគតិចស្មៀងដែលមានជីវភាពខ្វះខាតនៅក្នុងភូមិក្តុលលើចូលរួមស្តាប់ការ

## ធ្វើបទបង្ហាញរបស់មន្ត្រីអំពីសារសំខាន់នៃការប្រើប្រាស់ប័ណ្ណសមធម៌ និងគម្រោងសាងសង់បង្គន់អនាម័យក្នុងសហគមន៍

ទី ស៊ីថា




ជនជាតិដើមភាគតិចស្មៀង ដែលមានជីវភាពខ្វះខាតនៅក្នុងភូមិក្តុលលើចូលរួមស្តាប់ការធ្វើបទបង្ហាញរបស់មន្ត្រីមកពីក្រសួងអភិវឌ្ឍន៍ជនបទ អំពីសារសំខាន់នៃការប្រើប្រាស់ប័ណ្ណសមធម៌ និងគម្រោងសាងសង់បង្គន់អនាម័យក្នុងសហគមន៍ នៅរសៀល ថ្ងៃទី២៥ ខែមីនា ឆ្នាំ២០២៦។ (បណ្ណសារមជ្ឈមណ្ឌលឯកសារកម្ពុជា)

នៅរសៀល ថ្ងៃទី២៥ ខែមីនា ឆ្នាំ២០២៦ ក្រុមការងាររបស់ក្រសួងអភិវឌ្ឍន៍ជនបទបានចុះមកជួបប្រជុំជាមួយបងប្អូនជនជាតិដើមភាគតិចស្មៀង ដែលមានជីវភាពខ្វះខាតចំនួន២៦គ្រួសារនៅក្នុងភូមិក្តុលលើ ឃុំទន្លូង ស្រុកមេមត់ ខេត្តត្បូងឃ្មុំ អំពីសារសំខាន់នៃការប្រើប្រាស់ប័ណ្ណសមធម៌ (ប័ណ្ណក្រីក្រ) និងគម្រោងសាងសង់បង្គន់អនាម័យ។ កិច្ចប្រជុំនេះបានរៀបចំធ្វើឡើងនៅទីតាំងផ្ទះសហគមន៍ជនជាតិដើមភាគតិចស្មៀងក្នុងភូមិក្តុលលើនៃមជ្ឈមណ្ឌលឯកសារកម្ពុជា ដែលជាទីកន្លែងសិក្សាស្រាវស្រាវពីប្រវត្តិសាស្ត្រខ្មែរក្រហម, ទំនៀមទម្លាប់ វប្បធម៌ ប្រពៃណី សាសនា របស់ជនជាតិដើមភាគតិចស្មៀង និងជាទីតាំងសាធារណៈបម្រើដល់សហគមន៍ទាំងមូល។

ជាកិច្ចចាប់ផ្តើម លោកវ៉ាស នាគុលា គឺជាមន្ត្រីមកពីគម្រោងអភិវឌ្ឍន៍ជនបទបានណែនាំខ្លួន និងបានថ្លែង



ជនជាតិដើមភាគតិចស្ទៀង ដែលមានជីវភាពខ្វះខាតនៅក្នុងភូមិក្តុលលើចូលរួមស្តាប់ការធ្វើបទបង្ហាញរបស់មន្ត្រីមកពីក្រសួងអភិវឌ្ឍន៍ជនបទ អំពីសារសំខាន់នៃការប្រើប្រាស់ប័ណ្ណសមធម៌ និងគម្រោងសាងសង់បង្គន់អនាម័យក្នុងសហគមន៍ នៅរសៀល ថ្ងៃទី២៥ ខែមីនា ឆ្នាំ២០២៦ ។ (បណ្ណសារមជ្ឈមណ្ឌលឯកសារកម្ពុជា)

អំណរគុណដល់អាជ្ញាធរភូមិក្តុលលើ និងឃុំទន្លុងរួមទាំងក្រុមការងាររបស់មជ្ឈមណ្ឌលឯកសារកោះថ្ម ដែលបានចូលរួមសហការ។ ជាពិសេសលោកអរគុណចំពោះវត្តមានរបស់ពុកម៉ែបងប្អូនជនជាតិដើមភាគតិចស្ទៀង ដែលមានប័ណ្ណក្រីក្របានមកចូលរួមប្រជុំនៅថ្ងៃនេះ។

ក្នុងឱកាសនេះ លោក វ៉ាសនា គុលា បានបង្ហាញពីគោលបំណងចំនួនពីរ សម្រាប់បងប្អូនជនជាតិដើមភាគតិចស្ទៀង គឺ គោលបំណងទីមួយ ៖ ទាក់ទងនឹងប័ណ្ណសមធម៌ ឬ ប័ណ្ណក្រីក្រ ដែលបងប្អូនកាន់យកមកចូលរួមប្រជុំ។ លោក វ៉ាសនា គុលា បន្តថារាជរដ្ឋាភិបាលកម្ពុជា បានកំណត់យកគោលនយោបាយថ្នាក់ជាតិលើកចុងក្រោយ ទាក់ទងនឹងប័ណ្ណសមធម៌ ឬប័ណ្ណក្រីក្រ។ ប័ណ្ណសមធម៌ឬប័ណ្ណក្រីក្រត្រូវបានបែងចែកជាបីផ្នែកគឺ៖ ប័ណ្ណក្រីក្រកម្រិត១, ប័ណ្ណក្រីក្រកម្រិត២ និងប័ណ្ណក្រីក្រកម្រិត៣ ឬ ហៅថាប័ណ្ណហានិភ័យ។ ប័ណ្ណទាំងបីប្រភេទនេះ សុទ្ធតែមានអត្ថប្រយោជន៍ដល់បងប្អូនទាំងអស់គ្នា ជាពិសេសប័ណ្ណនេះបងប្អូនអាចប្រើប្រាស់បានទាំងក្រុមគ្រួសារ។

លោកវ៉ាសនាគុលាបានស្នើសុំឱ្យបងប្អូនជនជាតិដើមភាគតិចស្ទៀងថែរក្សាប័ណ្ណក្រីក្រឱ្យបានល្អកុំឱ្យដាច់រហែកឬត្រូវទឹកភ្លៀង ព្រោះប័ណ្ណសមធម៌ (ប័ណ្ណក្រីក្រ) គឺជាយន្តការរបស់រាជរដ្ឋាភិបាលសម្រាប់កំណត់អត្តសញ្ញាណគ្រួសារក្រីក្រ និងជនងាយរងគ្រោះ ដើម្បីទទួលបានអត្ថប្រយោជន៍សង្គមសំខាន់ៗ រួមមាន៖ ការពិនិត្យព្យាបាលជំងឺឥតគិតថ្លៃនៅតាមមន្ទីរពេទ្យរដ្ឋ ការឧបត្ថម្ភសាច់ប្រាក់ក្រោមកម្មវិធីជាតិជំនួយសង្គមក្នុងកញ្ចប់គ្រួសារ និងអន្តរាគមន៍ជំនួយជាអាទិភាពផ្សេងទៀតពីការបាទក្រហម ឬគណ:កម្មាធិការជាតិគ្រប់គ្រងគ្រោះមហន្តរាយ។

លោកវ៉ាសនាគុលាបន្ថែមថាចំពោះសេវាសុខាភិបាល គឺទទួលបានការពិនិត្យ ព្យាបាល និងសម្រាកពេទ្យដោយឥតគិតថ្លៃនៅ គ្រប់មណ្ឌលសុខភាព និងមន្ទីរពេទ្យបង្អែករបស់រដ្ឋ។ ជំនួយសាច់ប្រាក់ គឺទទួលបានការឧបត្ថម្ភសាច់ប្រាក់ (ប្រចាំខែឬកញ្ចប់) ពី

កម្មវិធីជាតិជំនួយសង្គមក្នុងកញ្ចប់គ្រួសារ។ ជំនួយអាទិភាព គឺទទួលបានការអនុគ្រោះ ឬជំនួយជាអាទិភាពនៅពេលមានគ្រោះអាសន្នដូចជា គ្រោះធម្មជាតិ (ទឹកជំនន់ ខ្យល់កន្ត្រាក់) ឬវិបត្តិសេដ្ឋកិច្ចផ្សេងៗ។ ចំណែក ការអប់រំ គឺការលើកលែងថ្លៃសិក្សា ឬទទួលបានអាហារូបករណ៍សម្រាប់កូនចៅគ្រួសារក្រីក្រ (ជាទូទៅយោងតាមគោលការណ៍កម្រិតទី១ និងទី២)។

ជាចុងក្រោយលោកវ៉ាសនាគុលាបានបង្ហាញគោលបំណងទីពីរ៖ ដោយលោកបានបែងចែកបងប្អូនជនជាតិដើមភាគតិចស្ទៀងដែលមានបង្គន់អនាម័យឱ្យនៅម្ខាង និងបងប្អូនដែលគ្មានបង្គន់អនាម័យឱ្យនៅម្ខាងទៀត។ លោក វ៉ាសនា គុលា បានសួរសំណួរដល់បងប្អូនជនជាតិដើមភាគតិចស្ទៀងដែលកំពុងប្រើប្រាស់បង្គន់អនាម័យ អំពីអត្ថប្រយោជន៍របស់វាម្នាក់ម្តងៗ។ បន្ទាប់ពីបានស្តាប់អំពីអត្ថប្រយោជន៍បង្គន់អនាម័យរួចមកបងប្អូនជនជាតិដើមភាគតិចស្ទៀងដែលគ្មានបង្គន់អនាម័យបានបង្ហាញពីបំណងចង់បានបង្គន់អនាម័យគ្រប់គ្នា។ លោក វ៉ាសនា គុលា បានជំរុញឱ្យជនជាតិដើមភាគតិចស្ទៀងទាំងអស់ចូលរួមសង់បង្គន់អនាម័យដើម្បីសុខភាព និងសុវត្ថិភាពរបស់សមាជិកគ្រួសារ។



ជនជាតិដើមភាគតិចស្ទៀង ដែលមានជីវភាពខ្វះខាតនៅក្នុងភូមិក្តុលលើចូលរួមស្តាប់ការធ្វើបទបង្ហាញរបស់មន្ត្រីមកពីក្រសួងអភិវឌ្ឍន៍ជនបទ អំពីសារសំខាន់នៃការប្រើប្រាស់ប័ណ្ណសមធម៌ និងគម្រោងសាងសង់បង្គន់អនាម័យក្នុងសហគមន៍ នៅរសៀល ថ្ងៃទី២៥ ខែមីនា ឆ្នាំ២០២៦។ (បណ្ណសារមជ្ឈមណ្ឌលឯកសារកម្ពុជា)



# ទិវាសិទ្ធិនារីអន្តរជាតិឆ្នាំ២០២៦៖ បន្តរៀបរាប់រឿងរ៉ាវនិងធ្វើការតស៊ូមតិដើម្បីយុត្តិធម៌ និង
## សន្តិភាព ខណៈដែលពិភពលោកកំពុងយកចិត្តទុកដាក់លើជម្លោះនៅមជ្ឈិមបូព៌ា

*សូ ហ្វារីណា*



*កុមារបដិវត្តន៍នៅក្នុងរបបខ្មែរក្រហមកំពុងឈរគោរពទង់ជាតិ។*
*(បណ្ណសារមជ្ឈមណ្ឌលឯកសារកម្ពុជា)*

ខណៈពេលដែលយើងកំពុងរស់នៅក្នុងតំបន់ដែលមានសុវត្ថិភាព និងប្រារព្ធទិវានារីអន្តរជាតិលើកទី១១៥ នៅឆ្នាំ២០២៦ដែលផ្តោតសំខាន់ការទទួលខុសត្រូវ ការទទួលបានយុត្តិធម៌ និងសន្តិសុខសម្រាប់ស្ត្រី និងក្មេងស្រី មានស្ត្រីនិងកុមារជាច្រើនទៀតកំពុងតែរស់នៅក្នុងតំបន់ជម្លោះ ឬជិតនៅតាមព្រំដែន ដែលទទួលបានអាហារ សន្តិសុខ ការថែទាំសុខភាព ការអប់រំ តិចតួច និងមិនទាន់ទទួលបានយុត្តិធម៌នៅឡើយ។

ជម្លោះព្រំដែនរវាងប្រទេសកម្ពុជា និងប្រទេសថៃមិនត្រឹមតែបន្សល់ទុកនូវចំនួនអ្នកស្លាប់ និងរបួសជាច្រើនប៉ុណ្ណោះទេ ប៉ុន្តែថែមទាំងមានការបាត់បង់ទឹកដី និងបន្សល់ទុកជនភៀសសឹកកម្ពុជាក្រោយពីមានបទឈប់បាញ់កាលពីខែធ្នូ ឆ្នាំ២០២៥។ យ៉ាងហោចណាស់មានប្រជាជនកម្ពុជា

ចំនួន ៥០,០០០ នាក់ ដែលភាគច្រើនជាស្ត្រី និងកុមារ ហើយដែលផ្ទះសម្បែងនិងដីធ្លី ព្រមទាំងទ្រព្យសម្បត្តិ ត្រូវបានទាហានថៃរឹបអូសយកទៅដោយខុសច្បាប់ នៅតែរស់នៅក្នុងជំរំជនភៀសសឹកនៅឡើយ។

សន្តិភាពយូរអង្វែងតែងតែត្រូវបានបន្ទុចបង្អាក់ និងពន្យារពេលដោយយោធានិងរដ្ឋាភិបាលថៃ។ នៅលើឆាកអន្តរជាតិ រដ្ឋមន្ត្រីការបរទេសថៃព្យាយាមផ្សព្វផ្សាយច្បាប់អន្តរជាតិ និងបង្ហាញខ្លួនឯងថាគឺជាតួអង្គស្រឡាញ់សន្តិភាព ដើម្បីឱ្យបណ្ដាប្រទេសផ្សេងៗលង់ជឿ ប៉ុន្តែតាមពិតទាហានថៃដោយមានការគាំទ្រពីរដ្ឋាភិបាលថៃកំពុងសាងសង់លេណដ្ឋានយោធារឹងមាំ ផ្លូវថ្នល់នៅលើទឹកដីកម្ពុជា និងកែប្រែភូមិឋានខ្មែរដែលទាហានថៃកាន់កាប់ដោយខុសច្បាប់ឱ្យទៅជារបស់ខ្លួននិងបន្តគំរាមកំហែងប្រជាជនកម្ពុជាស្លូតត្រង់នៅតាមព្រំដែន។

ទោះបីជាមិនមានពេលវេលាកំណត់ណាមួយដើម្បីធានាបាននូវយុត្តិធម៌ និងសន្តិភាពយូរអង្វែង ខណៈភាគីថៃពន្យារពេលសំណើរាំងរ៉ាស់វែងបង្គោលព្រំដែនគោកដែលមានវិវាទ ដែលស្នើដោយភាគីកម្ពុជា ស្របពេលពិភពលោកកំពុងមមាញឹកជាមួយសង្គ្រាមនៅមជ្ឈិមបូព៌ា, ស្ត្រីនិងកុមារដែលជាជនភៀសសឹក នៅតែបន្តរៀបរាប់រឿងរ៉ាវរបស់ខ្លួនទៅកាន់ពិភពលោកឱ្យបានដឹងកាន់តែច្រើន នឹងទាមទារយុត្តិធម៌ចំពោះការបាត់បង់និងខូចខាត ហើយតែងតែមានក្ដីសង្ឃឹមថាខ្លួនអាចវិលត្រឡប់ទៅផ្ទះសម្បែងរបស់ខ្លួនវិញនៅថ្ងៃណាមួយនៅពេលខាងមុខ។

ការស៊ូទ្រាំ ការតស៊ូមតិដើម្បីយុត្តិធម៌និងសន្តិភាព និងភាពធន់របស់ស្ត្រីនិងកុមារ គឺជាអាវុធរបស់អ្នកដែលទទួលរងនូវភាពអយុត្តិធម៌។ សូមឱ្យប្រធានបទនៃទិវានារីអន្តរជាតិឆ្នាំនេះ ជំរុញនូវភាពត្រឹមត្រូវឡើងវិញ ក្នុងគោលបំណងពង្រឹងប្រព័ន្ធការទទួលខុសត្រូវ និងការធានានូវការទទួលបានយុត្តិធម៌សម្រាប់ស្ត្រី និងក្មេងស្រី ជួយបង្កើនសកម្មភាពនិងកម្លាំងសមូហភាពរបស់ស្ត្រីនៅទូទាំងពិភពលោកដើម្បីសម្រេចបានយុត្តិធម៌ ការជួបជុំគ្រួសារ និងសន្តិភាពយូរអង្វែង។



កុមារនិងគ្រូបង្រៀននៅក្នុងរបបកម្ពុជាប្រជាធិបតេយ្យ (១៩៧៥-១៩៧៩)។ (បណ្ណសារមជ្ឈមណ្ឌលឯកសារកម្ពុជា)

# ការលើកកម្ពស់សមភាពយេនឌ័រ និងការគាំទ្រអនាគតកុមារី នៅភូមិអូរស្វាយ នៃស្រុកបុរីអូរស្វាយ សែនជ័យ

*ស្រេង លីដា*




*អង្គការនារីដើម្បីសន្តិភាព សហការជាមួយ អគារមរតកសង្គមរាស្ត្រនិយម សម្តេចឪ-សម្តេចម៉ែ (បុរីអូរស្វាយ-សែនជ័យ) នៃព្រះរាជបណ្ណាល័យហ្វូងម៉ែ រៀបចំវេទិកាអប់រំសហគមន៍ ផ្តោតលើគម្រោង «ក្មេងស្រីដឹកនាំសកម្មភាព» ស្ថិតនៅក្នុងភូមិអូរស្វាយ ឃុំអូរស្វាយ ស្រុកបុរីអូរស្វាយសែនជ័យ ខេត្តស្ទឹងត្រែង នៅថ្ងៃទី១៣ ខែមីនា ឆ្នាំ២០២៦។*
*(បណ្ណសារមជ្ឈមណ្ឌលឯកសារកម្ពុជា)*

នៅថ្ងៃទី១៣ ខែមីនា ឆ្នាំ២០២៦ អង្គការនារីដើម្បីសន្តិភាព បានរៀបចំវេទិកាអប់រំសហគមន៍ របស់គម្រោង«ក្មេងស្រីដឹកនាំសកម្មភាព»។ កម្មវិធីនេះ ត្រូវបានរៀបចំធ្វើឡើង ក្រោមកិច្ចសហការជាមួយ អគារមរតកសង្គមរាស្ត្រនិយម សម្តេចឪ-សម្តេចម៉ែ (បុរីអូរស្វាយ-សែនជ័យ) នៃព្រះរាជបណ្ណាល័យហ្វូងម៉ែ ស្ថិតនៅក្រោមម្លប់ស្វាយ តាមដងទន្លេមេគង្គ។ វេទិកាអប់រំសហគមន៍នៅក្រោមដើមស្វាយធំមួយដើមក្បែរមាត់ទន្លេមេគង្គ មិនត្រឹមតែផ្តល់ចំណេះដឹងដល់អ្នកចូលរួមតែប៉ុណ្ណោះទេ ក៏ប៉ុន្តែថែមទាំងផ្តល់បរិយាកាសដ៏មនោរម្យជាមួយធម្មជាតិតាមដងទន្លេមេគង្គ។

គោលបំណងចម្បងនៃវេទិកាអប់រំសហគមន៍ គឺជាការបញ្ជ្រាបការយល់ដឹងឱ្យកាន់តែស៊ីជម្រៅអំពី «ទស្សនទានយេនឌ័រ» តាមរយៈការពិភាក្សា និង

ការរៀបចំជាទម្រង់សំណួរ-ចម្លើយ។ អ្នកចូលរួមបានស្វែងយល់កាន់តែច្បាស់អំពីភាពខុសគ្នារវាង «ភេទ» (លក្ខណៈជីវសាស្ត្រពីកំណើត) និង «យេនឌ័រ» (តួនាទី និងការរំពឹងទុករបស់សង្គម)។ លើសពីនេះ កម្មវិធីបានជួយឱ្យសហគមន៍រួមគ្នាពិចារណា និងលុបបំបាត់ផ្នត់គំនិតអវិជ្ជមាន ដែលធ្លាប់ជាសម្ពាធរឹតត្បិតសិទ្ធិសេរីភាព និងបង្កជាការរើសអើងចំពោះស្ត្រី និងកុមារីនាពេលកន្លងមក។

ទន្ទឹមនឹងការផ្លាស់ប្តូរឥរិយាបថសង្គម កម្មវិធីក៏បានសង្កត់ធ្ងន់លើចំណុចយុទ្ធសាស្ត្រចំនួនពីរ៖ ១) ការគាំទ្រការសិក្សា និងវិជ្ជាជីវៈ៖ លើកទឹកចិត្តឱ្យមាតាបិតាក្លាយជា «ប្រព័ន្ធគាំទ្រដ៏រឹងមាំ» សម្រាប់កូនៗ ដោយផ្តល់ឱកាសឱ្យកូនៗទទួលបានការអប់រំជាន់ខ្ពស់ និងមានសេរីភាពពេញលេញក្នុងការជ្រើសរើសវិជ្ជាជីវៈតាមចំណង់ចំណូលចិត្ត ដើម្បីកសាងអនាគតដ៏រឹងមាំ និង ២) ការសន្ទនាដោយបើកចំហក្នុងគ្រួសារ ដើម្បីជំរុញការប្រាស្រ័យទាក់ទងរវាងអាណាព្យាបាល និងកូនៗ លើប្រធានបទ សិទ្ធិ សុខភាពផ្លូវភេទ និងសុខភាពបន្តពូជ។ ការបង្កើនភាពស្និទ្ធស្នាល និងការយល់ដឹងក្នុងគ្រួសារលើបញ្ហាទាំងនេះ គឺជាខែលការពារកុមារីពីហានិភ័យផ្សេងៗ និងជួយក្មេងស្រីឱ្យរស់នៅដោយភាពជឿជាក់។

កិច្ចសហការរវាងអង្គការនារីដើម្បីសន្តិភាព និងអគាររមរតកសង្គមរាស្ត្រនិយម នាថ្ងៃនេះ មិនត្រឹមតែជាការចែករំលែកចំណេះដឹងតែប៉ុណ្ណោះទេ ប៉ុន្តែជាការបណ្តុះគ្រាប់ពូជនៃសមភាពយេនឌ័រ និងការផ្តល់តម្លៃដល់មនុស្សគ្រប់រូបក្នុងស្រុកបុរីអូរស្វាយសែនជ័យ។ នៅពេលដែលផ្នត់គំនិតសង្គមត្រូវបានបើកចំហ កុមារី នឹងមានឱកាសកាន់តែច្រើនក្នុងការបង្ហាញសមត្ថភាពក្លាយជាអ្នកដឹកនាំ និងជាកម្លាំងចលករដ៏សំខាន់ក្នុងការអភិវឌ្ឍន៍សង្គមជាតិទាំងមូល។





អង្គការនារីដើម្បីសន្តិភាព សហការជាមួយ អគាររមរតកសង្គមរាស្ត្រនិយម សម្តេចឪ-សម្តេចម៉ែ (បុរីអូរស្វាយ-សែនជ័យ) នៃព្រះរាជបណ្ណាល័យ ហ៊ុនម៉ែ រៀបចំវេទិកាអប់រំសហគមន៍ ផ្តោតលើគម្រោង «ក្មេងស្រីដឹកនាំសកម្មភាព» ស្ថិតនៅក្នុងភូមិអូរស្វាយ ឃុំអូរស្វាយ ស្រុកបុរីអូរស្វាយសែនជ័យ ខេត្តស្ទឹងត្រែង នៅថ្ងៃទី១៣ ខែមីនា ឆ្នាំ២០២៦។ (បណ្ណសារមជ្ឈមណ្ឌលឯកសារកម្ពុជា)









អង្គការនារីដើម្បីសន្តិភាព សហការជាមួយ អគារមរតកសង្គមរាស្ត្រនិយម សម្តេចឪ-សម្តេចម៉ែ (បុរីអូរស្វាយ-សែនជ័យ) នៃព្រះរាជបណ្ណាល័យហ្លួនម៉ែ រៀបចំវេទិកាអប់រំសហគមន៍ ផ្តោតលើគម្រោង «ក្មេងស្រីដឹកនាំសកម្មភាព» ស្ថិតនៅក្នុងភូមិអូរស្វាយ ឃុំអូរស្វាយ ស្រុកបុរីអូរស្វាយសែនជ័យ ខេត្តស្ទឹងត្រែង នៅថ្ងៃទី១៣ ខែមីនា ឆ្នាំ២០២៦។ (បណ្ណសារមជ្ឈមណ្ឌលឯកសារកម្ពុជា)



# វេទិកាថ្នាក់រៀនស្តីពីប្រវត្តិសាស្ត្រ ខ្មែរក្រហមផ្តោតលើប្រធានបទ៖ «ព្រឹត្តិការណ៍ថ្ងៃទី១៨ ខែមីនា ឆ្នាំ១៩៧0 និងភាពជាអ្នកដឹកនាំរបស់យុវជនជំនាន់ក្រោយ» នៅមជ្ឈមណ្ឌលឯកសារខេត្តព្រៃវែង

ជាវ៉រដ្ឋ មេត្តា








មជ្ឈមណ្ឌលឯកសារខេត្តព្រៃវែងរៀបចំវេទិកាថ្នាក់រៀនស្តីពីប្រវត្តិសាស្ត្រខ្មែរក្រហម ផ្តោតលើប្រធានបទ៖ «ព្រឹត្តិការណ៍ថ្ងៃទី១៨ ខែមីនា ឆ្នាំ១៩៧០ និងភាពជាអ្នកដឹកនាំរបស់យុវជនជំនាន់ក្រោយ» ដល់សិស្សថ្នាក់ទី១២ ចំនួន១១នាក់ មកពីវិទ្យាល័យ ហ៊ុន សែន កំពង់លាវ នៅព្រឹកថ្ងៃទី១២ ខែមីនា ឆ្នាំ២០២៦។ (បណ្ណសារមជ្ឈមណ្ឌលឯកសារកម្ពុជា)

នៅវេលាម៉ោង៨ និង៣០នាទីព្រឹកថ្ងៃទី១២ ខែមីនា ឆ្នាំ២០២៦ សិស្សានុសិស្សថ្នាក់ទី១២ ចំនួន១១នាក់ មកពីវិទ្យាល័យ ហ៊ុន សែន កំពង់លាវ បានចូលរួមវេទិកាថ្នាក់រៀនអំពីប្រវត្តិសាស្ត្រកម្ពុជាប្រជាធិបតេយ្យ (១៩៧៥-១៩៧៩) ផ្តោតលើប្រធានបទ«ព្រឹត្តិការណ៍ថ្ងៃទី១៨ ខែមីនា ឆ្នាំ១៩៧០» និង «ភាពជាអ្នកដឹកនាំរបស់យុវជនជំនាន់ក្រោយ»។ គោលបំណងនៃវេទិកាថ្នាក់រៀននេះ គឺជំរុញឱ្យសិស្សា-នុសិស្សស្វែងយល់បន្ថែមពីព្រឹត្តិការណ៍ដែលនាំឱ្យកើតមានអំពើប្រល័យពូជសាសន៍ខ្មែរក្រហម ដែលបានសម្លាប់មនុស្សអស់ប្រមាណជាងពីរលាននាក់ ត្រឹមតែក្នុងរយៈពេលជាងបីឆ្នាំនៃការកាន់អំណាចរបស់ខ្លួន។ វេទិកានេះបានផ្តល់ឱកាសដល់សិស្សានុសិស្សសិក្សាពីគន្លឹះសំខាន់ៗ និងចាំបាច់មួយចំនួន ដើម្បីតម្រង់ទិស និងអភិវឌ្ឍន៍សមត្ថភាពខ្លួនទៅជាយុវជនឆ្នើម និងជាអ្នកដឹកនាំនាពេលអនាគត។

វេទិកាថ្នាក់រៀនបានចាប់ផ្តើមដោយការពិភាក្សារវាងគ្រូខទ្ទេស ផេង ពង្ស៉ាស៊ី នាយកមជ្ឈមណ្ឌលឯកសារខេត្តព្រៃវែងជាមួយសិស្សានុសិស្ស ទាក់ទងនឹងរបបខ្មែរក្រហម។ លោក ផេង ពង្ស៉ាស៊ី បាន

រៀបរាប់ថា នៅសល់តែរយៈពេលមួយសប្ដាហ៍ទៀតតែប៉ុណ្ណោះ គឺត្រូវជាខួបលើកទី៥៦ឆ្នាំនៃការធ្វើរដ្ឋប្រហារទម្លាក់សម្ដេចព្រះ នរោត្តម សីហនុ ចេញពីតំណែងព្រះប្រមុខរដ្ឋ។ ឆ្លៀតឱកាសនេះ លោក ដេង ពង្សវ៉ាស៊ី បានសួរសំណួរទៅកាន់សិស្សទាក់ទងនឹងថ្ងៃទី១៨ ខែមីនា ឆ្នាំ១៩៧០ ដើម្បីឱ្យសិស្សនៅក្នុងថ្នាក់ពិភាក្សាគ្នា។

បន្ទាប់មកលោក ដេង ពង្សវ៉ាស៊ី ចាប់ផ្ដើមពន្យល់ពីមូលហេតុដែលនាំឱ្យកើតមានរដ្ឋប្រហារទម្លាក់សម្ដេចព្រះ នរោត្តម សីហនុដោយលើកឡើងថា បណ្ដាលមកពីស្ថានភាពយោធា គឺវត្តមានកងទ័ពវៀតណាមខាងជើង និងកងទ័ពវៀតកុងនៅតាមបណ្ដោយព្រំដែនកម្ពុជា-វៀតណាម, កត្តាសេដ្ឋកិច្ច (គោលនយោបាយជាតូបនីយកម្មធ្វើឱ្យសេដ្ឋកិច្ចធ្លាក់ចុះ អតិផរណា អំពើពុករលួយ) និង កត្តានយោបាយ (ក្រុមស្ដាំនិយម និងក្រុមឆ្វេងនិយមចង់ផ្លាស់ប្ដូររបបនយោបាយកម្ពុជាឱ្យងាកទៅរកនិន្នាការនយោបាយដែលក្រុមនីមួយៗចង់បាន ក្រៅពីគោលនយោបាយអព្យាក្រឹត)។ លោក ដេង ពង្សវ៉ាស៊ី ក៏បានលើកឡើងពីឥទ្ធិពលនៃការធ្វើរដ្ឋប្រហារដែលបន្តជាផលប៉ះពាល់យ៉ាងធ្ងន់ធ្ងរដល់ជីវភាពរស់នៅប្រចាំថ្ងៃរបស់ប្រជាជននៅទូទាំងប្រទេសកម្ពុជា។ ទន្ទឹមនោះ លោក ដេង ពង្សវ៉ាស៊ី បានបង្ហាញពីព្រឹត្តិការណ៍នៃការទម្លាក់គ្រាប់បែកនាដើមទសវត្សរ៍ឆ្នាំ១៩៧០ ដែលបានស្ងប់ស្ងាត់ជាង៥០ឆ្នាំកន្លងមកហើយនៅប្រទេសកម្ពុជា ប៉ុន្តែស្លាកស្នាមប្រវត្តិសាស្ត្រនៅតែដិតដាមជាប់ក្នុងចិត្តប្រជាជនកម្ពុជាជានិច្ច។ លោក ដេង ពង្សវ៉ាស៊ី បានប្រៀបធៀប ដោយបានលើកឡើងពីការទម្លាក់គ្រាប់បែកនាពេលថ្មីៗនេះ ដែលជាការបង្កហេតុដោយភាគីថៃក្នុងសង្គ្រាមឈ្លានពានប្រទេសកម្ពុជា និងបង្កជាវិនាសកម្មសារជាថ្មីម្ដងទៀតក្នុងសតវត្សរ៍នៃបច្ចេកវិទ្យា មកលើប្រជាជនកម្ពុជាដែលកំពុងរស់នៅយ៉ាងសុខសាន្តនៅតាមបណ្ដោយព្រំដែនកម្ពុជា-ថៃ។

មុននឹងបញ្ចប់វេទិកាថ្នាក់រៀន លោក ដេង ពង្សវ៉ាស៊ីបានលើកឡើងពីផលលំបាករយៈពេលវែងនៃសង្គ្រាមនៅកម្ពុជា ដែលបណ្ដាលមកពីរដ្ឋប្រហារ និងការឈ្លានរបស់ថៃ។ រដ្ឋប្រហារ គឺមិនមែនត្រឹមតែជាការផ្លាស់ប្ដូរមេដឹកនាំតែប៉ុណ្ណោះទេ ប៉ុន្តែគឺវាជាមូលហេតុដែលអូសទាញប្រទេសកម្ពុជាចូលក្នុងភ្លើងសង្គ្រាម ហើយជាឫសគល់ដែលនាំឱ្យកើតមានរបបប្រល័យពូជសាសន៍នៅកម្ពុជា។ មូលហេតុនៃឈ្លានពានរបស់ថៃ គឺជាការប៉ុនប៉ងដោយបានគ្រោងទុកជាយូរមកហើយពីសំណាក់សត្រូវ ហើយបានធ្វើឱ្យប្រទេស និងប្រជាជនកម្ពុជាធ្លាក់ចូលក្នុងវិបត្តិសេដ្ឋកិច្ច រាំងស្ទះដល់ការអភិវឌ្ឍន៍ប្រទេសជាតិ និងលើកកម្ពស់សមត្ថភាពយោធា ដែលត្រូវចំណាយពេលវេលាវែងក្នុងការស្តារឡើងវិញ។



មជ្ឈមណ្ឌលឯកសារខេត្តព្រៃវែងរៀបចំវេទិកាថ្នាក់រៀនស្ដីពីប្រវត្តិសាស្ត្រខ្មែរក្រហម ផ្ដោតលើប្រធានបទ៖ «ព្រឹត្តិការណ៍ថ្ងៃទី១៨ ខែមីនា ឆ្នាំ១៩៧០ និងភាពជាអ្នកដឹកនាំរបស់យុវជនជំនាន់ក្រោយ» ដល់សិស្សថ្នាក់ទី១២ចំនួន១១នាក់ មកពីវិទ្យាល័យ ហ៊ុន សែន កំពង់លាវ នៅព្រឹកថ្ងៃទី១២ ខែមីនា ឆ្នាំ២០២៦។ (បណ្ណសារមជ្ឈមណ្ឌលឯកសារកម្ពុជា)

ដើម្បីចូលរួមទប់ស្កាត់អំពើប្រល័យពូជសាសន៍ និងអំពើឈ្លានពាន លោក ដេង ពង្សវ៉ាស៊ីបានណែនាំដល់សិស្សានុសិស្សឱ្យខិតខំរៀនសូត្រពីប្រវត្តិសាស្ត្ររបស់ខ្លួន និងត្រៀមខ្លួនទប់ស្កាត់អំពើឃោរឃៅដែលនាំដល់ការកាប់សម្លាប់ប្រជាជន និងការបំផ្លិចបំផ្លាញប្រទេសជាតិ។







មជ្ឈមណ្ឌលឯកសារខេត្តព្រៃវែងរៀបចំវេទិកាថ្នាក់រៀនស្តីពីប្រវត្តិសាស្ត្រខ្មែរក្រហម ផ្តោតលើប្រធានបទ៖ «ព្រឹត្តិការណ៍ថ្ងៃទី១៨ ខែមីនា ឆ្នាំ១៩៧០ និងភាពជាអ្នកដឹកនាំរបស់យុវជនជំនាន់ក្រោយ» ដល់សិស្សថ្នាក់ទី១២ចំនួន១១នាក់ មកពីវិទ្យាល័យ ហ៊ុន សែន កំពង់លាវ នៅព្រឹកថ្ងៃទី១២ ខែមីនា ឆ្នាំ២០២៦។ (បណ្ណសារមជ្ឈមណ្ឌលឯកសារកម្ពុជា)

## ចំណាប់អារម្មណ៍របស់សិស្ស

ខ្ញុំឈ្មោះ **ហាន លក្ខិណា** អាយុ១៨ឆ្នាំ គឺជាសិស្សរៀនថ្នាក់ទី១២ នៃវិទ្យាល័យ ហ៊ុន សែន កំពង់លាវ។ នៅពេលដែលខ្ញុំបានមកដល់មជ្ឈមណ្ឌលឯកសារខេត្តព្រៃវែងដំបូង ខ្ញុំមានអារម្មណ៍ប្លែក និងទទួលបាននូវបទពិសោធន៍ថ្មីៗ ជាពិសេសទទួលបានចំណេះដឹងពីប្រវត្តិសាស្ត្រខ្មែរក្រហមបានច្រើនជាងមុនៗ នៅក្នុងចំណោមមេរៀនដែលគ្រូបានបង្រៀនខ្ញុំនៅថ្ងៃនេះ ខ្ញុំមានការចាប់អារម្មណ៍ទៅលើមេរៀនរដ្ឋប្រហារទម្លាក់សម្តេចព្រះ នរោត្តម សីហនុ នៅថ្ងៃទី១៨ ខែមីនា ឆ្នាំ១៩៧០។ នៅពេលនោះ សម្តេចព្រះ នរោត្តម សីហនុ កំពុងតែដឹកនាំប្រទេសកម្ពុជា ស្រាប់តែក្រុមឆ្វេងនិយម និងក្រុមស្តាំនិយមបានទាញទម្លាក់ព្រះអង្គចេញពីតំណែង និងឈានដល់ការធ្វើរដ្ឋប្រហារ។ សេនាប្រមុខ លន់ នល់ គឺជាអ្នកធ្វើរដ្ឋប្រហារទម្លាក់សម្តេចព្រះ នរោត្តម សីហនុ ដោយសារតែមានក្រុមឆ្វេងនិយម និងក្រុមស្តាំនិយមចោទសម្តេចថា មានទំនាក់ទំនងជាមួយវៀតណាមដែលជាហេតុធ្វើឱ្យវៀតណាមមករស់នៅលើទឹកដីប្រទេសកម្ពុជាកាន់តែច្រើនៗ សេនាប្រមុខ លន់ នល់ បានដឹកនាំប្រទេសមួយរយៈពេលខ្លី ហើយមិនយូរប៉ុន្មានខ្មែរក្រហមបានឡើងដឹកនាំប្រទេសកម្ពុជា។ បន្ទាប់ពីខ្មែរក្រហមឡើងកាន់អំណាច ប្រជាជនកម្ពុជាជួបការលំបាកវេទនា ដូចជា ធ្វើការងារហួសកម្លាំង ហូបចុកមិនគ្រប់គ្រាន់ និងត្រូវបានសម្លាប់យ៉ាងរង្គាល។ ចំណែកមេរៀនទាក់ទងនឹងភាពជាអ្នកដឹកនាំរបស់យុវជន ខ្ញុំយល់ថាល្អខ្លាំងណាស់ព្រោះពាក់ព័ន្ធទៅនឹងសង្គមជាក់ស្តែង ឧទាហរណ៍ខ្លួនខ្ញុំផ្ទាល់ត្រូវខិតខំរៀនសូត្រ មានសីលធម៌ល្អក្នុងការរស់នៅ និង

បេះគោរពដល់អ្នកដទៃ ព្រោះអ្នកដឹកនាំល្អគឺត្រូវតែមានចំណេះដឹង។ ខ្ញុំនឹងខិតខំសិក្សាស្វែងយល់ពីប្រវត្តិសាស្ត្រនៅក្នុងអតីតកាល និងបច្ចុប្បន្នដើម្បីជួយសង្គមជាតិទាំងមូលឱ្យមានការអភិវឌ្ឍន៍កាន់តែប្រសើរជាងនេះ។ ជាចុងក្រោយ ខ្ញុំចង់ផ្តាំផ្ញើទៅប្អូនៗឱ្យខិតខំរៀនសូត្រពីប្រវត្តិសាស្ត្រខ្មែរក្រហម ដើម្បីកុំឱ្យការកាប់សម្លាប់កើតឡើងម្តងទៀត ព្រោះប្រជាជនកម្ពុជាបានជួបការលំបាកច្រើនមកហើយ។

ខ្ញុំឈ្មោះ **ថន ស្រីនីត** អាយុ១៧ឆ្នាំ រៀនថ្នាក់ទី១២ នៃវិទ្យាល័យ ហ៊ុន សែនកំពង់លាវ។ នេះគឺជាលើកទី១របស់ខ្ញុំដែលបានមកសិក្សានៅមជ្ឈ-មណ្ឌលឯកសារខេត្តព្រៃវែង។ ខ្ញុំចាប់អារម្មណ៍ខ្លាំងលើរូបថតប្រវត្តិសាស្ត្រ ដែលក្រុមការងារបានពន្យល់ខ្ញុំពីព្រឹត្តិការណ៍នៃផ្ទាំងរូបថតទាំងនេះ។ ខ្ញុំចង់ឱ្យក្មេងៗជំនាន់ក្រោយ និងប្អូនៗមកសិក្សាស្វែងយល់ពីប្រវត្តិ-សាស្ត្រដូចខ្ញុំដែរ។ ខ្ញុំសប្បាយរីករាយ និងលាយឡំជាមួយភាពសោកសៅនៅពេលដឹងរឿងរ៉ាវដែលប្រជាជនកម្ពុជាបានជួបប្រទះក្នុងរបបខ្មែរក្រហម។ យាយទួតរបស់ខ្ញុំម្នាក់ត្រូវខ្មែរក្រហមបានបាញ់សម្លាប់។ ម្តាយខ្ញុំបានប្រាប់ខ្ញុំថា គ្រាប់កាំភ្លើងដែលខ្មែរក្រហមបាញ់សម្លាប់យាយទួតរបស់ខ្ញុំបានខ្ទាតមកត្រូវយាយរបស់ខ្ញុំម្នាក់ទៀត បណ្តាលឱ្យមានស្លាកស្នាមរហូតមកដល់បច្ចុប្បន្ន។ ខ្ញុំចង់សិក្សាពីប្រវត្តិសាស្ត្រខ្មែរក្រហម ព្រោះបានធ្វើឱ្យខ្ញុំយល់កាន់តែយល់ច្បាស់បន្ថែមទៀតពីប្រទេសជាតិ ហើយខ្ញុំក៏បានត្រៀមខ្លួនប្រឡងសញ្ញាបត្រមធ្យមសិក្សាទុតិយភូមិទាក់ទងនឹងមុខវិជ្ជាប្រវត្តិសាស្ត្រនៅពេលខាងមុខដែរ។ ខ្ញុំនឹងខិតខំរៀនសូត្រ ដើម្បីពង្រឹងសមត្ថភាពរបស់ខ្លួន និងជួយអភិវឌ្ឍន៍សង្គមជាតិឱ្យបានជឿនលឿន។ ប្រសិនបើមានពេលទំនេរ ខ្ញុំនឹងមកអានឯកសារ និងទស្សនាខ្សែភាពយន្តឯកសារទាក់ទងនឹងប្រវត្តិសាស្ត្រខ្មែរក្រហមនៅមជ្ឈមណ្ឌលឯកសារខេត្តព្រៃវែងម្តងទៀត។




មជ្ឈមណ្ឌលឯកសារខេត្តព្រៃវែងរៀបចំវេទិកាថ្នាក់រៀនស្តីពីប្រវត្តិសាស្ត្រខ្មែរក្រហម ផ្តោតលើប្រធានបទ៖ «ព្រឹត្តិការណ៍ថ្ងៃទី១៨ ខែមីនា ឆ្នាំ១៩៧០ និងភាពជាអ្នកដឹកនាំរបស់យុវជនជំនាន់ក្រោយ» ដល់សិស្សថ្នាក់ទី១២ចំនួន១១នាក់ មកពីវិទ្យាល័យ ហ៊ុន សែន កំពង់លាវ នៅព្រឹកថ្ងៃទី១២ ខែមីនា ឆ្នាំ២០២៦។ (បណ្ណសារមជ្ឈមណ្ឌលឯកសារកម្ពុជា)

# វេទិកាថ្នាក់រៀនស្តីអំពី «ប្រវត្តិសាស្ត្រកម្ពុជាប្រជាធិបតេយ្យ (១៩៧៥-១៩៧៩)» នៅមជ្ឈមណ្ឌលសន្តិភាពអន្លង់វែង

*លី សុខឃាង*







មជ្ឈមណ្ឌលសន្តិភាពអន្លង់វែង រៀបចំវេទិកាថ្នាក់រៀនស្តីពីប្រវត្តិសាស្ត្រកម្ពុជាប្រជាធិបតេយ្យ ផ្តោតលើប្រធានបទ៖ ១) រដ្ឋប្រហារ ថ្ងៃទី១៨ ខែមីនា ឆ្នាំ១៩៧០ និង២) ការលាលែងពីតំណែងប្រមុខរដ្ឋនៃរបបកម្ពុជាប្រជាធិបតេយ្យរបស់សម្តេចព្រះ នរោត្តម សីហនុ ដល់សិស្សចំនួន៥នាក់ មកពីវិទ្យាល័យអន្លង់វែង នៅថ្ងៃទី១១ ខែមីនា ឆ្នាំ២០២៦។ (បណ្ណសារមជ្ឈមណ្ឌលឯកសារកម្ពុជា)

នៅថ្ងៃទី១១ ខែមីនា ឆ្នាំ២០២៦ មជ្ឈមណ្ឌលសន្តិភាពអន្លង់វែង បានរៀបចំវេទិកាថ្នាក់រៀនស្តីពី «ប្រវត្តិសាស្ត្រកម្ពុជាប្រជាធិបតេយ្យ (១៩៧៥-១៩៧៩)» សម្រាប់សិស្សានុសិស្សចំនួន៥នាក់ មកពីវិទ្យាល័យអន្លង់វែង។ គោលបំណងរបស់វេទិកាថ្នាក់រៀន គឺលើកកម្ពស់ការយល់ដឹងអំពីការចងចាំប្រវត្តិសាស្ត្រក្នុងរបបខ្មែរក្រហម ជាពិសេសយុវជនជំនាន់ក្រោយ លើកកម្ពស់សន្តិភាព និងជំរុញឱ្យមានការផ្សះផ្សាផ្លូវចិត្តដល់អ្នករស់រានមានជីវិតពីរបបខ្មែរក្រហម។ វេទិកាថ្នាក់រៀនសម្រាប់ខែមីនា មជ្ឈមណ្ឌលសន្តិភាពអន្លង់វែង បានផ្តោតសំខាន់ទៅលើប្រធានបទចំនួនពីគឺ៖ ១) រដ្ឋប្រហារ ថ្ងៃទី១៨ ខែមីនា ឆ្នាំ១៩៧០ និង២) គណៈអចិន្ត្រៃយ៍ខ្មែរក្រហមពិភាក្សាអំពីបញ្ហានៃការសុំលាលែងពីតំណែងប្រមុខរដ្ឋនៃកម្ពុជាប្រជាធិបតេយ្យ របស់សម្តេចព្រះ នរោត្តម សីហនុ នៅក្នុងថ្ងៃទី១១ ខែមីនា ឆ្នាំ១៩៧៦។

## ១) ព្រឹត្តិការណ៍រដ្ឋប្រហារ ថ្ងៃទី១៨ ខែមីនា ឆ្នាំ១៩៧០

ចំពោះព្រឹត្តិការណ៍រដ្ឋប្រហារថ្ងៃទី១៨ ខែមីនា ឆ្នាំ១៩៧០ គឺជាចំណុចរបត់នៃប្រវត្តិសាស្ត្រ

នយោបាយរបស់កម្ពុជា ដែលបាននាំប្រទេសកម្ពុជាឱ្យធ្លាក់ទៅក្នុងសង្គ្រាមស៊ីវិលអស់រយៈពេលជិត៣ទសវត្សរ៍។ រដ្ឋប្រហារត្រូវបានធ្វើឡើងនៅពេលដែលសម្តេចព្រះ នរោត្តម សីហនុ គង់នៅក្រៅប្រទេស។ លោកសេនាប្រមុខ លន់ នល់ និងព្រះអង្គម្ចាស់ ស៊ីសុវត្ថិ សិរិមតៈ បានរៀបចំការបោះឆ្នោតទម្លាក់ព្រះអង្គចេញពីតំណែងព្រះប្រមុខរដ្ឋ ដោយមានការអនុម័តពីសភាជាតិកម្ពុជា។ តែទោះជាយ៉ាងណាក៏ដោយ ព្រឹត្តិការណ៍នេះចាត់ចូលជារដ្ឋប្រហារបាន ដោយសារតែក្នុងរដ្ឋធម្មនុញ្ញកម្ពុជាបានចែងថា ប្រមុខរដ្ឋនឹងគ្រងតំណែងអស់មួយជីវិត ហើយការផ្លាស់របបដឹកនាំនៅក្នុងសង្គមមួយក៏ត្រូវបានចាត់ចូលក្នុងហេតុផលទាំងនេះដែរ។ មូលហេតុចម្បងដែលនាំឱ្យមានរដ្ឋប្រហារទម្លាក់សម្តេចព្រះ នរោត្តម សីហនុ ចេញពីតំណែងព្រះប្រមុខរដ្ឋ គឺក្រោមហេតុផលដែលមានវត្តមានកងទ័ពវៀតកុងនៅលើទឹកដីកម្ពុជា ហើយនៅពេលនោះ រួមផ្សំជាមួយនឹងវិបត្តិសេដ្ឋកិច្ច និងអំពើពុករលួយក្នុងជួររដ្ឋាភិបាល។ ការធ្វើរដ្ឋប្រហាររបស់ លន់ នល់ បានធ្វើឱ្យប្រទេសកម្ពុជាមានភាពវឹកវរ និងលេចចេញនូវចលនាបក្សកុម្មុយនីស្តមួយដែលក្រោយមក ស្គាល់យ៉ាងទូលំទូលាយថា «ខ្មែរក្រហម»។ ភ្លាមៗនោះ សម្តេចព្រះ នរោត្តម សីហនុបានបង្កើតរណសិរ្សរួបរួមជាតិមួយនៅទីក្រុងប៉េកាំង ប្រទេសចិន ហើយអំពាវនាវឱ្យប្រជារាស្ត្ររបស់ព្រះអង្គចូលរួមនៅក្នុងចលនាតស៊ូនៅក្នុងព្រៃម៉ាគី ដែលត្រូវបានស្គាល់ថាជាព្រៃភ្លឹងឬព្រៃតស៊ូនៅក្នុងប្រទេសកម្ពុជា។ ហេតុការណ៍នេះ បានធ្វើឱ្យក្រុមចលនាកុម្មុយនីស្តខ្មែរក្រហមឆ្លៀតឱកាសកៀរគរប្រជាជន ហើយឈានទៅដល់ការគាំទ្រយ៉ាងពេញទំហឹងពីប្រជាជន ក្រោមរូបភាពនៃការទាមទារអំណាចថ្វាយព្រះមហាក្សត្រ។

បន្ទាប់ពីនោះ ប្រជាជនរាប់ម៉ឺននាក់បានចូលរួមជាមួយខ្មែរក្រហម តាមរយៈការបង្កើនចំនួនកងទ័ពយ៉ាងឆាប់រហ័សនៃចលនាតស៊ូ ពីចំនួន៣ពាន់នាក់នៅក្នុងឆ្នាំ១៩៧០ ទៅ៤ម៉ឺននាក់នៅក្នុងឆ្នាំ១៩៧៣។ ក្នុងពេលជាមួយគ្នានេះ លន់ នល់ បានបង្កើតរបបថ្មីមួយហៅថា «របបសាធារណរដ្ឋខ្មែរ» ដែលដឹកនាំប្រទេសកម្ពុជាពីឆ្នាំ១៩៧០-១៩៧៥ ទទួលបានការគាំទ្រពីសហរដ្ឋអាមេរិក។ របបសាធារណរដ្ឋខ្មែរទទួលបរាជ័យទៅវិញដោយសារអំពើពុករលួយ អសន្តិសុខសង្គម និងសង្គ្រាមផ្តួលរំលំពីចលនាកុម្មុយនីស្តខ្មែរក្រហម នៅថ្ងៃទី១៧ ខែមេសា ឆ្នាំ១៩៧៥។ ចាប់ពីពេលនោះមករបបកម្ពុជាប្រជាធិបតេយ្យដឹកនាំដោយក្រុមកុម្មុយនីស្តខ្មែរក្រហមបានឡើងកាន់កាប់អំណាចទាំងស្រុង (១៩៧៥-១៩៧៩) ដោយបានបើកទំព័រប្រវត្តិសាស្ត្រដ៏ជូរចត់មួយសម្រាប់សង្គមកម្ពុជាតាមរយៈការបង្ហូរឈាម ការសម្លាប់រង្គាលមិនរើសមុខ និងអំពើប្រល័យពូជសាសន៍ជាតិសាសន៍ឯងដែលបណ្តាលឱ្យបាត់បង់ជីវិតប្រជាជនប្រមាណជិត២លាននាក់។

### ២) ការសុំលាលែងពីតំណែងប្រមុខរដ្ឋរបស់សម្តេចព្រះនរោត្តម សីហនុ ក្នុងថ្ងៃទី១១ ខែមីនា ឆ្នាំ១៩៧៦

ព្រឹត្តិការណ៍ដែលភ្ជាប់នឹងការពិភាក្សាលើការធ្វើរដ្ឋប្រហារ គឺការសុំលាលែងពីតំណែងប្រមុខរដ្ឋរបស់សម្តេចព្រះ នរោត្តម សីហនុ ដោយមានការពិភាក្សា និងជួបប្រជុំដំបូងបង្អស់របស់គណៈកម្មាធិការអចិន្ត្រៃយ៍បក្សកុម្មុយនីស្តកម្ពុជានៅថ្ងៃទី១១ ខែមីនា ឆ្នាំ១៩៧៦។ គណៈអចិន្ត្រៃយ៍បក្សកុម្មុយនីស្ត បានព្រមព្រៀងទទួលយកសំណើសុំលាលែងរបស់ព្រះអង្គ ប៉ុន្តែមិនអនុញ្ញាតឱ្យព្រះអង្គចាកចេញពីប្រទេស ឬធ្វើសេចក្តីថ្លែងការណ៍ ឬជួបពិភាក្សាជាមួយអង្គទូតបរទេសណាមួយឡើយ។ របបរាជានិយមនៅកម្ពុជា ត្រូវបានបញ្ចប់នៅអំឡុងរបបខ្មែរក្រហម។

រហូតដល់ខែមេសា ឆ្នាំ១៩៧៦ សភាតំណាងប្រជាជនកម្ពុជាបានបើកសម័យប្រជុំលើកទីមួយ និងតែម្តងគត់របស់ខ្លួន ដោយបានព្រមព្រៀងគ្នាជាឯកច្ឆន្ទទៅលើសំណើយាងចូលនិវត្តន៍របស់សម្តេចព្រះ នរោត្តម សីហនុ ដោយផ្តល់ថ្វាយព្រះអង្គនូវប្រាក់សោធននិវត្តន៍ចំនួន៨ពាន់ដុល្លារនៅក្នុងមួយឆ្នាំ។

ទោះជាយ៉ាងណា ខ្មែរក្រហមមិនដែលបើកថ្វាយនូវប្រាក់បំណាច់ដល់ព្រះអង្គទាល់តែសោះ។ ព្រះអង្គ និងព្រះរាជវង្សានុវង្ស ត្រូវបានឃុំឃាំងនៅក្នុងវីឡាតូចមួយ ស្ថិតនៅក្នុងបរិវេណនៃព្រះបរមរាជវាំង។ ព្រះអង្គបានឃុំជាប់នៅក្នុងវាំងរហូតដល់ខែមករា ឆ្នាំ១៩៧៩ គឺរហូតដល់ថ្ងៃដួលរលំនៃរបបកម្ពុជាប្រជាធិបតេយ្យ។

នៅថ្ងៃទី២ ខែមករា ឆ្នាំ១៩៧៩ កងកុម្ម៉ង់ដូវៀតណាមបានឆ្លងកាត់ទន្លេចតុមុខក្បែរព្រះបរមរាជវាំង ដើម្បីចាប់ពង្រត់សម្តេចព្រះ នរោត្តម សីហនុ យកទៅវៀតណាម និងឱ្យព្រះអង្គដឹកនាំចលនាតស៊ូមួយក្រោមការជួយទំនុកបម្រុងរបស់វៀតណាមប្រឆាំងនឹងរបបកម្ពុជាប្រជាធិបតេយ្យ។ ប៉ុន្តែផែនការរបស់កងកុម្ម៉ង់ដូវៀតណាមត្រូវបរាជ័យ។ នៅថ្ងៃនោះដែរ ដោយសារសភាពការណ៍ដែលវៀតណាមវាយចូលកម្ពុជាកាន់តែមានសភាពធ្ងន់ធ្ងរ ខៀវ សំផន បានជម្លៀសព្រះអង្គទៅកាន់ស្រុកស៊ីសុផុន ក្បែរព្រំដែនខ្មែរ-ថៃ។ ពីរថ្ងៃក្រោយមក ខៀវ សំផន បានទៅយាងព្រះអង្គចូលមកទីក្រុងភ្នំពេញវិញ ដោយនិយាយថា វៀតណាមបានដកថយវិញហើយ។ ថ្ងៃទី៥ ខែមករា ឆ្នាំ១៩៧៩ ប៉ុល ពត បានយាងព្រះអង្គទៅជួបប្រជុំប្រឆាំងនឹងការលុកលុយរបស់វៀតណាម។ ជាថ្នូរនឹងកិច្ចការដ៏មានសារសំខាន់នេះ ប៉ុល ពត យល់ព្រមអនុញ្ញាតឱ្យព្រះរាជវង្សានុវង្សទាំងអស់ចាកចេញពីកម្ពុជាជាមួយព្រះអង្គដែរ ទោះបីមានការជំទាស់ពី អៀង សារី ដែលចង់ទុកព្រះរាជវង្សានុវង្សទាំងអស់នៅក្នុងប្រទេសជាចំណាប់ខ្មាំងក៏ដោយ។ សម្តេចព្រះ នរោត្តម សីហនុ និងព្រះរាជវង្សានុវង្សរបស់ព្រះអង្គបានចាកចេញឆ្ពោះទៅកាន់ប្រទេសចិនតាមជើងហោះហើររបស់ចិន នៅថ្ងៃទី៦ ខែមករា ឆ្នាំ១៩៧៩។



មជ្ឈមណ្ឌលសន្តិភាពអន្លង់វែង រៀបចំវេទិកាថ្នាក់រៀនស្តីពីប្រវត្តិសាស្ត្រកម្ពុជាប្រជាធិបតេយ្យ ផ្តោតលើប្រធានបទ៖ ១) រដ្ឋប្រហារ ថ្ងៃទី១៨ ខែមីនា ឆ្នាំ១៩៧០ និង២) ការលាលែងពីតំណែងប្រមុខរដ្ឋនៃកម្ពុជាប្រជាធិបតេយ្យរបស់សម្តេចព្រះ នរោត្តម សីហនុ ដល់សិស្សចំនួន៥នាក់ មកពីវិទ្យាល័យអន្លង់វែង នៅថ្ងៃទី១១ ខែមីនា ឆ្នាំ២០២៦។ (បណ្ណសារមជ្ឈមណ្ឌលឯកសារកម្ពុជា)

# មជ្ឈមណ្ឌលឯកសារកោះថ្មរៀបចំវេទិកាថ្នាក់រៀនស្តីពី ប្រវត្តិសាស្ត្រកម្ពុជាប្រជាធិបតេយ្យ (១៩៧៥-១៩៧៩) ផ្តោតលើប្រធានបទ ៖ ការរំលោភលើសិទ្ធិ និងពលកម្មកុមារ

**ចន បុប្ផា**





មជ្ឈមណ្ឌលឯកសារកោះថ្មរៀបចំវេទិកាថ្នាក់រៀនស្តីពី ប្រវត្តិសាស្ត្រកម្ពុជាប្រជាធិបតេយ្យ (១៩៧៥-១៩៧៩) ផ្តោតលើប្រធានបទ ៖ ការរំលោភលើសិទ្ធិ និងពលកម្មកុមារ ដល់សិស្សានុសិស្សចំនួន១៦នាក់មកពីសាលាបឋមសិក្សា ប៊ុនរ៉ានី ហ៊ុនសែន កោះថ្ម ព្រឹកថ្ងៃទី១៣ ខែមីនា ឆ្នាំ២០២៦។ (បណ្ណសារមជ្ឈមណ្ឌលឯកសារកម្ពុជា)

ព្រឹកថ្ងៃទី១៣ខែមីនាឆ្នាំ២០២៦សិស្សានុសិស្សមកពីសាលាបឋមសិក្សា ប៊ុនរ៉ានី ហ៊ុនសែន កោះថ្ម ចំនួន១៦នាក់បានចូលរួមទស្សនកិច្ចសិក្សាទាក់ទងប្រវត្តិសាស្ត្ររបបកម្ពុជាប្រជាធិបតេយ្យ (១៩៧៥-១៩៧៩)។ ក្នុងឱកាសនេះ ក្រុមការងារមជ្ឈមណ្ឌលឯកសារកោះថ្មបានលើកយកប្រធានបទ៖ ការរំលោភលើសិទ្ធិ និងពលកម្មកុមារ ក្នុងរបបខ្មែរក្រហមមកធ្វើបទបង្ហាញ។ កុមារត្រូវបានចាត់ទុកជាក្រដាសសដែលអង្គការអាចបំពាក់បំប៉នមនោគមវិជ្ជាបដិវត្តន៍បានយ៉ាងងាយស្រួល។

ជាកិច្ចចាប់ផ្តើមលោក ឈុំ រ៉ា បុគ្គលិកមជ្ឈមណ្ឌលឯកសារកោះថ្មដឹកនាំសិស្សានុសិស្សទស្សនាពិព័រណ៍រូបថត ដែលបានបន្សល់ទុកតាំងពីទសវត្សរ៍ឆ្នាំ១៩៦០ ដល់ទសវត្សរ៍ឆ្នាំ១៩៩០។ លោក ឈុំ រ៉ា បង្ហាញសិស្សានុសិស្សពីពិព័រណ៍រូបថត និងផ្ទាំងគំនូរស្តីពីប្រវត្តិសាស្ត្រកម្ពុជាប្រជាធិបតេយ្យ (១៩៧៥-១៩៧៩) ដំណើរឆ្ពោះទៅផ្តួលរំលំរបបប្រល័យពូជសាសន៍ថ្ងៃទី២០ ខែមិថុនា ឆ្នាំ១៩៧៧ ដែលដឹកនាំដោយសម្តេច ហ៊ុន សែន។

តមកលោក ឈុំ វ៉ា បានលើកយករឿងរ៉ាវ កុមារនៅក្នុងរបបខ្មែរក្រហម ដែលត្រូវបានបញ្ជូនឱ្យទៅរៀននៅក្រោមដើមឈើ និងនៅក្រោមផ្ទះប្រជាជន។ គ្រូបង្រៀនភាគច្រើន គឺជាកសិករក្រដែលអាចអាននិងសរសេរអក្សរបានបន្តិចបន្តួចតែប៉ុណ្ណោះ។ ទោះបីជាការអប់រំនៅតាមតំបន់មួយចំនួន មានការរីកចម្រើនក្នុងឆ្នាំ១៩៧៨ គឺកុមារទទួលបានការសិក្សាថ្នាក់បឋម ពី២ទៅ៣ម៉ោងក្នុងមួយថ្ងៃក៏ដោយ ក៏នៅតែមិនទាន់មានសាលារៀនដែលមានដំណើរការពេញលេញសម្រាប់សិក្សា។ ខ្មែរក្រហមនិយាយថា «អង្គការគ្មានទេសញ្ញាប័ត្រ មានតែសញ្ញាឃើញ។ បើចង់បានបាក់អង បាក់ឌុប ត្រូវទៅយកនៅ ទំនប់ ប្រឡាយ» ឬ «ការរៀនអក្សរ រៀនលេខមិនសំខាន់ទេ ការសំខាន់គឺការងារ និងចលនាបដិវត្តន៍»។ ស្របពេលដែលកុមារត្រូវបានបង្ហាត់បង្រៀនឱ្យចេះអាន និងសរសេរអក្សរបន្តិចបន្តួច ភាគច្រើននៃការអប់រំកុមារទាំងនោះ គឺផ្តោតទៅលើ ការអប់រំនយោបាយ។ ក្មេងៗត្រូវបានជ្រើសរើសឱ្យទៅចូលរួមវគ្គហ្វឹកហ្វឺនមនោគមវិជ្ជា ដើម្បីអាចចូលបម្រើក្នុងជួរកងទ័ព កងការពារ ឬនីរសារបាន។

ក្នុងរបបកម្ពុជាប្រជាធិបតេយ្យ កុមារក៏ត្រូវអង្គការចាត់តាំងឱ្យធ្វើការងារ។ ការងាររបស់កុមារ គឺដើររើសអាចម៍គោ កាត់ទន្រ្ទានខែត្រ ប្រមូលលាមកមនុស្សដើម្បីធ្វើជី និងដឹកជញ្ជូនអាវុធទៅសមរភូមិ។ នៅទីតាំងសមរភូមិកុមារជួនកាលទទួលរងរបួស ឬត្រូវគ្រាប់កាំភ្លើងស្លាប់ក៏មាន។ ជាងនេះទៅទៀត កុមារាកុមារីទាំងនេះត្រូវបំបែកចេញពីឪពុកម្តាយ និងមិនដែលស្គាល់ភាពកក់ក្តៅក្នុងគ្រួសារឡើយ។

កុមារទាំងអស់ត្រូវអង្គការបង្ហាត់បង្រៀនថា «អង្គការគឺជាមាតាបិតារបស់ខ្លួន។ ប្រសិនបើម៉ែឪវាយកូន មានន័យថា មើលងាយអង្គការ ដូច្នេះអង្គការមិនប្រណីឡើយ»។ កម្មាភិបាលខ្មែរក្រហម បានឱ្យកុមារស៊ើបការណ៍ពីឪពុកម្តាយរបស់ខ្លួន ហើយជួនកាលកុមារទាំងនោះហ៊ានសម្លាប់ឪពុកម្តាយបង្កើតរបស់ខ្លួនទៀតផង ប្រសិនបើទទួលបានបញ្ជាពីអង្គការ។ រយៈកាលកន្លងផុតទៅ កុមាររាប់ម៉ឺននាក់បានជឿទៅលើអ្វីដែលអង្គការបានប្រាប់ ហើយគោរពតាមតែបញ្ជារបស់អង្គការតែប៉ុណ្ណោះ។ ក្នុងអំឡុងពេលសង្គ្រាមជាមួយវៀតណាមក្នុងឆ្នាំ១៩៧៧ និងឆ្នាំ១៩៧៨ កងទ័ពខ្មែរក្រហមជាច្រើនបានស្លាប់ ឬរងរបួសជាទម្ងន់។ ខ្មែរក្រហមបានបញ្ជូនកុមារឱ្យទៅសមរភូមិមុខ ដែលនៅទីនោះ កុមាររាប់ពាន់នាក់ត្រូវរងរបួស និងស្លាប់។

តមក ក្រុមការងារមជ្ឈមណ្ឌលឯកសារកោះថ្ម បានលើកយកសាច់រឿងជីវិតពិតរបស់អ្នករស់រានមានជីវិតពីរបបខ្មែរក្រហមឈ្មោះ ម៉ុង ខេន អតីតប្រធានកងកុមារ មករៀបរាប់ប្រាប់សិស្សានុសិស្សដែលមានសេចក្តីសង្ខេបដូចខាងក្រោម៖

ឈ្មោះ **ម៉ុង ខេន** ភេទប្រុស អាយុ៦១ឆ្នាំ មានស្រុកកំណើតនៅភូមិជាំទូក ឃុំរូង ស្រុកមេមត់ ខេត្តកំពង់ចាម។ បច្ចុប្បន្ន ខេន រស់នៅភូមិជាំទូក ឃុំរូង ស្រុកមេមត់ ខេត្តត្បូងឃ្មុំ។ ក្នុងរបបខ្មែរក្រហមអង្គការចាត់តាំង ខេនឱ្យធ្វើជាប្រធានកងកុមារ និងមើលការខុសត្រូវកុមារចំនួន១៥នាក់នៅក្នុងភូមិ។ ខេន គឺជាអ្នកបង្រៀនកុមារពីរបៀបធ្វើជីដាក់ស្រូវ ជីដាក់បន្លែ និងដកស្មៅនៅវាលស្រែ។ នៅពេលដល់ម៉ោងចូលរៀន ខេន និងកុមារក្នុងភូមិត្រូវទៅរៀននៅក្រោមផ្ទះប្រជាជន និងម្លប់ឈើ។ នៅសម័យខ្មែរក្រហម គ្រូរបស់ ខេន តឹងរ៉ឹងណាស់គឺមិនឱ្យសិស្សចម្លងគ្នាឡើយ។ ប្រសិនបើគ្រូឃើញសិស្សក្នុងថ្នាក់ចម្លងគ្នា គឺគ្រូវាយសិស្សនឹងរំពាត់ រួចហើយហៅឪពុកម្តាយសិស្សមកណែនាំបន្ថែម។

តមកក្រុមការងារមជ្ឈមណ្ឌលឯកសារកោះថ្ម បានចាក់បញ្ចាំងខ្សែភាពយន្តឯកសារមានចំណងជើងថា «ក្បង់ទឹកទន្លេ» ឱ្យសិស្សទស្សនា។ ការចាក់បញ្ចាំងខ្សែភាពយន្តនេះ មានគោលបំណងឱ្យសិស្សានុសិស្សចេះរស់នៅផ្សារភ្ជាប់រវាងមនុស្សជាមួយ វប្បធម៌ មុខរបរ និងធម្មជាតិ ព្រោះជាមូលដ្ឋានគ្រឹះនៃតុល្យភាពជីវិត និងការរីកចម្រើនប្រកបដោយចីរភាព។

បន្ទាប់ពីចប់វេទិកាថ្នាក់រៀន សិស្សបានបង្ហាញចំណាប់អារម្មណ៍ដូចខាងក្រោម៖







មជ្ឈមណ្ឌលឯកសារកោះថ្មរៀបចំវេទិកាថ្នាក់រៀនស្តីពី ប្រវត្តិសាស្ត្រកម្ពុជាប្រជាធិបតេយ្យ (១៩៧៥-១៩៧៩) ផ្តោតលើប្រធានបទ ៖ ការរំលោភលើសិទ្ធិ និងពលកម្មកុមារ ដល់សិស្សានុសិស្សចំនួន១៦នាក់មកពីសាលាបឋមសិក្សា ប៊ុនរ៉ានី ហ៊ុនសែន កោះថ្ម នៅព្រឹកថ្ងៃទី១៣ ខែមីនា ឆ្នាំ២០២៦។ (បណ្ណសារមជ្ឈមណ្ឌលឯកសារកម្ពុជា)

**ឆន់ សុវណ្ណរាជ** គឺជាសិស្សថ្នាក់ទី៦ នៃសាលាបឋមសិក្សា ប៊ុនរ៉ានី ហ៊ុនសែន កោះថ្ម លើកឡើងថា «ខ្ញុំពិតជាមានអារម្មណ៍រីករាយជាខ្លាំងដែលបានចូលរួមទស្សនាពិព័រណ៍អំពីរបបកម្ពុជាប្រជា-ធិបតេយ្យ ដែលមានរូបថតរបស់ប្រជាជនធ្វើការងារវែកដី និងរូបថតប្រជាជនកម្ពុជាវិលត្រឡប់មកស្រុកកំណើតវិញបន្ទាប់ពីរបបខ្មែរក្រហមដួលរលំ នៅឆ្នាំ១៩៧៩។ ខ្ញុំចាប់អារម្មណ៍ខ្សែភាពយន្តឯកសាររឿង«ក្បង់ទឹកទន្លេ» ដែលបង្ហាញអំពីជីវភាពប្រជាជននៅតាមតំបន់ផ្សេងៗ ការគោរពប្រពៃណីរបស់ជនជាតិដើមភាគតិច និងរបៀបធ្វើកសិកម្មបុរាណ។ ទាំងអស់នេះគឺជាចំណេះដឹងថ្មីដែលខ្ញុំទទួលបាន»។

**វ៉ែម ស្រីមុំ** គឺជាសិស្សថ្នាក់ទី៦ នៃសាលាបឋមសិក្សា ប៊ុនរ៉ានី ហ៊ុនសែន កោះថ្ម រៀបរាប់ថា «ថ្ងៃនេះខ្ញុំត្រេកអរខ្លាំងណាស់ដែលបងៗក្រុមការងាររបស់មជ្ឈមណ្ឌលឯកសារកោះថ្ម អនុញ្ញាតឱ្យខ្ញុំចូលរួមទស្សនារូបពិព័រណ៍ក្នុងមជ្ឈមណ្ឌលឯកសារកោះថ្ម និងបានចាក់បញ្ចាំងខ្សែភាពយន្តឯកសាររឿង «ក្បង់ទឹកទន្លេ» ឱ្យខ្ញុំទស្សនា។ លើសពីនេះ បងៗក្រុមការងារមជ្ឈមណ្ឌលឯកសារកោះថ្ម បានណែនាំអំពីរូបថត និងរូបគំនូរនៃពិព័រណ៍ក្នុងរបបខ្មែរក្រហមឱ្យខ្ញុំបានដឹង។ ខ្ញុំពិតជាអរគុណណាស់ ចំពោះបងៗដែលបានរៀបចំវេទិកាថ្នាក់រៀនក្នុងថ្ងៃនេះ។

# ការិយាល័យព័ត៌មានសាធារណៈ













«ការិយាល័យព័ត៌មានសាធារណៈ» របស់មជ្ឈមណ្ឌលឯកសារកម្ពុជាបានបើកបម្រើជូន សិស្ស និស្សិត អ្នកសិក្សាស្រាវជ្រាវ បុគ្គលិករាជការ និងអង្គការក្រៅរដ្ឋាភិបាល និងបុគ្គលទាំងឡាយដែលមានចំណាប់អារម្មណ៍អំពីការវិវឌ្ឍន៍របស់អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា ឬសាលាក្តីខ្មែរក្រហម។

មជ្ឈមណ្ឌលឯកសារកម្ពុជាជាកន្លែងប្រមូលផ្តុំ និងចងក្រងឯកសារអំពីរបបកម្ពុជាប្រជាធិបតេយ្យបានច្រើនបំផុត។ ឯកសារនៅមជ្ឈមណ្ឌលឯកសារកម្ពុជាមានប្រាំប្រភេទ។ ប្រភេទឯកសារទីមួយគឺឯកសារជាក្រដាសស្នាមដែលមានចំនួនជិតមួយលានទំព័រ។ ប្រភេទឯកសារទីពីរ គឺជាបទសម្ភាសន៍ដែលបុគ្គលិកមជ្ឈមណ្ឌលឯកសារកម្ពុជាចុះទៅធ្វើសម្ភាសន៍ជាមួយជនរងគ្រោះ និងអតីតកម្មាភិបាលខ្មែរក្រហម។ ប្រភេទឯកសារទីបីគឺជារូបថតទាក់ទងទៅនឹងសម័យខ្មែរក្រហម។ ប្រភេទឯកសារទីបួនគឺជាឯកសារទាក់ទងទៅនឹងការធ្វើផែនទីរណ្តៅសាកសព និងទីតាំងសម្លាប់របស់ខ្មែរក្រហម និងឯកសារទីប្រាំគឺជាខ្សែភាពយន្តឯកសារដែលបានផលិតឡើងក្នុងរបបខ្មែរក្រហម និងសម័យក្រោយមកទៀត។

តាមរយៈការិយាល័យព័ត៌មានសាធារណៈ សាធារណជនអាចស្រាវជ្រាវឯកសារទាំងនេះបាន។ ឯកសារខ្លះទៀតរួមមាន៖ ប្រវត្តិរូបកម្មាភិបាលខ្មែរក្រហម ចម្លើយសារភាព កំណត់ហេតុរបស់បក្សទូរលេខឆ្លើយឆ្លងព័ត៌មានដែលបានមកពីការសម្ភាសន៍ជាមួយអតីតកម្មាភិបាលខ្មែរក្រហម និងទិន្នន័យគន្លងនិទ្ទេសបង្ហាញពីរណ្តៅសាកសព ទីតាំងគុក និងបូជនីយដ្ឋានប្រល័យពូជសាសន៍។

ការិយាល័យព័ត៌មានសាធារណៈមានទីតាំងនៅអគារលេខ ១១ ផ្លូវលេខ ២៥៦ សង្កាត់ចតុមុខ ខណ្ឌដូនពេញ រាជធានីភ្នំពេញ។ ការិយាល័យរបស់យើងបើកជូនសាធារណជនចាប់ពីថ្ងៃចន្ទដល់ថ្ងៃសុក្រ ពេលព្រឹកពីម៉ោង ៨៖០០ ដល់ម៉ោង ១២៖០០ និងពេលរសៀលពីម៉ោង ២៖០០ ដល់ ម៉ោង ៥៖០០។ ប្រសិនបើអស់លោកអ្នកមានចម្ងល់ ឬចង់រៀបចំព្រឹត្តិការណ៍ជាក្រុមណាមួយ សូមទាក់ទងបុគ្គលិករបស់យើង រស់ សំពៅ អ្នកសម្របសម្រួល តាមរយៈទូរសព្ទលេខ៖ ០១២ ៨៨២ ៥០៥ ឬ

អ៊ីម៉ែល ៖ truthsampeou.r@dccam.org

សូមអរគុណ!














# ប្អូនប្រុសដែលបាត់ខ្លួន

ស្រ៊ាង លីហ្វារ



រូបថត ដួង ឌឿន នៅមន្ទីរសន្តិសុខ ស-២១ ក្នុងឆ្នាំ១៩៧៨។ (បណ្ណសារមជ្ឈមណ្ឌលឯកសារកម្ពុជា)

នៅពេលមេឃភ្លៀង បងស្រីរបស់ ឌឿន តែងតែនឹកឃើញគ្រាដែល ឌឿន នាំប្រពន្ធកូនមកលេង និងជួបជុំគ្រួសារ នៅមុនពេលរបបខ្មែរក្រហមឡើងកាន់អំណាច។ ឌឿនបានឈប់រៀនត្រឹមថ្នាក់ទី៧ ពីសង្គមចាស់ ហើយត្រឡប់មកធ្វើស្រែជាមួយឪពុកម្តាយ។ ឌឿន បានរៀបការប្រពន្ធឈ្មោះ ឈឿ គឺជាជាងកាត់ដេរខោអាវនៅឃុំល្វា ស្រុកបវេល ខេត្តបាត់ដំបង ក្នុងឆ្នាំ១៩៧៣ និងបានរស់នៅខាងប្រពន្ធ។ ឌឿន មានកូនបីនាក់ ក្នុងនោះមានស្រីម្នាក់ និងប្រុសពីរនាក់។ ក្រោយមក ម្តាយរបស់ ឌឿនបានហៅគ្រួសារ ឌឿនមករស់នៅភូមិបវេលវិញ។

នៅដើមឆ្នាំ១៩៧៥ ពេលកងទ័ពខ្មែរក្រហមចូលក្នុងភូមិបវេល ឌឿន បានបែកគ្នាជាមួយបងប្អូននិងឪពុកម្តាយ។ បងស្រីរបស់ ឌឿន និងឪពុកម្តាយ បានភៀសខ្លួនពីភូមិបវេលទៅអាងកំពីងពួយ ជិតភ្នំជ្រោយស្វា ដើម្បីគេចពីគ្រាប់ផ្លោង។ ចំណែក ឌឿន បានរត់ភៀសខ្លួនទៅអង្គរបូរី ជាមួយប្រពន្ធ ប៉ុន្តែគាត់តែងតែនាំប្រពន្ធកូនមកលេងបងប្អូន និងឪពុកម្តាយ។

ឌឿន ធ្វើការក្នុងកងសេដ្ឋកិច្ច និងមានតួនាទីនេសាទត្រីដើម្បីផ្គត់ផ្គង់កម្មករនៅការដ្ឋាន។ ឌឿនធ្វើការជាមួយកម្មាភិបាលខ្មែរក្រហមម្នាក់ឈ្មោះ តាអេង គណៈឃុំបវេល ស្រុក៧០ តំបន់៣។ នៅឆ្នាំ១៩៧៨ពេលឌឿនទៅយកត្រីនៅឃុំគោកសង្កែ ឌឿន បានឃើញ តាអេង ប្រព្រឹត្តខុសសីលធម៌ជាមួយមិត្តនារីខ្មែរក្រហមម្នាក់។ ពេលនោះ តាអេង ហាមឃាត់ ឌឿន មិនឱ្យនិយាយរឿងនេះទេ។ ដំបូង ឌឿន បានស្តាប់ តាអេង និងមិនហ៊ាននិយាយប្រាប់នរណាទាំងអស់សូម្បីតែប្រពន្ធកូនរបស់ខ្លួន។ ប៉ុន្តែ ក្រោយមក ឌឿនបានប្រាប់មិត្តភក្តិរួមការងាររបស់ខ្លួនពីអំពើខុសសីលធម៌របស់ តាអេង។ មិនយូរប៉ុន្មាន យាយសាត គឺជាប្រធានកងសេដ្ឋកិច្ចបានដឹងរឿងរបស់តាអេង។

នៅយប់នោះពេលឌឿនកំពុងធ្វើការ យាយសាតបានហៅ ឌឿនទៅទិសខាងត្បូង។ ឌឿន ស្លៀកខោពណ៌ប្រផេះ និងមានយោធាខ្មែរក្រហមបើកឡានមកដឹក ឌឿន សំដៅទៅផ្តល់បំបែក មុខសាលាឃុំបវេល ដែលជាទីតាំងមន្ទីរសន្តិសុខ និងជាកន្លែងសម្លាប់មនុស្ស។ តាំងពីពេលនោះមក ហឿន មិនដែលឃើញ ឌឿន ត្រឡប់មកផ្ទះវិញទេ។ ចំណែកប្រពន្ធរបស់ឌឿនត្រូវទៅធ្វើការទាំងនៅសរសៃខ្ចីព្រោះទើបតែសម្រាលកូនបានតែប៉ុន្មានខែតែប៉ុណ្ណោះ។ ហឿនបានបន្តថា ទោះបីជាប្រពន្ធរបស់ ឌឿន ដឹងថាប្តីបាត់ខ្លួនក៏មិនហ៊ានយំសោក។

យោងតាមឯកសារប្រវត្តិរូបរបស់អ្នកជាប់ឃុំឃាំងនៅមន្ទីរសន្តិសុខ ស-២១ ចុះលេខ K00២០៤ នៅមជ្ឈមណ្ឌលឯកសារកម្ពុជា រៀបរាប់អំពីឈ្មោះ ដួង ឌឿន ភេទប្រុស មានកម្ពស់១,៦៣ម៉ែត្រ និងប្រវែងដងខ្លួន ០,៨៥ម៉ែត្រ មានអាយុ៣២ឆ្នាំ នៅថ្ងៃចាប់ខ្លួន។ ឌឿន មានឪពុកឈ្មោះ អ៊ិត ដួង និងម្តាយឈ្មោះ មាន គឺជាកសិករ។ ឌឿនមានទីកន្លែងកំណើតនៅភូមិបវេល ឃុំបវេល ស្រុកបវេល ខេត្តបាត់ដំបង។ នៅក្នុងរបបខ្មែរក្រហម ឌឿន ធ្វើការ និងរស់នៅភូមិភាគពាយ័ព្យ តំបន់៥៦០ ភូមិបវេល ឃុំបវេល ស្រុកបវេល ខេត្តបាត់ដំបង។ ឌឿន ត្រូវបានខ្មែរក្រហមឃាត់ខ្លួននៅថ្ងៃទី២១ ខែមីនា ឆ្នាំ១៩៧៨ និងឃុំខ្លួននៅផ្ទះ៤៣ បន្ទប់ធំ១។ ឌឿនមានប្រពន្ធឈ្មោះ ស ឈឿ។

## អំពីបងស្រីរបស់ខឿនៈ

ដួង ហឿន មានអាយុ៦៣ឆ្នាំ (ក្នុង ២០០៦) ត្រូវជាបងស្រីរបស់ឈ្មោះ ដួង ខឿន ដែលបានបាត់ខ្លួននៅឆ្នាំ ១៩៧៨។ ហឿនមានស្រុកកំណើត និងរស់នៅភូមិបវេល១ ឃុំបវេល ស្រុកបវេល ខេត្តបាត់ដំបង។ សព្វថ្ងៃ ហឿន ប្រកបរបរលក់នំបត់ និងនំផ្អែម។ ហឿន មានប្ដីឈ្មោះ ហោ ឈួន គឺជាអតីតទាហាន លន់ នល់ ពាក់ស័ក្តិបី។ ឪពុករបស់ ហឿន ឈ្មោះ ដួង និងម្ដាយឈ្មោះ ជុច ហម។ ហឿនមានបងប្អូនបីនាក់ គឺទី១) ឈ្មោះ ដួង ហឿន, ទី២) ឈ្មោះ ដួង ខឿន, និងទី៣) ឈ្មោះ ដួង ដឿន ស្លាប់ឆ្នាំ១៩៧៣ ដោយសារជំងឺ។ នៅឆ្នាំ១៩៧០ ហឿន បានមករស់នៅទីក្រុងភ្នំពេញមួយរយៈជាមួយប្ដី។ នៅឆ្នាំ១៩៧២ ប្ដីរបស់ ហឿន បានស្លាប់ក្នុងសមរភូមិ នៅខេត្តកំពង់ឆ្នាំង ដោយបន្សល់ទុកកូនបីនាក់។

នៅក្នុងរបបខ្មែរក្រហម ហឿន ត្រូវបានខ្មែរក្រហមចាត់ទុកគាត់ថាជាប្រជាជន១៧ មេសា និងចាត់តាំងឱ្យធ្វើការក្នុងកងពិសេស (ធ្វើការងារធ្ងន់) ព្រោះគាត់មានប្ដីធ្វើជាទាហាន លន់ នល់។ ខ្មែរក្រហមបានបង្ខំ ហឿនឱ្យធ្វើពលកម្មហួសកម្លាំង ថែមទាំងចោទគាត់ថាមានជំងឺសតិអារម្មណ៍។ ហឿន ត្រូវធ្វើការ ទាំងមានផ្ទៃពោះ និងហូបមិនបានគ្រប់គ្រាន់ គឺហូបតែបបររាវលាយជាមួយពោត និងកន្ទក់។ ហឿន បានរស់នៅ និងធ្វើការបែកពីឪពុកម្ដាយ ចំណែកបងប្អូនត្រូវទៅធ្វើការងារនៅកងផ្សេងៗគ្នា។

បន្ទាប់ពីរបបខ្មែរក្រហមដួលរលំនៅឆ្នាំ១៩៧៩ ហឿន តែងតែស្ដាប់ព័ត៌មានប្រកាសតាមវិទ្យុស្វែងរកសាច់ញាតិដែលបាត់ខ្លួនក្នុងរបបខ្មែរក្រហមដើម្បីស្វែងរកដំណឹងប្អូនប្រុសឈ្មោះ ខឿន។ ក្រោយមកទើប ហឿន ទទួលព័ត៌មានពីមិត្តភក្តិរបស់ ខឿន ដែលរស់នៅបរទេសថា ខឿន ត្រូវបានខ្មែរក្រហមចាប់ខ្លួន និងបញ្ជូនទៅឃុំឃាំងនៅមន្ទីរសន្តិសុខស-២១ ព្រោះ ខឿន បានដឹង"រឿងរ៉ាវរបស់គណៈឃុំបវេលឈ្មោះ តាអេង ដែលប្រព្រឹត្តខុសសីលធម៌។ ហឿន បានសរសេរសំបុត្រទៅសួរ តាអេង ដែលរស់នៅជំរំ ប៉ុន្តែ តាអេង បានបដិសេធមិនផ្ដល់ព័ត៌មានឡើយ។



ជនរងគ្រោះនៅមន្ទីរសន្តិសុខស-២១ ប្តុកក ទួលស្លែង។ (បណ្ណសារមជ្ឈមណ្ឌលឯកសារកម្ពុជា)

# ជាតិនេះ ខ្ញុំបិះតែនឹងស្លាប់ចំនួន១៤លើក

សៀវ សុផុន



សៀវ សុផុន បួសជាព្រះសង្ឃនៅវត្តល្វា អំឡុងឆ្នាំ១៩៧០ និងឆ្នាំ១៩៧១។ (បណ្ណសារមជ្ឈមណ្ឌលឯកសារកម្ពុជា)

## ក្រយៅបាតដៃម្ដាយថ្លៃ កូនប្រុសត្រូវតែរស់

ទោះជាយ៉ាងណាក៏តែងមានមនុស្សយើង ដេកស្លាប់ម្តងម្កាល នេះគឺឧបសគ្គតែងកើតមានសឹងតែគ្រប់ជំហាន ដែលបណ្ដាលឱ្យជីវិតខ័យ គ្រប់តែដង្ហើមចេញចូល ដោយពុំកំណត់ទីកន្លែងស្លាប់នោះទេ សូម្បីតែបន្លាព្រៃទាំងឡាយគឺវាដុះដើម្បីការពារខ្លួនវា មានដូចជាដើមផ្ដៅ ឬរពាក់.....គឺបន្លារបស់វាស្រួចងខ្វង ដូចចំពុះសត្វសេក ហើយដុះបញ្ច្រាសឬឱបមកក្រោម និងដុះនៅលើដើមធាង និងស្លឹកវា ដែលមានភាពងាយស្រួលបំផុត ក្នុងការចាក់ទម្លុះសាច់មនុស្ស ឬមុតដាច់ក្រណាត់សំពត់សាច់ខោ កាលបើយើងដើរទៅកោសឬរូសដើមរបស់វាតែបន្តិចៗ បើសិនជាបន្លារបស់វាង ឡើងលើវិញ ម៉្លេះសមពុំមានចោទជាបញ្ហាដូចខាងលើនេះឡើយ គឺនេះឯងហើយដែលហៅថា មច្ចុរាជដ៏តូចមួយសោះ ពុំចេះអាណិតស្រណោះមកដល់ជីវិតរបស់សត្វលោកណាឡើយ។ សូម្បីមនុស្សឈឺដេកនៅលើគ្រែទៅហើយក្ដីជំងឺនោះមកញាំញីឥតឈប់ឈរ ទោះបីស្រែកថ្ងូរយ៉ាងណាក៏ពុំត្រាប្រណីយើងម្ដងណាឡើយ គឺវាយលុកទន្ទ្រានលុះត្រាតែជីវិតបង់ទើបព្រលែងដៃចោលវិញ។ ម្យ៉ាងទៀតកាលបរិច្ឆេទស្លាប់គឺពុំរើសពេលវេលានៃការស្លាប់ អាចមាននៅក្នុងពេលបច្ចុប្បន្នកាល អតីតកាល និងអនាគតកាល ហើយការស្លាប់នេះទៀតសោតក៏មានច្រើនប្រភេទទៀតដូចជា ដោយតាយហោង ដោយគ្រឿងអាវុធយុទ្ធភ័ណ្ឌ ឬ ដោយជំងឺជាដើម។ល។

## ខ្ញុំត្រូវបានប្រឈមនិងការបាត់បង់សង្ខារ អស់ចំនួន១៤ដង

រីចំណែកការស្លាប់នៅក្នុងបរិបទនៃរឿងរ៉ាវដែលលើកយកមកសរសេរគឺតាមបែបរួចផុតពីស្លាប់ ភ្លាមៗក្នុងមួយប៉ប្រិចភ្នែកតែប៉ុណ្ណោះ និងមួយបែបវិញទៀត គឺចេញផុតពីអ្នកទាំងអស់គ្នានោះមកហើយ ខ្ញុំទើបទទួលដំណឹងក្រោយឆ្នាំ១៩៧៩ ច្បាស់ការថាមនុស្សទាំងអម្បាលម៉ាន ដែលខ្ញុំបាទធ្លាប់រស់នៅជ្រកកោនជាមួយ គឺត្រូវបានខ្មែរក្រហមសម្លាប់ចោល ទាំងអស់គ្នានៅសេសសល់ឱ្យបានម្នាក់ណាឡើយ។ ពុំនោះទេដូចពាក្យសាមញ្ញមួយឃ្លា ដែលតែងលើកជារឿយៗមកថា សំណាងមួយក្នុង១០០គ្រោះថ្នាក់! ចុះបើតួអង្គនៅក្នុងសៀវភៅនេះមានសំណាងបានរស់ដល់ទៅ១៤លើក គឺក្នុងចំណោមគ្រោះថ្នាក់១៤x១០០=១,៤០០គ្រោះថ្នាក់(មួយពាន់បួនរយគ្រោះថ្នាក់) តើពិតដែរទេ? ដូច្នេះយើងអាចធ្វើសំយោគសរុបមកវិញ បានសេចក្ដីថា សំណាងខ្ញុំមួយក្នុងចំណោម១៤០០គ្រោះថ្នាក់។ អនុញ្ញាតគោរពមកដល់អស់លោកអ្នកដែលបានអានសាច់រឿងនៅក្នុងសៀវភៅនេះរួចរាល់ទាំងស្រុងអស់ហើយនោះ សូមមេត្តាពិចារណាទៅដោយគតិយុត្តិរៀងៗខ្លួន ថាតើឧបទ្ទវហេតុឬគ្រោះថ្នាក់ដែលកើតមានក្នុងកម្រិតដូចខាងក្រោមនេះ នៅក្នុងវគ្គនីមួយៗនោះ គឺស័ក្តិសមនឹងរូបខ្ញុំបាទត្រូវស្លាប់ដែរឬទេ?

## លើកទី១៖ នៅក្នុងក្រុងសៀមរាប ជំនាន់ លន់ នល់ (១៩៧០-១៩៧៥)

នៅឆ្នាំ១៩៧០ ទាហានវៀតណាមខាងជើងឬឈ្មោះដែលគេហៅជាទូទៅថា យួនយៀកកុងត្រូវបានចូលមកវាយបែកបន្ទាយប៉ូលិសនៅដំដែកក្នុងស្រុកសូទ្រនិគម ខេត្តសៀមរាប។ ទន្ទឹមគ្នានោះ អតីតសាលារៀនអនុ-វិទ្យាល័យដំដែក ដែលសព្វថ្ងៃហៅថាវិទ្យាល័យដំដែកគឺត្រូវបានបិទទ្វាររត់ចោលសិស្សជាស្ថាពរ។ សម្មាញ់សានដារាវង្ស ហៅ វណ្ណា បានរត់ចូលទៅក្នុងក្រុងសៀមរាប និងបន្តទៅរស់នៅឯរាជធានីភ្នំពេញ ព្រោះមានបងបង្កើតប្រុសស្រី ធ្វើការងាររដ្ឋនៅ

ទីកន្លែងភ្នំពេញស្រាប់ៗ ដោយ វណ្ណា មានបងប្រុសម្នាក់ឈ្មោះលោកវរសេនីយ៍ទោ អាំង គឹមសន ជានាយទាហានមួយរូបៗ វណ្ណា ស្ម័គ្រចិត្តចូលធ្វើជាយុទ្ធជននៅក្នុងអង្គភាពយោធាមួយនៃរបបសាធារណរដ្ឋខ្មែរ គឺលោកវរសេនីយ៍ត្រី ឡាច សឿម ជាមេបញ្ជាការៗ នៅចុងឆ្នាំ១៩៧០ និងដើមឆ្នាំ១៩៧១ ពេទ្យទាហានដែលមានឈ្មោះ វណ្ណា ដូចខាងលើនេះ បានទៅហាត់ក្បួនយុទ្ធសាស្ត្រនៅ ឡាំស៊ីង ប្រទេសវៀតណាមខាងត្បូង អស់រយៈពេលបីខែ ត្រូវបានបញ្ចប់វគ្គសិក្សាទាំងស្រុងៗ លុះត្រឡប់មកកាន់រដ្ឋធានីភ្នំពេញវិញ គឺត្រូវគ្នានឹងពេលនៃការធ្វើប្រតិបត្តិការសឹក ចេនឡា ទី២ គឺដើម្បីបើកផ្លូវជាតិលេខ៦ ពីភ្នំពេញទៅកាន់កំពង់ធំៗ កាលនោះនៅលើថ្នល់ជាតិលេខ៦ នៅត្រង់ចំណុចស្ពានអូរដា មានការតតាំងគ្នាមួយយ៉ាងស្វិតស្វាញរហូតដល់ទៅពីរយប់ និងបីថ្ងៃមកហើយ នៅតែពុំអាចបើកផ្លូវបានទៀត ដូច្នេះអង្គភាពទ័ពរបស់លោកវរសេនីយ៍ត្រី ឡាច សឿម ត្រូវបានទទួលបទបញ្ជាបេសកកម្ម ឱ្យឡើងទៅជួយអន្តរាគមជាបន្ទាន់ភ្លាមៗ។ ក្រោយពីបើកក្បួនយុទ្ធសាស្ត្រចេញជួយអន្តរាគមន៍ នៅក្នុងទ្រង់ទ្រាយធំប្រកបដោយជោគជ័យ និងបានដល់គោលដៅហើយនោះសំឡេងផ្ទុះអាវុធរវាងខ្មែរក្រហមនិងទាហាន លន់ នល់ ផ្ទុះឡើងទ្រហឹងទាំងគ្រាប់តូចនិងធំ ហើយ វណ្ណា បានស្ពាយឧបករណ៍ពេទ្យទាហាន, កាំភ្លើង និងគ្រាប់រំសេវពេញខ្លួនទាំងអស់ដើម្បីចូលរួមក្នុងការប្រយុទ្ធយ៉ាងពេញទំហឹងៗ បន្តិចក្រោយមក វណ្ណា បានដើរចាកចេញពីលោកមេបញ្ជាការអង្គភាពដើម្បីបំពេញតួនាទីរបស់ខ្លួនគឺក្រាបផងលូនផង ដើម្បីចូលមើលកម្លាំងទាហានដែលកំពុងប្រយុទ្ធនៅតាមបណ្ដាលេណដ្ឋានក្រែងមានរងរបួសផ្សេងៗ ដោយគ្រាប់រំសេវដោយថាហេតុៗ ធ្វើសកម្មភាពបែបនេះបណ្ដើរ និងមានការសង្ស័យបណ្ដើរថា ហេតុដូចម្ដេចបានជានៅម្ដុំចង្កេះរបស់ខ្លួនរាងឈឺផ្សាៗបែបនេះ? មិនអស់ចិត្តយកដៃឆ្វេងខ្លួនឯងស្រវាស្ទាបមកក្រោយខ្នងបន្តិច ស្រាប់តែមានធ្លុះសាច់សំពត់អាវត្រែអ៊ី ប៉ុនកូនដៃ ហើយយកមកហិតនឹងច្រមុះមើលស្រាប់តែធុំក្លិនឈាមហើយឈ្វៀមទៀតផងៗ លុះប្រយុទ្ធគ្នារួចរាល់ ទើបសហការីយើងជួយបើកអាវមើលទៅ គឺពិតជាត្រូវរងនឹងអំបែងគ្រាប់អេក្លាឆាសបន្តិច ហើយគ្រាន់តែរលាត់ស្បែក និងមានឈាមចេញមករុមៗតែប៉ុណ្ណោះៗ

នៅរដូវរំហើយក្នុងឆ្នាំ១៩៧២ ខ្ញុំបាទ សៀវ សុផុន (១៩ឆ្នាំ) រួមជាមួយមិត្តសម្លាញ់ សាន ដារាវង្ស ហៅ វណ្ណា (២០ឆ្នាំ) ជាទម្លាប់គឺតែងបបួលគ្នាជិះកង់ម្នាក់មួយគ្រឿងដើរលេងផ្លូវទៅភ្នំក្រោម ហើយជួនកាលកង់មួយគ្រឿងជិះឌុបគ្នាពីរនាក់ ព្រមទាំងជិះបណ្ដើរដូរគ្នាជិះឌុបពីមុខទៅក្រោយ និងពីក្រោយទៅមុខបណ្ដើរ នៅលើកង់ម្ដងម្នាក់ ដោយពុំមានចុះពីលើកង់សោះឡើយ ហើយបានក្លាយទៅជាទម្លាប់យ៉ាងស្ទាត់ជំនាញទៀតផងៗ ឬបើពុំនោះទេយើងចេញពីក្រុងទៅលេងនៅទិសខាងជើង គឺអាចទៅបានត្រឹមតែស្អាតចាស់ ព្រោះផ្លូវទៅអង្គរវត្តត្រូវកាត់ផ្ដាច់ដោយខ្មែរក្រហមកាន់កាប់ និងនៅលើផ្លូវជាតិលេខ៦ ឆ្ពោះទិសខាងកើត យើងអាចទៅបានដោយដើរបានត្រឹមតែរោងម៉ាស៊ីនអារឈើ សូគី ហៅសូកាយ ឬភោជនីយដ្ឋានអាប៉ូ ឡូបូស្រា សព្វថ្ងៃនេះតែប៉ុណ្ណោះៗ ទេសកាលនៅរសៀលថ្ងៃនោះចៃដន្យបំផុតមួយ គឺយើងមានម៉ូតូឌុនចាស់មួយគ្រឿងម៉ាក សាស់ Sechs ជិះឌុបគ្នាពីរនាក់ចេញពីក្រុងសៀមរាបឆ្ពោះទៅទិសខាងលិចដោយជិះនៅលើផ្លូវជាតិលេខ៦ ដែលការពារផ្លូវដោយទាហាននៃរបបសាធារណរដ្ឋខ្មែរ ហើយនៅលើដងផ្លូវនេះ យើងអាចធ្វើដំណើរបានរហូតទៅដល់ខេត្តបាត់ដំបងៗ ស្របគ្នានោះតែងមានទ័ពខ្មែរក្រហមចេញមកពួនស្ទាក់បាញ់ ឡាននៅម្ដុំត្រង់វត្តប្រាសាទ គឺខាងលិចស្រុកពួកបន្តិចៗ ម៉ូតូយើងចេញផុតក្រុងមួយសន្ទុះមកនៅតាមចិញ្ចើមផ្លូវជាតិគឺពុំមានផ្ទះសម្បែងប្រជាជននោះទេ គឺមានតែព្រៃរបោះៗ ដែលដុះនៅត្រង់នេះបន្តិចត្រង់នោះបន្តិច ហើយពុំសូវមានគេធ្វើដំណើរដែរ តែប្រកបទៅដោយសុវត្ថិភាពល្អ ពុំសូវមានក្ដីបារម្ភអ្វីច្រើនពេកដែរៗ ពេលមកដល់ភូមិគោកប៉ាទ្រី ពួកយើងពិតជាស៊យខ្លាំងណាស់ ព្រោះម៉ូតូបានខូចរលត់ម៉ាស៊ីនដោយឯកឯង យើងបណ្ដើរម៉ូតូមកឈប់ស្របគ្នា នឹងចិញ្ចើមថ្នល់ជាតិនៅខាងស្ដាំដៃខ្លួនហើយ មិត្តវណ្ណា ស្រាយយកកូនសោមកជួសជុលម៉ូតូ ហើយទន្ទឹមគ្នានោះខ្ញុំបាទបានប្រាប់ទៅសម្លាប់ថា ខ្ញុំទៅបន្ទោបង់បសាវៈ (នោម) នៅដុបព្រៃខាងជើងនេះបន្តិចៗ លុះដើរជិតទៅដល់គោលដៅហើយនោះ គឺពុំទាន់ទាំងបានរូតឡេវខោចុះផង ស្រាប់តែសម្លាញ់វណ្ណា បានស្រែកហៅឈ្មោះខ្ញុំយ៉ាងរន្ធើនជាប់ៗគ្នាថា ផុន! ផុន! ឈប់សិន! ឈប់សិន!..។ លុះខ្ញុំក្រឡេកភ្នែកមើលទៅកាន់សំឡេងនោះ ស្រាប់តែឃើញមនុស្សម្នាក់ទៀត ដែលជាទាហាននៃរបបសាធារណរដ្ឋខ្មែរ ស្លៀកខោជើងវែងពណ៌ត្រែអ៊ី មានសាំងទៀរ៉ុងក្រវាត់ជាប់នឹងចង្កេះ និងពាក់មួកកន្ទិបយោធា តែពុំមានពាក់អាវទេ បានរត់ត្រហេបត្រហប នៅលើថ្នល់ជាតិលេខ៦ ពីកើតមកលិច ហើយបានលើកដៃទាំងពីរខ្ពស់ឡើងលើ ដោយបក់ហៅទាំងសន្ធាន គឺបក់ហើយបក់ទៀត ព្រមទាំងស្រែកយ៉ាងខ្លាំងផងថា ឈប់សិនៗ គ្រាប់មីនៗ ឈប់ៗ...។ រំពេចនោះ ខ្ញុំស្រឡាំងកាំង

ខ្លាំងណាស់ ទប់ជើងទាំងពីរង៉ក់ នៅទ្រឹងមួយកន្លែងភ្លាម បែរមើលទៅខាងមុខវិញយ៉ាងរហ័ស ម្ចាស់ថ្លៃអើយ! គឺពិតជាខ្សែមីនបង្កប់មានទំហំប៉ុនដើមរពាក់ និងស្ថិតនៅចំពីមុខជើងខ្ញុំចម្ងាយមិនដល់១ម៉ែត្រផង បានលាតសន្ធឹងសម្ដែងកាត់ពីមុខ ដោយបន្ទំគ្នានឹងជើងដើមដុបទន្ទ្រានខែត្រៗ ពេលនោះរូបរាងកាយរបស់ខ្ញុំ ពុំហ៊ានកម្រើកបន្តិចណាទេ គឺមានសភាពដូចរូបចម្លាក់ តែបានមៀងភ្នែកសសៀរៗលួចមើលបន្តិចដែរ ដោយសម្លឹងសួរដេញស្រាវតាមខ្សែមីននោះបន្តទៅមុខទៀត ទើបឃើញគ្រាប់ផ្ទុះច្បាស់នឹងភ្នែកគឺជាមីនប្រភេទក្លេម៉រ ពណ៌បៃតងចាស់មួយគ្រាប់ ម៉ាក យូ.អេស.អេ មានជើងទម្របីរាងកោងដូចវង់ខែ និងទំហំជិតប៉ុនសន្លឹកក្រដាសរ៉ាម ព្រមទាំងបែរមុខតម្រង់មកចំរូបខ្ញុំតែម្ដង ដែលមានចម្ងាយប្រមាណជា៣ម៉ែត្រប៉ុណ្ណោះពីយុវជនរបស់យើង។ ក្រោយពីបានធ្វើការវកិច្ច គោរពដឹងគុណដល់បងជាយោធារូបនោះរួចមក លោកបាននិយាយប្រាប់យើងថា មីន ប្រភេទនេះបើសិនជាផ្ទុះវិញគឺរកសាច់មនុស្សយកមកធ្វើបុណ្យពុំបានផង។ សោកស្ដាយខ្លាំងណាស់ ដោយកាលនោះយើងល្ងង់ព្រោះនៅក្មេងពេកសូម្បីតែពាក្យថា អរគុណ និងឈ្មោះរបស់គាត់ពុំបានទាំងសុំយកមកទុកផង ហើយប្រសិនបើជាបងប្រុសរូបនោះ លោកត្រូវបានអស់ជីវិត ដោយស្នាដៃនៃរបបខ្មែរក្រហមពិតមែន ខ្ញុំសូមធ្វើការឧទ្ទិសកុសលផលបុណ្យរបស់ខ្ញុំដែលមានទាំងអម្បាលម៉ាន តាមរយៈសៀវភៅនេះជូនទៅដល់ដួងវិញ្ញាណក្ខន្ធរបស់លោក សូមឱ្យបានដល់សុគតិភពកុំបីឃ្លៀសឃ្លាតឡើយ។ ថ្វីត្បិតតែសម្លាញ់ វណ្ណស្ថិតនៅរាងប្រយោលបន្តិចពីគ្រាប់មីននោះក្ដី ក៏ប៉ុន្តែទឹកមុខរបស់គេស្លេកស្លាំងដូចគ្នាដែរ ព្រោះមីនបង្កប់នេះមិនត្រឹមតែមានកម្លាំងខ្លាំងប៉ុណ្ណោះទេ គឺថែមទាំងមានអំបែងអេក្លាយ៉ាងច្រើនស្អេកស្កះទៀតផង។ យើងទាំងពីរនាក់បណ្ដើរម៉ូតូ ដោយប្ដូរវេនគ្នាម្ដងម្នាក់ គឺបកក្បាលត្រឡប់ចូលមកកាន់ ក្រុងសៀមរាបវិញ។ លុះបណ្ដើរម៉ូតូអូសមកបានឆ្ងាយបន្តិច មានរ៉ឺម៉ុកម៉ូតូរត់.ដ. មួយគ្រឿងទំនេរ បើកបរពីក្រោយយើងមក ហើយបានហៅគាត់ឱ្យជួយដឹក ទាំងមនុស្សនិងម៉ូតូត្រឡប់ចូលមកក្នុងក្រុងវិញ។ អង្គុយលើរ៉ឺម៉ុកម៉ូតូពិតមែន តែអារម្មណ៍គឺស្ថិតនៅក្នុងហេតុការណ៍អម្បាញ់មិញនេះ ទាំងស្រុង និងពាំនាំនូវរឿងដ៏គ្រោះថ្នាក់មួយនេះ មកជាមួយផង ថែមទាំងចងចាំអស់មួយជីវិត។

**(នៅមានវគ្គបន្ត)**




សៀវ សុផុន (រូបខាងឆ្វេង) និង ម៉ាត់ សុភាត់ នៅឆ្នាំ១៩៧៣។
(បណ្ណសារមជ្ឈមណ្ឌលឯកសារកម្ពុជា)

រូបក្របមុខ៖
កងទ័ពបដិវត្តន៍ខ្មែរក្រហមចូលគ្រប់គ្រងព្រលានយន្តហោះពោធិ៍ចិនតុង ថ្ងៃទី១៧ ខែមេសា ឆ្នាំ១៩៧៥។
(បណ្ណសារមជ្ឈមណ្ឌលឯកសារកម្ពុជា)

រូបក្របក្រោយ៖
ព្រលានយន្តហោះពោធិ៍ចិនតុងក្នុងរបបកម្ពុជាប្រជាធិបតេយ្យ (១៩៧៥-១៩៧៩)។
(បណ្ណសារមជ្ឈមណ្ឌលឯកសារកម្ពុជា)




**មជ្ឈមណ្ឌលឯកសារកម្ពុជា ៖ ការិយាល័យព័ត៌មានសាធារណៈ**
ផ្ទះលេខ១១ ផ្លូវ២៥៦ សង្កាត់ចតុមុខ ខណ្ឌដូនពេញ រាជធានីភ្នំពេញ ព្រះរាជាណាចក្រកម្ពុជា ទូរសព្ទ៖ (៨៥៥) ៧៨ ៦៩៨ ៣៣៣
DC-Cam/PIR: #11 ◆ Street 256 ◆ Sangkat Chaktomuk ◆ Khan Daun Penh ◆ Phnom Penh ◆ Cambodia 1110
Tel: (855) 23 211 875 ◆ dccam@online.com.kh ◆ www.dccam.org
A magazine of the Documentation Center of Cambodia: Searching for the Truth ◆ Issue 315, March 2026
Licensed by the Ministry of Information of the Kingdom of Cambodia, Prakas No. 375 P.M. PRA. KA, 30 October 2018.